ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# យុទ្ធសាស្ត្រជាតិស្តីពីការប្រឆាំង

# ការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម

# ឆ្នាំ២០១៩ - ២០២៣



# មាតិកា

**បុព្វកថា** ........ i
**សេចក្តីថ្លែងអំណរគុណ** ........ iii
**អក្សរកាត់** ........ iv
**ខ្លឹមសារសង្ខេប** ........ vi
**សេចក្តីផ្តើម និងទស្សនៈវិស័យ** ........ ១
**វិធីសាស្ត្រ** ........ ៥
**ទិដ្ឋភាពទូទៅនៃគោលដៅ និងគោលបំណង** ........ ៧
**គោលបំណងគន្លឹះជាយុទ្ធសាស្ត្រជាតិ** ........ ៩
**១. ការយល់ដឹង និងការកាត់បន្ថយហានិភ័យសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម** ........ ៩
១.១ ការកាត់បន្ថយហានិភ័យសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្មតាមវិស័យ និងស្ថាប័ន ........ ១០
១.២ ការកាត់បន្ថយបទល្មើសហិរញ្ញវត្ថុកើតឡើងពីលំហូរសាច់ប្រាក់ចេញ-ចូលខុសច្បាប់ ........ ១២
**២. វិធានការទប់ស្កាត់ និងការត្រួតពិនិត្យបុគ្គលរាយការណ៍** ........ ១៤
២.១ ការកែលម្អការអនុវត្តវិធានការប្រឆាំងការសម្អាតប្រាក់របស់បុគ្គលរាយការណ៍និងឧស្សាហកម្ម ........ ១៥
២.២ ការកែលម្អប្រព័ន្ធត្រួតពិនិត្យផ្អែកលើហានិភ័យ ........ ១៦
**៣. ការបង្កើនតម្លាភាពស្ថាប័ន** ........ ១៩
៣.១ បង្កើតក្របខ័ណ្ឌគោលនយោបាយអំពីអត្ថគាហកៈ ........ ១៩
៣.២ បង្កើនគុណភាព និងភាពសប្បូរបែបនៃព័ត៌មានរបស់អត្ថគាហកៈ ........ ១៩
**៤. ការប្រមូល ការវិភាគ និងការបញ្ជូនព័ត៌មានស៊ើបការណ៍ហិរញ្ញវត្ថុដែលមានសារៈប្រយោជន៍** ........ ២១
៤.១ ការពង្រឹងសមត្ថភាពរបស់អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា ........ ២១
៤.២ ស.ហ.ក គាំទ្រដល់ការអនុវត្តសកម្មភាពប្រឆាំង ស.ប.ហ.ភ ........ ២៣
**៥. ប្រសិទ្ធភាពនៃការស៊ើបអង្កេតការសម្អាតប្រាក់ និងសំអាងបទល្មើស** ........ ២៥
៥.១ ការកសាងធនធាននិងសមត្ថភាពរបស់អាជ្ញាធរទទួលខុសត្រូវការស៊ើបអង្កេតការសម្អាតប្រាក់ និងសំអាងនៃបទល្មើស (អគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គនាយកដ្ឋានពន្ធដារ អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា អង្គភាពប្រឆាំងអំពើពុករលួយ) ........ ២៦
៥.២ ការបង្កើនការស៊ើបអង្កេតការសម្អាតប្រាក់ និងបទល្មើសហិរញ្ញវត្ថុ ........ ២៩
**៦. ការជំរុញប្រសិទ្ធភាពនៃការចោទប្រកាន់ការសម្អាតប្រាក់ និងសំអាងនៃបទល្មើស** ........ ៣០
៦.១ បង្កើនធនធានសម្រាប់ការចោទប្រកាន់បទសម្អាតប្រាក់ និងសំអាងនៃបទល្មើស ........ ៣០
៦.២ ការកំណត់អាទិភាពការចោទប្រកាន់បទសម្អាតប្រាក់ ........ ៣២
**៧. ការជំរុញប្រសិទ្ធភាពនៃការរឹបអូសផលនៃបទល្មើស** ........ ៣៣
៧.១ ការពង្រឹងសមត្ថភាពស្ថាប័នទទួលខុសត្រូវក្នុងការរឹបអូសឧបករណ៍ និងផលនៃបទល្មើស ........ ៣៣
៧.២ ការកំណត់អាទិភាពការរឹបអូសផលនៃបទល្មើស ........ ៣៤
**៨. កិច្ចសហប្រតិបត្តិការអន្តរជាតិ** ........ ៣៦

៨.១ កែលម្អក្របខ័ណ្ឌគតិយុត្ត ដើម្បីធ្វើកិច្ចសហប្រតិបត្តិការអន្តរជាតិ ..... ៣៦
៨.២ សហប្រតិបត្តិការអន្តរជាតិ ..... ៣៦
**៩. ការប្រឆាំងហិរញ្ញប្បទានភេរវកម្មនិងហិរញ្ញប្បទាននៃការរីកសាយភាយអាវុធមហាប្រល័យ** ..... ៣៧
៩.១ កែលម្អក្របខ័ណ្ឌគតិយុត្ត ដើម្បីប្រឆាំងហិរញ្ញប្បទានការរីកសាយភាយអាវុធមហាប្រល័យ ..... ៣៧
៩.២ សហការជាមួយវិស័យឯកជន ដើម្បីប្រឆាំងហិរញ្ញប្បទានការរីកសាយភាយអាវុធមហាប្រល័យ ..... ៣៨
**១០. ការគ្រប់គ្រងកម្មវិធីជាតិស្តីពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម** ..... ៣៩
១០.១ ការតាមដានការអនុវត្តយុទ្ធសាស្ត្រជាតិស្តីពីការប្រឆាំង ស.ប.ហ.ភ ..... ៣៩
១០.២ ថវិកាគាំទ្រការអនុវត្តយុទ្ធសាស្ត្រជាតិ ឆ្នាំ២០១៩-២០២៣ ..... ៣៩
**ផែនការសកម្មភាព** ..... ៤០

# បុព្វកថា

ភាពរីកចម្រើនយ៉ាងឆាប់រហ័សនៃនវានុវត្តន៍ហិរញ្ញវត្ថុ ក្នុងសករាជនៃទំនើបកម្មបច្ចេកវិទ្យាបាន ធ្វើឲ្យប្រព័ន្ធហិរញ្ញវត្ថុសកលលោក ប្រឈមនឹងការគំរាមកំហែងពីការជ្រៀតចូលនៃលំហូររូបិយវត្ថុមិនស្រប ច្បាប់ ដែលបានមកពីផលនៃបទល្មើសចូលក្នុងប្រព័ន្ធហិរញ្ញវត្ថុ។ ការិយាល័យអង្គការសហប្រជាជាតិ សម្រាប់ត្រួតពិនិត្យគ្រឿងញៀននិងបទឧក្រិដ្ឋ បានប៉ាន់ស្មានចំនួនទឹកប្រាក់ដែលឧក្រិដ្ឋជនបានសម្អាត ផលនៃបទល្មើសមានប្រមាណពី ២ ទៅ ៥ ភាគរយនៃផលិតផលក្នុងស្រុកសរុបរបស់សកលលោក ឬ ប្រមាណពី ៨០០ ប៊ីលាន ទៅ ២ ទ្រីលានដុល្លារអាមេរិកក្នុងមួយឆ្នាំៗ។ ទិន្នន័យនេះបង្ហាញពីផលប៉ះពាល់ យ៉ាងខ្លាំងដល់ស្ថិរភាពសង្គមនិងសេដ្ឋកិច្ច ដែលរដ្ឋាភិបាលនៃបណ្តាប្រទេសទាំងឡាយត្រូវយកចិត្តទុកដាក់ ទប់ស្កាត់ និងបង្ក្រាបឲ្យបានទាន់ពេលវេលា តាមរយៈការស្វែងរកបទល្មើស ដើម្បីបង្កក និងរឹបអូសផល និងឧបករណ៍នៃបទល្មើសទាំងនេះ ហើយអាជ្ញាធរពាក់ព័ន្ធក៏បាន និងកំពុងដាក់ចេញវិធានការជាបន្តបន្ទាប់ ដើម្បីពង្រឹង និងបង្កើនប្រសិទ្ធភាពការងារប្រឆាំងបទល្មើសទាំងនេះ រួមទាំងបទល្មើសសម្អាតប្រាក់និង ហិរញ្ញប្បទានភេរវកម្ម។

ដើម្បីចូលរួមជាមួយសហគមន៍អន្តរជាតិ ក្នុងការប្រយុទ្ធប្រឆាំងនឹងការសម្អាតប្រាក់ និងហិរញ្ញប្បទាន ភេរវកម្ម ប្រទេសកម្ពុជា ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានដាក់ឲ្យអនុវត្តក្របខ័ណ្ឌគតិយុត្តជាបន្តបន្ទាប់ ដើម្បីទប់ស្កាត់ និងបង្ក្រាបរាល់សកម្មភាពបទល្មើសសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម រួមទាំង បទល្មើសឆ្លងដែន ឲ្យប្រកបដោយប្រសិទ្ធភាព។ ក្នុងបរិបទដែលបទល្មើសសម្អាតប្រាក់ និងហិរញ្ញប្បទាន ភេរវកម្មតែងតែវិវឌ្ឍន៍ជារូបភាពថ្មីៗនិងកាន់តែសាំញ៉ាំ និងបន្ទាប់ពីឯកសារយុទ្ធសាស្ត្រជាតិឆ្នាំ២០១៣-២០១៧ ផុតកាលកំណត់ ប្រទេសកម្ពុជាបានរៀបចំធ្វើបច្ចុប្បន្នកម្មឯកសារយុទ្ធសាស្ត្រជាតិ ស្តីពីការប្រឆាំងការ សម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ឆ្នាំ២០១៩-២០២៣ ដែលនឹងជំរុញប្រសិទ្ធភាពនៃការអនុវត្តការ ប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និងបទល្មើសផ្សេងទៀត ដែលកំពុងគំរាមកំហែងដល់ សេដ្ឋកិច្ច និងសង្គមនៅកម្រិតជាតិ តំបន់ និងសកលលោក។

យុទ្ធសាស្ត្រជាតិនេះមានកំណត់គោលបំណងជាយុទ្ធសាស្ត្រ និងផែនការសកម្មភាពតាមអាទិភាព និងពេលវេលាច្បាស់លាស់ ដែលអាជ្ញាធរពាក់ព័ន្ធសហការជាមួយវិស័យឯកជន ដើម្បីធានាប្រសិទ្ធភាព នៃការងារប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ឲ្យទទួលបានជោគជ័យ និងដោយឡែក ឆ្លើយតបនឹងអនុសាសន៍ដែលបានកំណត់ក្នុងរបាយការណ៍វាយតម្លៃអញ្ញមញ្ញ ស្តីពីការប្រឆាំងការសម្អាត ប្រាក់ និងហិរញ្ញប្បទានភេរវកម្មឆ្នាំ២០១៧ និងការវាយតម្លៃហានិភ័យថ្នាក់ជាតិឆ្នាំ២០១៦។

ការរៀបចំយុទ្ធសាស្ត្រជាតិនេះ ដែលបញ្ជាក់ពីការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ទទួលបានជំនួយបច្ចេកទេសពីមូលនិធិរូបិយវត្ថុអន្តរជាតិ ព្រមទាំងមានការពិគ្រោះយោបល់ពីក្រសួង-ស្ថាប័នពាក់ព័ន្ធ ដើម្បីប្រមូលរាល់ធាតុចូលទាំងអស់ឲ្យបានគ្រប់ជ្រុងជ្រោយ ក្នុងគោលបំណងជំរុញប្រសិទ្ធភាពនៃការអនុវត្តច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធនឹងការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្មឲ្យបានជោគជ័យ។

ថ្ងៃពុធ ៧រោច ខែអស្សុជ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៨

**ទេសាភិបាល និងជាប្រធានគណៈកម្មាធិការ**
**សម្របសម្រួលថ្នាក់ជាតិប្រឆាំង**
**ការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម**

**ជា ចាន់តូ**

# សេចក្តីថ្លែងអំណរគុណ

គណៈកម្មាធិការសម្របសម្រួលថ្នាក់ជាតិប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម (គ.ស.ហ) សូមថ្លែងអំណរគុណចំពោះក្រុមការងារបច្ចេកទេសអន្តរក្រសួងប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម (ក.ប.ស.ហ) ទាំង ២២ ក្រសួង-ស្ថាប័ន ដឹកនាំដោយអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា (ស.ហ.ក) ដែលបានចំណាយពេលវេលាដ៏មានតម្លៃ សហការរៀបចំ ផ្តល់ធាតុចូល និងចែករំលែកបទពិសោធន៍ការងារជាមូលដ្ឋានក្នុងការឆ្លើយកម្រងសំណួរ ដើម្បីរៀបចំឯកសារ "យុទ្ធសាស្ត្រជាតិស្តីពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្មឆ្នាំ២០១៩-២០២៣" ប្រកបដោយជោគជ័យ។

ទន្ទឹមនេះ គ.ស.ហ ក៏សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅផងដែរដល់ថ្នាក់ដឹកនាំជាន់ខ្ពស់ក្រសួង-ស្ថាប័នពាក់ព័ន្ធ ដែលបានចាត់បញ្ជូនមន្ត្រីជំនាញ និងលើកទឹកចិត្តក្រុមការងារ ក.ប.ស.ហ ឲ្យបំពេញការងាររៀបចំយុទ្ធសាស្ត្រជាតិនេះឲ្យសម្រេចបានជាផ្លែផ្កាគួរជាទីកោតសរសើរ។ ជាពិសេស ស.ហ.ក ដែលបានដើរតួនាទីយ៉ាងសកម្ម ក្នុងការដឹកនាំ រៀបចំ សម្របសម្រួលការងារ និងបកប្រែឯកសារយុទ្ធសាស្ត្រជាតិនេះប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព។

ជាមួយគ្នានេះដែរ ការងាររៀបចំឯកសារយុទ្ធសាស្ត្រជាតិនេះអាចសម្រេចទៅបានដោយជោគជ័យក៏អាស្រ័យដោយមានការជួយឧបត្ថម្ភ គាំទ្រទាំងថវិកា និងជំនួយបច្ចេកទេសពីមូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) និងម្ចាស់ជំនួយមូលនិធិ Thematic Trust Fund មានប្រទេសន័រវេស ស្វីស ជប៉ុន កាតា អារ៉ាប៊ីសាអូឌីត អង់គ្លេស លុចសំបួ ហូឡង់ និង បារាំង ដែលបានផ្តល់ក្រុមការងារជំនួយបច្ចេកទេសដឹកនាំដោយលោក Clive Scott ទីប្រឹក្សាប្រចាំតំបន់ និងសហការី រួមមាន លោកស្រី Kristel Poh លោកស្រី Kathleen Kao និងលោក Thomas Hansen ក្នុងការរៀបចំឯកសារយុទ្ធសាស្ត្រជាតិនេះ ដែល គ.ស.ហ សូមសម្តែងនូវអំណរគុណយ៉ាងជ្រាលជ្រៅជាទីបំផុតផងដែរ។

# អក្សរកាត់

| | | |
|---|---|---|
| Anti-Corruption Unit | អង្គភាពប្រឆាំងអំពើពុករលួយ | អ.ប.ព (ACU) |
| Asia/Pacific Group on Money Laundering | ក្រុមប្រទេសអាស៊ីប៉ាស៊ីហ្វិក ស្តីពីការសម្អាតប្រាក់ | APG |
| Beneficial Ownership | អត្ថគាហកៈ | BO |
| Cambodia Financial Intelligence Unit | អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា | ស.ហ.ក (CAFIU) |
| Central Authority | អាជ្ញាធរកណ្តាល | CA |
| Office of the Council of Ministers | ទីស្តីការគណៈរដ្ឋមន្ត្រី | COM |
| Democratic People's Republic of Korea | សាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យកូរ៉េ | DPRK |
| Designated Non-Financial Businesses and Professions | មុខរបរនិងវិជ្ជាជីវៈមិនមែនហិរញ្ញវត្ថុ | DNFBPs |
| Financial Action Task Force | ក្រុមការងារហិរញ្ញវត្ថុ | FATF |
| General Commissariat of National Police | អគ្គស្នងការដ្ឋាននគរបាលជាតិ | GCNP |
| General Department of Taxation | អគ្គនាយកដ្ឋានពន្ធដារ | GDT |
| General Department of Customs and Excise of Cambodia | អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា | GDCE |
| Law Enforcement Agency | អាជ្ញាធរអនុវត្តច្បាប់ | LEA |
| Ministry Of Commerce | ក្រសួងពាណិជ្ជកម្ម | MOC |
| Ministry of Economic and Finance | ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | MEF |
| Ministry of Foreign Affairs and International Cooperation | ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | MFA-IC |
| Ministry of Interior | ក្រសួងមហាផ្ទៃ | MOI |
| Ministry of Justice | ក្រសួងយុត្តិធម៌ | MOJ |
| Ministry of Land Management, Urban Planning and Construction | ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | MLMUPC |
| Ministry of Posts and Telecommunications | ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | MPT |
| Ministry of Public Work and Transportation | ក្រសួងសាធារណការ និងដឹកជញ្ជូន | MPWT |
| Money Laundering and Terrorist Financing | ការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម | ស.ប.ហ.ភ (ML/TF) |
| Mutual Evaluation Report | របាយការណ៍វាយតម្លៃអញ្ញមញ្ញ | MER |
| The Technical Inter-Ministries Working Group on Anti-Money Laundering and Combating the Financing of Terrorism | ក្រុមការងារអន្តរក្រសួងប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម | ក.ប.ស.ហ(MEWG) |
| Mutual Legal Assistance | ជំនួយផ្នែកច្បាប់ទៅវិញទៅមកក្នុងវិស័យព្រហ្មទណ្ឌ | MLA |
| National Accounting Council | ក្រុមប្រឹក្សាជាតិគណនេយ្យ | NAC |

| | | |
|---|---|---|
| National Bank of Cambodia | ធនាគារជាតិនៃកម្ពុជា | NBC |
| National Coordination Committee on Anti- Money Laundering and Terrorist Financing | គណៈកម្មាធិការសម្របសម្រួលថ្នាក់ជាតិប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម | គ.ស.ហ (NCC) |
| National Risk Assessment on Money Laundering and Terrorist Financing | ការវាយតម្លៃហានិភ័យថ្នាក់ជាតិស្តីពីការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម | NRA |
| National Strategy on Anti-Money Laundering and Combating the Financing of Terrorism 2019-2023 | យុទ្ធសាស្ត្រជាតិ ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្មឆ្នាំ២០១៩-២០២៣ | National Strategy on AML/CFT 2019-2023 |
| Non-Profit Organizations | អង្គការក្រៅរាជរដ្ឋាភិបាល | NPOs |
| Politically Exposed Persons | បុគ្គលពាក់ព័ន្ធនយោបាយ | PEPs |
| Proliferation Financing | ហិរញ្ញប្បទានការរីកសាយភាយអាវុធមហាប្រល័យ | PF |
| National Authority for Combating Drugs | អាជ្ញាធរជាតិប្រយុទ្ធប្រឆាំង គ្រឿងញៀន | NACD |
| Secretariat National Counter Terrorism Committee | លេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងភេរវកម្ម | SNCTC |
| Securities and Exchange Commission of Cambodia | គណៈកម្មការមូលបត្រកម្ពុជា | SECC |
| Trade-Based Money Laundering | ការសម្អាតប្រាក់ជាទម្រង់ពាណិជ្ជកម្ម | TBML |
| United Nation Security Council Resolutions | សេចក្តីសម្រេចចិត្តរបស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ | UNSCR |

# ខ្លឹមសារសង្ខេប

ប្រទេសកម្ពុជាយើងបានដាក់ចេញនូវគោលនយោបាយ និងវិធានការជាច្រើន ដើម្បីការពារគ្រឹះស្ថានហិរញ្ញវត្ថុ និងសេដ្ឋកិច្ចជាតិ ពីឥទ្ធិពលនៃការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម (ស.ប.ហ.ភ) បន្ទាប់ពីយើងបានចូលជាសមាជិករបស់ក្រុមប្រទេសអាស៊ីប៉ាស៊ីហ្វិក ស្តីពីការសម្អាតប្រាក់ កាលពីឆ្នាំ២០០៤។

ប្រទេសកម្ពុជាយើងមានក្របខ័ណ្ឌច្បាប់គ្រប់ជ្រុងជ្រោយសម្រាប់ប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម យើងបានបង្កើតអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា (ស.ហ.ក) និងភាគីពាក់ព័ន្ធសំខាន់ៗជាច្រើនបានចូលរួមដោះស្រាយបញ្ហាប្រឈមនានា ដែលកើតចេញពីការសម្អាតប្រាក់ និងសំអាងនៃបទល្មើសផ្សេងៗ។

ខណៈដែលកម្ពុជាយើងកំពុងខិតខំប្រឹងប្រែងប្រឆាំង ស.ប.ហ.ភ ក៏មានការខិតខំសម្របសម្រួលកិច្ចសហប្រតិបត្តិការរវាងភាគីពាក់ព័ន្ធ ដើម្បីបានជាកម្លាំងសរុបការពារកម្ពុជាឲ្យជៀសផុតពីឥទ្ធិពលនៃបទល្មើសហិរញ្ញវត្ថុ។ កិច្ចខិតខំប្រឹងប្រែងទាំងនេះមានដូចជា ការបង្កើតគណៈកម្មាធិការសម្របសម្រួលថ្នាក់ជាតិប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម (គ.ស.ហ) កាលពីឆ្នាំ២០១២ ការរៀបចំយុទ្ធសាស្ត្រជាតិស្តីពីការប្រឆាំង ស.ប.ហ.ភ ឆ្នាំ២០១៣-២០១៧ និងការបញ្ចប់ការវាយតម្លៃហានិភ័យថ្នាក់ជាតិ ស្តីពីការប្រឆាំងការ ស.ប.ហ.ភ កាលពីឆ្នាំ២០១៦។

ការផុតកំណត់យុទ្ធសាស្ត្រជាតិឆ្នាំ២០១៣-២០១៧ និងការផ្សព្វផ្សាយរបាយការណ៍វាយតម្លៃអញ្ញមញ្ញលើកទី២ របស់ប្រទេសកម្ពុជា ដោយក្រុមប្រទេសអាស៊ីប៉ាស៊ីហ្វិក ស្តីពីការសម្អាតប្រាក់កាលពីឆ្នាំ២០១៧ ជាមូលហេតុដែលធ្វើឲ្យរាជរដ្ឋាភិបាលកម្ពុជា រៀបចំយុទ្ធសាស្ត្រជាតិ ស្តីពី ការប្រឆាំង ស.ប.ហ.ភ ឆ្នាំ២០១៩-២០២៣ នេះ ដើម្បី ១/- ឆ្លើយតបនឹងកម្រិតហានិភ័យ ស.ប.ហ.ភ ដែលរកឃើញពីការវាយតម្លៃហានិភ័យថ្នាក់ជាតិ ស្តីពីប្រឆាំង ស.ប.ហ.ភ ២/- ឆ្លើយតបនឹងអនុសាសន៍ក្នុងរបាយការណ៍ការវាយតម្លៃអញ្ញមញ្ញ និង៣/- កំណត់ទិសដៅនៃគោលនយោបាយ និងប្រតិបត្តិការដល់គ្រប់ភាគីពាក់ព័ន្ធនឹងកម្មវិធីប្រឆាំង ស.ប.ហ.ភ សម្រាប់រយៈពេល ៥ ឆ្នាំ ខាងមុខ។

បណ្តាក្រសួង-ស្ថាប័ន និងភាគីពាក់ព័ន្ធនានាបានពិគ្រោះយោបល់គ្នា ពិភាក្សាជាក្រុម និងឆ្លើយកម្រងសំណួរជាច្រើន ដើម្បីរៀបចំយុទ្ធសាស្ត្រជាតិឆ្នាំ២០១៩-២០២៣ នេះ។

យុទ្ធសាស្ត្រជាតិឆ្នាំ២០១៩-២០២៣ នេះមានគោលបំណងជាយុទ្ធសាស្ត្រសំខាន់ៗចំនួន ១០រួមមានៈ

- ការយល់ដឹង និងការគ្រប់គ្រងហានិភ័យ
- ការផ្តល់អាជ្ញាប័ណ្ណនិងការត្រួតពិនិត្យគ្រឹះស្ថានហិរញ្ញវត្ថុ និងមុខរបរនិងវិជ្ជាជីវៈមិនមែនហិរញ្ញវត្ថុ និងការអនុវត្តវិធានការទប់ស្កាត់

- ការពង្រឹងតម្លាភាពស្ថាប័ន
- ការប្រមូល ការវិភាគ និងការបញ្ជូនរបាយការណ៍សើុបការណ៍ហិរញ្ញវត្ថុដែលមានគុណភាព
- ការសើុបអង្កេតនូវសំអាងបទល្មើស និងបទសម្អាតប្រាក់ប្រកបដោយប្រសិទ្ធភាព
- ការកាត់ទោសសំអាងបទល្មើស និងបទសម្អាតប្រាក់ប្រកបដោយប្រសិទ្ធភាព
- ការរឹបអូសផលនៃសំអាងបទល្មើសនិងបទសម្អាតប្រាក់ប្រកបដោយប្រសិទ្ធភាព
- កិច្ចសហប្រតិបត្តិការអន្តរជាតិប្រកបដោយប្រសិទ្ធភាព
- ការស្វែងរក និងការលុបបំបាត់ចោលហិរញ្ញប្បទានភេរវកម្មនិងហិរញ្ញប្បទាននៃការរីកសាយភាយអាវុធមហាប្រល័យ និង
- ការគ្រប់គ្រងកម្មវិធីជាតិស្តីពីការប្រឆាំង ស.ប.ហ.ភ ។

គោលបំណងនីមួយៗមានពន្យល់លម្អិតនៅក្នុងយុទ្ធសាស្ត្រជាតិនេះ។ សកម្មភាពនីមួយៗដែលត្រូវអនុវត្តដើម្បីសម្រេចគោលបំណងជាយុទ្ធសាស្ត្រទាំងនេះ មានលម្អិតក្នុងផែនការសកម្មភាពនៅក្នុងឧបសម្ព័ន្ធ។ សកម្មភាពអាទិភាពនីមួយៗ និងពេលវេលាដែលត្រូវបញ្ចប់សកម្មភាពទាំងនេះ អាស្រ័យតាមកម្រិតហានិភ័យដែលរកឃើញពីការវាយតម្លៃហានិភ័យថ្នាក់ជាតិ ស្តីពីប្រឆាំង ស.ប.ហ.ភ និងតាមអាទិភាពនៃកម្មវិធីជាតិប្រឆាំង ស.ប.ហ.ភ។

យុទ្ធសាស្ត្រជាតិនេះបង្កើនប្រសិទ្ធភាពនៃកិច្ចសម្របសម្រួលថ្នាក់ជាតិ រវាងភាគីពាក់ព័ន្ធសំខាន់ៗក្នុងការប្រឆាំង ស.ប.ហ.ភ និងផ្តល់ជាផែនទីមគ្គុទ្ទេសន៍សម្រាប់អនុវត្តមួយជាក់ស្តែង និងច្បាស់លាស់ជូនបណ្តាក្រសួង-ស្ថាប័ន និងភាគីពាក់ព័ន្ធនានា ដែលទទួលខុសត្រូវអនុវត្តកម្មវិធីប្រឆាំង ស.ប.ហ.ភ នៅប្រទេសកម្ពុជា ដោយត្រូវមានធនធានសមស្រប និងគ្រប់គ្រាន់។

# សេចក្តីផ្តើម និងទស្សនៈវិស័យ

ប្រទេសកម្ពុជាបានឆ្លងកាត់ដំណាក់កាលនៃសង្គ្រាម និងការផ្លាស់ប្តូររបបគ្រប់គ្រងរដ្ឋជាបន្តបន្ទាប់។ បន្ទាប់ពីការដួលរលំរបបប៉ុលពត ប្រទេសកម្ពុជាបានចាប់ផ្តើមកសាងប្រទេសឡើងវិញពីបាតដៃទទេ ដោយដៃម្ខាងខិតខំដោះស្រាយភាពអត់ឃ្លានរបស់ប្រជាជន និងដៃម្ខាងខិតខំតស៊ូរក្សាសុខសន្តិភាព និងស្ថិរភាពជូនប្រទេសជាតិ ក្នុងដំណាក់កាលពីឆ្នាំ១៩៧៩-១៩៩៣។ បន្ទាប់ពីកិច្ចព្រមព្រៀងទីក្រុងប៉ារីស ឆ្នាំ១៩៩១ ប្រទេសកម្ពុជារៀបចំការបោះឆ្នោតសកលលើកទី១ នៅឆ្នាំ១៩៩៣ និងទើបតែនៅក្រោយពេលសង្គ្រាមស៊ីវិលបានបញ្ចប់ និងទទួលបានសន្តិភាពពេញលេញចាប់ពីឆ្នាំ១៩៩៨ ប៉ុណ្ណោះ ដែលប្រទេសកម្ពុជាអាចផ្តោតលើការកសាងប្រទេសជាតិបានពេញដៃពេញជើង។

ក្នុងរយៈពេលតែ ២០ឆ្នាំ ចុងក្រោយ រាជរដ្ឋាភិបាលសម្រេចបាននូវសមិទ្ធផលជាច្រើន ដោយបានរៀបចំស្ថាប័នរដ្ឋ កសាងក្របខ័ណ្ឌច្បាប់ និងបទប្បញ្ញត្តិថ្មីៗ ស្របពេលជាមួយគ្នានឹងការធានាសុខសន្តិភាព និងស្ថិរភាពនយោបាយ និងការអភិវឌ្ឍសេដ្ឋកិច្ចសង្គម។ សមិទ្ធផលទាំងនេះជាមូលដ្ឋានគ្រឹះនៃការពង្រឹងនីតិរដ្ឋ និងជំរុញលទ្ធិប្រជាធិបតេយ្យ ដែលគាំទ្រដល់ការគោរពសិទ្ធមនុស្ស។ ចាប់តាំងពីឆ្នាំ២០០៣ មក រាជរដ្ឋាភិបាលបានផ្តោតការយកចិត្តទុកដាក់ខ្ពស់ និងផ្តល់អាទិភាពដល់ការធ្វើកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌។ ផែនការយុទ្ធសាស្ត្រ ផែនការអភិវឌ្ឍន៍ជាតិ លិខិតបទដ្ឋានច្បាប់និងគតិយុត្ត និងសកម្មភាពជាច្រើន ក៏ដូចជាការងារប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ត្រូវបានដាក់ចេញ ដើម្បីសម្រេចឲ្យបានជោគជ័យនៃកំណែទម្រង់នេះ។

ដោយការប្តេជ្ញាចិត្តខ្ពស់ក្នុងការកែទម្រង់ ប្រទេសកម្ពុជាទទួលបាននូវកំណើនសេដ្ឋកិច្ចខ្ពស់ និងមានកម្រិតអតិផរណាអាចគ្រប់គ្រងបាន ក្នុងអំឡុងពេល ២ ទសវត្សរ៍មកនេះ។ ក្នុងចន្លោះឆ្នាំ១៩៩៥-២០១៧ សេដ្ឋកិច្ចប្រទេសកម្ពុជាមានអត្រាកំណើនមធ្យមប្រមាណ ៧,៧ ភាគរយក្នុងមួយឆ្នាំ ដែលមានសសរស្តម្ភដ៏រឹងមាំចំនួន ៤ គាំទ្រដល់កំណើននេះ រួមមាន វិស័យកសិកម្ម វិស័យកម្មន្តសាល វិស័យសំណង់ និងវិស័យទេសចរណ៍។ លើសពីនេះ ប្រទេសកម្ពុជាបានប្តេជ្ញាចិត្តធ្វើសមាហរណកម្មសេដ្ឋកិច្ចរបស់ខ្លួនទៅក្នុងតំបន់និងពិភពលោក។ ប្រទេសកម្ពុជាមានឧត្តមភាពប្រកួតប្រជែងនៅលើទីផ្សារអន្តរជាតិ និងអាចទាក់ទាញវិនិយោគិនបរទេស ដើម្បីចូលរួមពង្រីកសេដ្ឋកិច្ចជាតិបន្ថែមទៀត។ ប៉ុន្តែភាពរីកចម្រើនទាំងនេះក៏ធ្វើឲ្យរាជរដ្ឋាភិបាលកម្ពុជាត្រូវយកចិត្តទុកដាក់តាមដានហានិភ័យ ដែលអាចកើតឡើងពីកំណើនសេដ្ឋកិច្ចខ្ពស់ពេក ដូចជាការប្រែប្រួលមិនទៀងទាត់នៃលំហូរទុន និងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម (ស.ប.ហ.ភ) ជាដើម។

នៅឆ្នាំ២០០៤ ប្រទេសកម្ពុជាបានចូលជាសមាជិករបស់ក្រុមប្រទេសអាស៊ីប៉ាស៊ីហ្វិក ស្តីពីការសម្អាតប្រាក់ (ក្រុមប្រទេសអាស៊ីប៉ាស៊ីហ្វិក-APG) និងបានប្តេជ្ញាចិត្តអនុវត្តតាមអនុសាសន៍ចំនួន

៤០ បូក ៩ របស់ក្រុមការងារហិរញ្ញវត្ថុ (FATF)។ នៅឆ្នាំ២០០៧ ប្រទេសកម្ពុជាបានអនុម័តច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម និងច្បាប់ស្តីពីការប្រឆាំងភេរវកម្ម។ ក្នុងឆ្នាំនោះដែរ ប្រទេសកម្ពុជា បានទទួលការវាយតម្លៃអញ្ញមញ្ញស្តីពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្មពី APG ដោយមានការចូលរួមពីធនាគារពិភពលោក។

នៅឆ្នាំ២០០៩ ប្រទេសកម្ពុជាបានអនុម័តក្រមព្រហ្មទណ្ឌ ដែលបញ្ចូលបញ្ញត្តិពីការដាក់ទោសដល់ការសម្អាតប្រាក់។ បទសម្អាតប្រាក់ដែលមានចែងក្នុងច្បាប់ស្តីពីវិសោធនកម្មមាត្រា៣ មាត្រា២៩ និងមាត្រា៣០ នៃច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ឆ្នាំ២០១៣ កាន់តែមានភាពលម្អិតនិងស្របតាមការតម្រូវនៃស្តង់ដារបស់ FATF។

នៅឆ្នាំ២០០៨ អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា (ស.ហ.ក) បានបង្កើតឡើងជាអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុស្វយ័ត ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ធនាគារជាតិនៃកម្ពុជា។ ស.ហ.ក ជាអង្គភាពបែបរដ្ឋបាល ហើយទន្ទឹមនោះដែរ ក៏ទទួលខុសត្រូវត្រួតពិនិត្យការងារប្រឆាំង ស.ប.ហ.ភ របស់បុគ្គលរាយការណ៍ដូចមានចែងក្នុងច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម។ ធនាគារជាតិនៃកម្ពុជា បានចេញប្រកាសស្តីពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ឆ្នាំ២០០៨ ចំពោះបុគ្គលរាយការណ៍ជាគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដែលស្ថិតនៅក្រោមអាណាព្យាបាលរបស់ធនាគារជាតិនៃកម្ពុជា និងប្រកាសស្តីពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្មរបស់បុគ្គលរាយការណ៍ដែលមិនស្ថិតក្រោមការគ្រប់គ្រងរបស់ធនាគារជាតិនៃកម្ពុជា ឆ្នាំ២០១០ អនុវត្តចំពោះបុគ្គលរាយការណ៍ផ្សេងទៀត ដើម្បីអនុវត្តច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ឲ្យកាន់តែមានប្រសិទ្ធភាព។

នៅឆ្នាំ២០១០ ប្រទេសកម្ពុជាបានអនុម័តច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ និងបានបង្កើតអង្គភាពប្រឆាំងអំពើពុករលួយ ដើម្បីប្រឆាំងអំពើពុករលួយ។

សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាបានបង្កើតគណៈកម្មាធិការសម្របសម្រួលថ្នាក់ជាតិប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម (គ.ស.ហ) នៅឆ្នាំ២០១២ ដើម្បីសម្របសម្រួលកម្មវិធីប្រឆាំង ស.ប.ហ.ភ ដែលកាន់តែស្មុគស្មាញឲ្យបានត្រឹមត្រូវ។ គ.ស.ហ បានអនុវត្តការងារដំបូងរបស់ខ្លួនដោយរៀបចំនិងដាក់ឲ្យអនុវត្តយុទ្ធសាស្ត្រជាតិ ស្តីពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ឆ្នាំ២០១៣-២០១៧ (យុទ្ធសាស្ត្រជាតិ ឆ្នាំ២០១៣-២០១៧)។ យុទ្ធសាស្ត្រជាតិ ឆ្នាំ២០១៣-២០១៧ ជាឯកសារដំបូងផ្តល់ជាមគ្គុទ្ទេសក៍ដល់ក្រសួង-ស្ថាប័នជាច្រើនដែលទទួលខុសត្រូវរួមលើការងារប្រឆាំង ស.ប.ហ.ភ នៅប្រទេសកម្ពុជា។

នៅឆ្នាំ២០១៦ ប្រទេសកម្ពុជាបានវាយតម្លៃហានិភ័យថ្នាក់ជាតិ ស្ដីពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម (ការវាយតម្លៃហានិភ័យថ្នាក់ជាតិ-NRA) ស្របតាមចំណុច ២.៣ នៃយុទ្ធសាស្ត្រជាតិ ឆ្នាំ២០១៣-២០១៧។ ការវាយតម្លៃលម្អិតនេះបានវិភាគពីការគំរាមកំហែង និងភាពងាយរងគ្រោះនៃ ស.ប.ហ.ភ នៅប្រទេសកម្ពុជា។ ការវាយតម្លៃពីភាពងាយរងគ្រោះនៃ ស.ប.ហ.ភ តាមវិស័យនីមួយៗ ក៏បានគ្របដណ្ដប់លើសកម្មភាពហិរញ្ញវត្ថុទាំងតូចទាំងធំនៃវិស័យធនាគារនិងហិរញ្ញវត្ថុ និងមុខរបរនិងវិជ្ជាជីវៈមិនមែនហិរញ្ញវត្ថុ (DNFBPs)។

នៅឆ្នាំ២០១៦ ប្រទេសកម្ពុជាបានទទួលការវាយតម្លៃអញ្ញមញ្ញលើការងារប្រឆាំង ស.ប.ហ.ភ ថ្នាក់ជាតិជាលើកទី ២ ដោយ APG។ មហាសន្និបាតប្រចាំឆ្នាំរបស់ APG បានអនុម័តរបាយការណ៍វាយតម្លៃអញ្ញមញ្ញនេះនៅទីក្រុងកូឡុំបូ ប្រទេសស្រីលង្កា នៅខែកក្កដា ឆ្នាំ២០១៧។

ការផុតកំណត់នៃយុទ្ធសាស្ត្រជាតិ ឆ្នាំ២០១៣-២០១៧ គឺជាមូលហេតុទីមួយនៃការរៀបចំយុទ្ធសាស្ត្រជាតិ ស្ដីពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ឆ្នាំ២០១៩-២០២៣ (យុទ្ធសាស្ត្រជាតិ ឆ្នាំ២០១៩-២០២៣) សម្រាប់ប្រទេសកម្ពុជាប្រើប្រាស់ជាឯកសារមគ្គុទ្ទេសក៍ក្នុងការអភិវឌ្ឍរយៈពេល ៥ឆ្នាំ ខាងមុខ។

របាយការណ៍វាយតម្លៃអញ្ញមញ្ញរបស់ប្រទេសកម្ពុជា (របាយការណ៍អញ្ញមញ្ញ) ឆ្នាំ២០១៧ ដែលមានអនុសាសន៍សំខាន់ៗជាច្រើន សម្រាប់កែលម្អកម្មវិធីប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម គឺជាមូលហេតុទីពីរ ក្នុងការរៀបចំយុទ្ធសាស្ត្រជាតិ ឆ្នាំ២០១៩-២០២៣។

ការប្រែប្រួលសំខាន់ៗនៃស្ថានភាពហិរញ្ញវត្ថុ និងប្រជាជនរបស់ប្រទេសកម្ពុជា ដែលបាននិងកំពុងកើតឡើងជាងពីរទសវត្សរ៍កន្លងមកនេះ គឺជាមូលហេតុទីបី សម្រាប់ការរៀបចំយុទ្ធសាស្ត្រជាតិ ឆ្នាំ២០១៩-២០២៣។ ក្នុងចន្លោះឆ្នាំ១៩៩៥-២០១៧ សេដ្ឋកិច្ចប្រទេសកម្ពុជាមានអត្រាកំណើនចំនួនប្រមាណ ៧,៧ ភាគរយ ដែលជាអត្រាកំណើនកម្រិតខ្ពស់ជាងគេលំដាប់ទី៦[១] ក្នុងពិភពលោក។ ក្នុងអំឡុងពេលនេះ ភាពក្រីក្រនៅប្រទេសកម្ពុជាបានធ្លាក់ចុះយ៉ាងឆាប់រហ័ស។ ឆ្នាំ២០១៤ អត្រាភាពក្រីក្រមានចំនួន ១៣,៥ ភាគរយ។ ប្រាំពីរឆ្នាំមុននេះ អត្រាភាពក្រីក្រមានចំនួន ៤៧,៨ ភាគរយ។ សេដ្ឋកិច្ចប្រទេសកម្ពុជាមានកំណើនស្របគ្នានឹងកំណើនវិស័យហិរញ្ញវត្ថុសំខាន់ៗមួយចំនួន ឧទាហរណ៍ នៅឆ្នាំ២០០៧ ធនាគារពាណិជ្ជមានចំនួន ១៧ ហើយនៅឆ្នាំ២០១៧ ចំនួននេះបានកើនឡើងទ្វេដងរហូតដល់ចំនួន ៣៩។ ដើម្បីធានានិរន្តរភាពនៃកំណើន និងវិធានការកាត់បន្ថយភាពក្រីក្រនេះបាន ប្រទេសកម្ពុជាត្រូវរក្សាឲ្យបាននូវសុចរិតភាពនៃប្រព័ន្ធហិរញ្ញវត្ថុរបស់ខ្លួន។

[១] ទិន្នន័យរបស់ធនាគារពិភពលោក

បើទោះបីជាមានការបង្កើនបុគ្គលិក និងធនធាននៅថ្នាក់បច្ចេកទេសសម្រាប់ការងារប្រឆាំង ស.ប.ហ.ភ ការកើនឡើងនេះក៏នៅមិនទាន់មានសន្ទុះស្របតាមកំណើនហេដ្ឋារចនាសម្ព័ន្ធសេដ្ឋកិច្ចនិងទីផ្សារ ឬការរីកវិសាលភាពនិងភាពស្មុគស្មាញនៃឧក្រិដ្ឋកម្ម ទាំងក្នុងនិងក្រៅស្រុក ដែលស្វះស្វែងកេងចំណេញពីវិស័យហិរញ្ញវត្ថុនៅប្រទេសកម្ពុជា។

យុទ្ធសាស្រ្តជាតិ ឆ្នាំ២០១៩-២០២៣ នេះ សង្កត់ធ្ងន់លើសារៈសំខាន់នៃបញ្ហាគន្លឹះមួយចំនួនដូចខាងក្រោម៖

- ក្រសួង-ស្ថាប័នសំខាន់ៗ និងអង្គភាពទទួលខុសត្រូវអនុវត្តការងារប្រឆាំង ស.ប.ហ.ភ ត្រូវបង្កើនធនធាន បន្ថែមទៀត ដើម្បីអនុវត្តភារកិច្ចរបស់ខ្លួនឲ្យបានត្រឹមត្រូវ។
- គ្រប់ភាគីពាក់ព័ន្ធទាំងអស់ ត្រូវផ្តល់អាទិភាពខ្ពស់លើប្រសិទ្ធភាពនៃការអនុវត្តវិធានការប្រឆាំង ស.ប.ហ.ភ ពោលគឺ៖
    - បុគ្គលរាយការណ៍ត្រូវរៀបចំ និងអនុវត្តគោលនយោបាយប្រឆាំង ស.ប.ហ.ភ ឲ្យបានល្អ
    - ស.ហ.ក ត្រូវប្រមូល វិភាគ និងបញ្ជូនរបាយការណ៍ស៊ើបការណ៍ហិរញ្ញវត្ថុឲ្យមានប្រសិទ្ធភាព
    - បុគ្គលរាយការណ៍ត្រូវរងការត្រួតពិនិត្យផ្អែកលើហានិភ័យស្តីពីការប្រឆាំង ស.ប.ហ.ភ និង
    - អាជ្ញាធរអនុវត្តច្បាប់ត្រូវស៊ើបអង្កេត ចោទប្រកាន់ ព្រមទាំងដាក់ទណ្ឌកម្មជនល្មើសសម្អាតប្រាក់ និងរឹបអូសផលនៃបទល្មើសឲ្យមានប្រសិទ្ធភាព។
- គ្រប់ភាគីពាក់ព័ន្ធទាំងអស់ត្រូវធ្វើកិច្ចសហប្រតិបត្តិការ និងកិច្ចសម្របសម្រួល ទាំងក្នុងនិងក្រៅក្រសួង-ស្ថាប័ន ឲ្យមានប្រសិទ្ធភាព ដើម្បីសម្រេចគោលបំណងប្រឆាំង ស.ហ.ប.ភ។

# វិធីសាស្ត្រ

ការរៀបចំយុទ្ធសាស្ត្រជាតិ ឆ្នាំ២០១៩-២០២៣ មានអ្នកចូលរួមប្រមាណ ៧០ រូប មកពីក្រសួង-ស្ថាប័ន ចំនួន ២២ រួមមាន ១/- អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា ២/- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ៣/- អង្គភាពប្រឆាំងអំពើពុករលួយ ៤/- ក្រសួងយុត្តិធម៌ ៥/- ក្រសួងមហាផ្ទៃ (i. នាយកដ្ឋានកិច្ចការសមាគម និងគណបក្សនយោបាយ ii. អគ្គនាយកដ្ឋានអន្តោប្រវេសន៍ iii. អគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម iv. អគ្គស្នងការដ្ឋាននគរបាលជាតិ) ៦/- ទីស្តីការគណៈរដ្ឋមន្ត្រី ៧/- ក្រសួងពាណិជ្ជកម្ម ៨/- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ៩/- ក្រសួងរៀបចំ ដែនដី នគរូបនីយកម្ម និងសំណង់ ១០/- ក្រសួងសាធារណការ និងដឹកជញ្ជូន ១១/- ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ១២/- ធនាគារជាតិនៃកម្ពុជា ១៣/- លេខាធិការដ្ឋាន គណៈកម្មាធិការជាតិប្រឆាំងភេរវកម្ម ១៤/- អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ១៥/- គណៈកម្មការ មូលបត្រកម្ពុជា ១៦/- អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ១៧/- អគ្គនាយកដ្ឋានពន្ធដារ ១៨/- ក្រុមប្រឹក្សាជាតិ គណនេយ្យ និង១៩/- គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ជាដើម។

គ.ស.ហ បានរៀបចំយុទ្ធសាស្ត្រជាតិ ឆ្នាំ២០១៩-២០២៣ ដោយប្រគល់ភារកិច្ចឲ្យក្រុមការងារ បច្ចេកទេសអន្តរក្រសួងប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម (ក.ប.ស.ហ) ពិភាក្សា និង ប្រមូលព័ត៌មានឲ្យបានស៊ីជម្រៅ។ លើសពីនេះ សមាជិកក្រុមការងារបានឆ្លើយតបនឹងកម្រងសំណួរផ្អែក លើបទពិសោធន៍ជាក់ស្តែង។ ជាមួយគ្នានេះដែរ យុទ្ធសាស្ត្រជាតិ ឆ្នាំ២០១៩-២០២៣ នេះបានប្រើប្រាស់ ឯកសារជាច្រើនផ្សេងទៀតធ្វើជាមូលដ្ឋាន ដូចជា របាយការណ៍អញ្ញមញ្ញ ឆ្នាំ២០១៧ របាយការណ៍វាយតម្លៃ ហានិភ័យថ្នាក់ជាតិ យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ឆ្នាំ២០១៦-២០២៥ និងរបាយការណ៍និងការសិក្សា ផ្សេងទៀតរៀបចំដោយអង្គការអន្តរជាតិនានា។

ការរៀបចំកម្រងសំណួរធ្វើឡើង ដោយផ្អែកលើគោលបំណងជាយុទ្ធសាស្ត្រជាតិរបស់យុទ្ធសាស្ត្រ ឆ្នាំ២០១៩-២០២៣ នេះ រួមមាន៖

១- ការយល់ដឹង និងការគ្រប់គ្រងហានិភ័យ

២- ការផ្តល់អាជ្ញាប័ណ្ណនិងការត្រួតពិនិត្យគ្រឹះស្ថានហិរញ្ញវត្ថុ និងមុខរបរនិងវិជ្ជាជីវៈមិនមែន ហិរញ្ញវត្ថុ និងការអនុវត្តវិធានការទប់ស្កាត់

៣- ការពង្រឹងតម្លាភាពស្ថាប័ន

៤- ការប្រមូល ការវិភាគ និងការបញ្ជូនរបាយការណ៍ស៊ើបការណ៍ហិរញ្ញវត្ថុដែលមានគុណភាព

៥- ការស៊ើបអង្កេតនូវសំអាងនៃបទល្មើស និងបទសម្អាតប្រាក់ប្រកបដោយប្រសិទ្ធភាព

៦- ការកាត់ទោសសំអាងបទល្មើស និងបទសម្អាតប្រាក់ប្រកបដោយប្រសិទ្ធភាព

៧- ការរឹបអូសផលនៃសំអាងបទល្មើស និងបទសម្អាតប្រាក់ប្រកបដោយប្រសិទ្ធភាព

៨- កិច្ចសហប្រតិបត្តិការអន្តរជាតិប្រកបដោយប្រសិទ្ធភាព

៩- ការស្វែងរក និងការលុបបំបាត់ហិរញ្ញប្បទានភេរវកម្មនិងហិរញ្ញប្បទាននៃការរីកសាយភាយអាវុធមហាប្រល័យ និង

១០- ការគ្រប់គ្រងកម្មវិធីជាតិស្តីពីការប្រឆាំង ស.ប.ហ.ភ ។

ក.ប.ស.ហ បានជួបប្រជុំពិភាក្សាពីបញ្ហាប្រឈមចម្បងៗ ដែលអាជ្ញាធរអាចជួបប្រទះនៅពេលអនុវត្តភារកិច្ច ដើម្បីសម្រេចគោលបំណងជាយុទ្ធសាស្ត្រទាំងនេះ។ ការពិភាក្សាធ្វើឡើងក្នុងទម្រង់ជាក្រុមតូចៗ និងបន្ទាប់មកធ្វើឡើងជារួម។ ក្រសួង-ស្ថាប័នទាំងអស់បានរកឃើញបញ្ហាប្រឈមចម្បងៗ ដូចជាធនធាននៅមានកម្រិត (ទាំងធនធានមនុស្សនិងហិរញ្ញវត្ថុ) និងកង្វះសមត្ថភាព។ ក្រសួង-ស្ថាប័នជាច្រើនបានលើកពីបញ្ហាមួយចំនួនពាក់ព័ន្ធនឹងកិច្ចសហប្រតិបត្តិការទាំងក្នុងនិងក្រៅស្រុក និងការទទួលបានព័ត៌មាន។ យុទ្ធសាស្ត្រជាតិ ឆ្នាំ២០១៩-២០២៣ នេះរាប់បញ្ចូលបញ្ហាទាំងនេះ។

# និដ្ឋភាពទូទៅនៃគោលដៅ និងគោលបំណង

យុទ្ធសាស្ត្រជាតិ ឆ្នាំ២០១៩-២០២៣ ជាឯកសារមគ្គុទ្ទេសក៍ដ៏ពេញលេញមួយសម្រាប់ការប្រឆាំង ស.ប.ហ.ភ នៅប្រទេសកម្ពុជាឲ្យប្រកបដោយប្រសិទ្ធភាព។ យុទ្ធសាស្ត្រនិងគោលបំណងចម្បងបំផុត ដែលមានក្នុងយុទ្ធសាស្ត្រជាតិ ឆ្នាំ២០១៩-២០២៣ នេះ គឺរៀបចំឡើង ដើម្បីឲ្យគ្រឹះស្ថានហិរញ្ញវត្ថុ និងមុខរបរនិងវិជ្ជាជីវៈមិនមែនហិរញ្ញវត្ថុ គេចផុតពីការប្រើប្រាស់ ដើម្បីសម្អាតផលនៃបទល្មើស និងស្វែងរកផលនៃបទល្មើសនិងទ្រព្យសម្បត្តិពាក់ព័ន្ធនឹងហិរញ្ញប្បទានភេរវកម្ម ព្រមទាំងធានាឲ្យអាជ្ញាធរអនុវត្តច្បាប់រួមគ្នាធ្វើការស៊ើបអង្កេត ចោទប្រកាន់ ដាក់ទណ្ឌកម្ម និងរឹបអូសផលនិងឧបករណ៍នៃសំអាងនៃបទល្មើស និងបទសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ប្រកបដោយប្រសិទ្ធភាព។

យុទ្ធសាស្ត្រជាតិនេះមានគោលបំណងគន្លឹះជាយុទ្ធសាស្ត្រចំនួន ១០ ដូចខាងក្រោម៖

១- ការយល់ដឹង និងការគ្រប់គ្រងហានិភ័យ

២- ការផ្តល់អាជ្ញាប័ណ្ណនិងការត្រួតពិនិត្យគ្រឹះស្ថានហិរញ្ញវត្ថុ និងមុខរបរនិងវិជ្ជាជីវៈមិនមែនហិរញ្ញវត្ថុ និងការអនុវត្តវិធានការទប់ស្កាត់

៣- ការពង្រឹងតម្លាភាពស្ថាប័ន

៤- ការប្រមូល ការវិភាគ និងការបញ្ជូនរបាយការណ៍ស៊ើបការណ៍ហិរញ្ញវត្ថុដែលមានគុណភាព

៥- ការស៊ើបអង្កេតនូវសំអាងបទល្មើស និងបទសម្អាតប្រាក់ប្រកបដោយប្រសិទ្ធភាព

៦- ការកាត់ទោសសំអាងបទល្មើស និងបទសម្អាតប្រាក់ប្រកបដោយប្រសិទ្ធភាព

៧- ការរឹបអូសផលនៃសំអាងបទល្មើសនិងបទសម្អាតប្រាក់ប្រកបដោយប្រសិទ្ធភាព

៨- កិច្ចសហប្រតិបត្តិការអន្តរជាតិប្រកបដោយប្រសិទ្ធភាព

៩- ការស្វែងរក និងការលុបបំបាត់ចោលហិរញ្ញប្បទានភេរវកម្មនិងហិរញ្ញប្បទាននៃការរីកសាយភាយអាវុធមហាប្រល័យ និង

១០- ការគ្រប់គ្រងកម្មវិធីជាតិស្តីពីការប្រឆាំង ស.ប.ហ.ភ ។

រាជរដ្ឋាភិបាលបានកំណត់គោលបំណងទាំងនេះ ដើម្បីការពារប្រទេសកម្ពុជាកុំឲ្យទទួលរងគ្រោះខូចខាតដោយសារឧក្រិដ្ឋជនប្រព្រឹត្តបទល្មើស ដើម្បីកេងយកប្រាក់ចំណេញ។ រាជរដ្ឋាភិបាលក៏បានកំណត់គោលបំណងទាំងនេះ ដើម្បីអនុវត្តតាមកាតព្វកិច្ចអន្តរជាតិ ដែលមានក្នុងសន្ធិសញ្ញាអន្តរជាតិនានា និងអនុសាសន៍ទាំង ៤០ របស់ FATF។ មូលហេតុនៃការកំណត់គោលបំណងជាគន្លឹះខាងលើ និងសមាសធាតុសំខាន់ៗនៃគោលបំណងទាំងនេះនឹងលម្អិតក្នុងជំពូកទាំង ១០ ខាងក្រោម។ សកម្មភាពជាអាទិភាព ដើម្បីសម្រេចបានគោលបំណងជាយុទ្ធសាស្ត្រនឹងត្រូវកំណត់នៅក្នុងផែនការសកម្មភាព។

ការរៀបចំយុទ្ធសាស្ត្រជាតិ ឆ្នាំ២០១៩-២០២៣ និងផែនការសកម្មភាពនេះធ្វើឡើងដោយទទួលស្គាល់ថា ដើម្បីសម្រេចបាននូវគ្រប់គោលបំណងជាយុទ្ធសាស្ត្រគឺត្រូវការពេលវេលា ហើយសកម្មភាពនីមួយៗមានកម្រិតអាទិភាព និងភាពបន្ទាន់ខុសៗគ្នា។

ហានិភ័យនៃ ស.ប.ហ.ភ ដែលបានរកឃើញ នៅក្នុងរបាយការណ៍វាយតម្លៃហានិភ័យថ្នាក់ជាតិ គឺជាកត្តាកំណត់អាទិភាព និងពេលវេលាអនុវត្តនៃសកម្មភាពនីមួយៗ ដែលកំណត់នៅក្នុងយុទ្ធសាស្ត្រជាតិ ឆ្នាំ២០១៩-២០២៣ នេះ។

# គោលបំណងគន្លឹះជាយុទ្ធសាស្ត្រជាតិ

## ១. ការយល់ដឹង និងការកាត់បន្ថយហានិភ័យសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម

➢ ការគំរាមកំហែងនៃការសម្អាតប្រាក់ ដែលមានក្នុងរបាយការណ៍វាយតម្លៃហានិភ័យថ្នាក់ជាតិ

នៅឆ្នាំ២០១៦ ប្រទេសកម្ពុជាបានរៀបចំរបាយការណ៍វាយតម្លៃហានិភ័យថ្នាក់ជាតិលើកទី១។ ក្រុមការងារអន្តរក្រសួងមួយបានសហការរៀបចំរបាយការណ៍នេះ ដោយប្រើប្រាស់វិធីសាស្ត្ររបស់ធនាគារពិភពលោក។ ក្រុមការងារនេះបានប្រមូលព័ត៌មានពីច្រើនប្រភព ទាំងព័ត៌មានរបស់រដ្ឋាភិបាល និងវិស័យឯកជន ដោយបញ្ចូលទិន្នន័យស្ថិតិដែលមានស្រាប់ និងការយល់ឃើញរបស់មន្ត្រីដែលមានបទពិសោធន៍ច្រើនឆ្នាំ ក្នុងការងារប្រឆាំង ស.ប.ហ.ភ និងការងារផ្តល់សេវាហិរញ្ញវត្ថុនានា។

របាយការណ៍វាយតម្លៃហានិភ័យថ្នាក់ជាតិ បានចាត់ថ្នាក់ហានិភ័យសម្អាតប្រាក់នៅប្រទេសកម្ពុជាមានកម្រិត *មធ្យមខ្ពស់*។ កត្តាដែលមានទម្ងន់ធ្វើឲ្យហានិភ័យសម្អាតប្រាក់កើនខ្ពស់ រួមមាន៖ សេដ្ឋកិច្ចដុល្លារូបនីយកម្ម និងប្រើប្រាស់សាច់ប្រាក់សុទ្ធច្រើន ការប្រើប្រាស់សេវាហិរញ្ញវត្ថុក្រៅផ្លូវការច្រើន ការរីកចម្រើនខ្លាំងនៃវិស័យអចលនទ្រព្យ និងវិស័យល្បែងស៊ីសងតាមកាស៊ីណូដែលមានទំហំធំ។

យោងតាមរបាយការណ៍វាយតម្លៃហានិភ័យថ្នាក់ជាតិ បទល្មើសដែលបង្កើតឲ្យមានផលនៃបទល្មើសច្រើនជាងគេ រួមមាន៖

- បទល្មើសបោកបញ្ឆោតនិងបន្លំលួច ដែលបង្កដោយជនល្មើសទាំងក្នុង និងក្រៅស្រុក
- បទល្មើសពុករលួយ និងស៊ីសំណូកសូកប៉ាន់
- បទល្មើសព្រៃឈើ និងសត្វព្រៃ
- បទល្មើសជួញដូរមនុស្ស
- បទល្មើសជួញដូរគ្រឿងញៀនណាកូទិក និងសារធាតុញៀន
- បទល្មើសរត់ពន្ធទំនិញ និងសាច់ប្រាក់ឆ្លងដែន

បទល្មើសបោកបញ្ឆោតនិងបន្លំលួច និងបទល្មើសពុករលួយ មានការគំរាមកំហែងនៃការសម្អាតប្រាក់ខ្ពស់ជាងគេ គឺមានកម្រិតហានិភ័យ*ខ្ពស់* និង*មធ្យមខ្ពស់* រៀងគ្នា។

របាយការណ៍វាយតម្លៃហានិភ័យថ្នាក់ជាតិបានកំណត់វិស័យ ដែលមានភាពងាយរងគ្រោះខ្លាំងជាងគេ រួមមាន៖

- វិស័យធនាគារ
- វិស័យផ្ទេរប្រាក់
- វិស័យកាស៊ីណូ និង
- វិស័យអចលនទ្រព្យ។

របាយការណ៍វាយតម្លៃហានិភ័យថ្នាក់ជាតិបានកំណត់វិស័យខាងលើនេះថា មានការគំរាមកំហែងនៃការសម្អាតប្រាក់នៅកម្រិត *មធ្យមខ្ពស់*។

ក.ប.ស.ហ បានពិនិត្យលទ្ធផលអំពីការគំរាមកំហែង និងភាពងាយរងគ្រោះនៃការសម្អាតប្រាក់យ៉ាងយកចិត្តទុកដាក់ និងបានយកលទ្ធផលនេះបញ្ចូលទៅក្នុងគោលបំណងគន្លឹះជាយុទ្ធសាស្ត្រទាំងដប់ក្នុងយុទ្ធសាស្ត្រជាតិ ឆ្នាំ២០១៩-២០២៣។

ធាតុមួយចំនួននៃយុទ្ធសាស្ត្រជាតិ ឆ្នាំ២០១៩-២០២៣ ដែលពាក់ព័ន្ធដល់ការគ្រប់គ្រងសំអាងនៃបទល្មើស ដែលមានហានិភ័យខ្ពស់ ឬការត្រួតពិនិត្យលើអនុវិស័យដែលងាយរងគ្រោះបំផុត នៅក្នុងវិស័យហិរញ្ញវត្ថុត្រូវបានកំណត់អាទិភាពខ្ពស់ជាងគេ និងត្រូវបង្កើនថវិកានិងធនធានមនុស្សឲ្យបានច្រើនជាងគេផងដែរ សម្រាប់អនុវត្តធាតុទាំងនេះ។ ទន្ទឹមនេះ អាជ្ញាធរត្រូវវាយតម្លៃហានិភ័យឲ្យបានកាន់តែលម្អិតទៀត ចំពោះវិស័យដែលមានហានិភ័យខ្ពស់ ដើម្បីបង្កើនការយល់ដឹងអំពីហានិភ័យសម្អាតប្រាក់នៃវិស័យទាំងនេះថែមទៀត និងដាក់ចេញវិធានការកាត់បន្ថយហានិភ័យឲ្យមានប្រសិទ្ធភាពបំផុត។

➢ ការគំរាមកំហែងនៃហិរញ្ញប្បទានភេរវកម្ម ដែលមានក្នុងរបាយការណ៍វាយតម្លៃហានិភ័យថ្នាក់ជាតិ

ផ្អែកតាមរបាយការណ៍វាយតម្លៃហានិភ័យថ្នាក់ជាតិ ហានិភ័យហិរញ្ញប្បទានភេរវកម្មនៅប្រទេសកម្ពុជាមានកម្រិត *មធ្យមទាប*។ ប្រទេសកម្ពុជាពុំធ្លាប់មានករណីភេរវកម្ម ឬហិរញ្ញប្បទានភេរវកម្មទេ ហើយគ្រឹះស្ថានហិរញ្ញវត្ថុក៏ពុំបានរកឃើញមូលនិធិរបស់ភេរវករ ឬអង្គការភេរវកម្ម ដែលក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិបានកំណត់ដែរ។

ប្រទេសកម្ពុជាមានវិធានការប្រឆាំងភេរវកម្ម និងហិរញ្ញប្បទានភេរវកម្មរួចជាស្រេច ហើយកម្មវត្ថុចម្បងគឺត្រូវរក្សាការអនុវត្តវិធានការទាំងនេះ និងបន្តការប្រុងប្រយ័ត្ន ដើម្បីធានាឲ្យបានថានៅប្រទេសកម្ពុជា ពុំមានគ្រឹះស្ថានហិរញ្ញវត្ថុ ឬអង្គការមិនស្វែងរកប្រាក់ចំណេញត្រូវបានប្រើប្រាស់ក្នុងគោលបំណងផ្តល់ហិរញ្ញប្បទានភេរវកម្មទេ។

### ១.១ ការកាត់បន្ថយហានិភ័យសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្មតាមវិស័យ និងស្ថាប័ន

របាយការណ៍វាយតម្លៃហានិភ័យថ្នាក់ជាតិមានសារៈប្រយោជន៍ ដោយសាររបាយការណ៍នេះជាឧបករណ៍សម្រាប់បង្កើនការយល់ដឹងអំពីហានិភ័យ ស.ប.ហ.ភ និងសម្រាប់ចាត់វិធានការអនុវត្តច្បាប់និងគ្រប់គ្រងឲ្យកាន់តែប្រសើរឡើងនាពេលអនាគត តាមរយៈការរៀបចំគោលនយោបាយ និងយុទ្ធសាស្ត្រនានា ដូចជាយុទ្ធសាស្ត្រជាតិ ឆ្នាំ២០១៩-២០២៣ ជាដើម។

ទោះជាយ៉ាងណា សារៈប្រយោជន៍នៃរបាយការណ៍វាយតម្លៃហានិភ័យថ្នាក់ជាតិនឹងថយចុះតាមពេលវេលា ដោយសាររបាយការណ៍នេះនឹងលែងឆ្លុះបញ្ចាំងបានត្រឹមត្រូវពីការគំរាមកំហែង ភាពងាយរងគ្រោះ

និងផលវិបាកនៃ ស.ប.ហ.ភ នៅក្នុងសង្គម និងស្ថាប័ននានា។ ដូច្នេះ អាជ្ញាធរចាំបាច់ត្រូវរៀបចំផែនការវាយតម្លៃហានិភ័យថ្នាក់ជាតិជាថ្មី យ៉ាងហោចណាស់ឲ្យបានមួយឆ្នាំ មុនពេលផុតកំណត់សុពលភាពនៃយុទ្ធសាស្ត្រជាតិឆ្នាំ២០១៩-២០២៣ នេះ។

បន្ថែមលើនេះ ការគំរាមកំហែងពី ស.ប.ហ.ភ តែងតែមានការផ្លាស់ប្តូរជានិច្ច និងទាមទារឲ្យមានការដោះស្រាយ។ ដូច្នេះ គ.ស.ហ គួរតាមដានការវិវត្តនៃការគំរាមកំហែងពី ស.ប.ហ.ភ នេះ និងឆ្លើយតប តាមរយៈការវាយតម្លៃហានិភ័យ ស.ប.ហ.ភ ដោយផ្តោតលើវិស័យដែលងាយរងគ្រោះលើប្រភេទសេវាហិរញ្ញវត្ថុ ឬលើការគំរាមកំហែងពីសំអាងបទល្មើសថ្មីៗ។

វិស័យដែលត្រូវវាយតម្លៃឲ្យបានម៉ត់ចត់អំពីការគំរាមកំហែងពី ស.ប.ហ.ភ មានដូចខាងក្រោម៖

**១.១.១ កំណត់ហានិភ័យតាមវិស័យមួយចំនួន**

**១.១.១.១ វិស័យអង្គការមិនស្វែងរកប្រាក់ចំណេញ**

ការវាយតម្លៃហានិភ័យថ្នាក់ជាតិឆ្នាំ២០១៦ មិនទាន់បានបញ្ចូលអង្គការមិនស្វែងរកប្រាក់ចំណេញនៅឡើយទេ។ អាជ្ញាធរត្រូវវាយតម្លៃការគំរាមកំហែង និងភាពងាយរងគ្រោះនៃ ស.ប.ហ.ភ និងកំណត់យន្តការនិងទម្រង់សមស្របនៃការគ្រប់គ្រងការប្រឆាំង ស.ប.ហ.ភ ប្រកបដោយប្រសិទ្ធភាព នៅផ្នែកនានានៃវិស័យ NPOs នេះ។

**១.១.១.២ ឈ្មួញជួញដូរលោហធាតុ និងត្បូងថ្មមានតម្លៃ**

ការអនុញ្ញាតឲ្យឈ្មួញជួញដូរលោហធាតុនិងត្បូងថ្មមានតម្លៃ អាចជួញដូរ និងផ្ទេរទ្រព្យសកម្មបានអាចជាការគំរាមកំហែងនៃ ស.ប.ហ.ភ ដែលប្រទេសកម្ពុជាពុំទាន់បានធ្វើការវាយតម្លៃនៅឡើយទេ។ អាជ្ញាធរត្រូវវាយតម្លៃពីកម្រិតហានិភ័យនៃ ស.ប.ហ.ភ និងកំណត់វិធានការគ្រប់គ្រងហានិភ័យ ដោយសារពុំទាន់មានការត្រួតពិនិត្យលើឈ្មួញជួញដូរលោហធាតុនិងត្បូងថ្មមានតម្លៃ។

**១.១.១.៣ វិស័យអចលនទ្រព្យ**

តាមរយៈរបាយការណ៍វាយតម្លៃហានិភ័យថ្នាក់ជាតិ វិស័យអចលនទ្រព្យមានហានិភ័យសម្អាតប្រាក់កម្រិត *មធ្យមខ្ពស់*។ អាជ្ញាធរត្រូវវាយតម្លៃហានិភ័យសម្អាតប្រាក់នៃវិស័យនេះ ដើម្បីកំណត់ពីភាពងាយរងគ្រោះ និងរៀបចំយន្តការត្រួតពិនិត្យនិងបញ្ញត្តិកម្ម ដើម្បីគ្រប់គ្រងនិងកាត់បន្ថយហានិភ័យទាំងនេះឲ្យមានប្រសិទ្ធភាពខ្ពស់។

**១.១.១.៤ វិស័យកាស៊ីណូ**

តាមរយៈរបាយការណ៍វាយតម្លៃហានិភ័យថ្នាក់ជាតិ វិស័យកាស៊ីណូមានហានិភ័យសម្អាតប្រាក់កម្រិត *មធ្យមខ្ពស់*។ អាជ្ញាធរត្រូវវាយតម្លៃហានិភ័យសម្អាតប្រាក់នៃវិស័យនេះ ដើម្បីកំណត់ពីភាពងាយ

រងគ្រោះ និងរៀបចំយន្តការត្រួតពិនិត្យនិងបញ្ញត្តិកម្ម ដើម្បីគ្រប់គ្រង និងកាត់បន្ថយហានិភ័យទាំងនេះឲ្យមានប្រសិទ្ធភាពខ្ពស់។

#### ១.១.២ ពង្រឹងការយល់ដឹងអំពីហានិភ័យរបស់នីតិបុគ្គល និងកិច្ចសម្របសម្រួលផ្នែកច្បាប់

ប្រទេសកម្ពុជាមិនទាន់បានវាយតម្លៃហានិភ័យ ស.ប.ហ.ភ ចំពោះនីតិបុគ្គលនិងកិច្ចសម្របសម្រួលផ្នែកច្បាប់ដែលអាចបង្កើតឡើង ឬគ្រប់គ្រងនៅប្រទេសកម្ពុជា។ ដូច្នេះ អាជ្ញាធរត្រូវសិក្សាពីភាពងាយរងគ្រោះនៃ ស.ប.ហ.ភ តាមរយៈនីតិបុគ្គលនិងកិច្ចសម្របសម្រួលផ្នែកច្បាប់។ ដូចគ្នានេះដែរ អាជ្ញាធរត្រូវវាយតម្លៃហានិភ័យ ស.ប.ហ.ភ តាមរយៈកិច្ចសម្របសម្រួលផ្នែកច្បាប់បរទេស ដែលអាចធ្វើប្រតិបត្តិការនៅប្រទេសកម្ពុជា។ សេចក្តីព្រាងច្បាប់ ស្តីពីបរធនបាលកិច្ចទូទៅអនុញ្ញាតឲ្យមានការបង្កើតបរធនបាលកិច្ចក្នុងស្រុក។ ដូច្នេះ អាជ្ញាធរត្រូវវាយតម្លៃពីហានិភ័យ ស.ប.ហ.ភ នៃការប្រើប្រាស់បរធនបាលកិច្ច ព្រមគ្នាជាមួយនឹងការវាយតម្លៃលើកិច្ចសម្របសម្រួលផ្នែកច្បាប់បរទេស។

#### ១.១.៣ ការបង្កើនការយល់ដឹងពីហានិភ័យ ស.ប.ហ.ភ

អាជ្ញាធរត្រូវផ្តល់ព័ត៌មានពីចរិតលក្ខណៈនៃហានិភ័យ ស.ប.ហ.ភ ដល់បុគ្គលរាយការណ៍ ដើម្បីកែសម្រួលនីតិវិធី និងការត្រួតពិនិត្យផ្ទៃក្នុង សម្រាប់គ្រប់គ្រងហានិភ័យទាំងនេះឲ្យមានប្រសិទ្ធភាព។ អាជ្ញាធរត្រូវចែករំលែករបាយការណ៍វាយតម្លៃហានិភ័យថ្នាក់ជាតិ ឬរបាយការណ៍សង្ខេប និងយុទ្ធសាស្ត្រជាតិ ឆ្នាំ២០១៩-២០២៣ ឲ្យបុគ្គលរាយការណ៍ទាំងអស់ និងសាធារណជន។ អាជ្ញាធរត្រួតពិនិត្យបុគ្គលរាយការណ៍ត្រូវធានាថា បុគ្គលរាយការណ៍បានបញ្ចូលផ្នែកពាក់ព័ន្ធនៃរបាយការណ៍វាយតម្លៃហានិភ័យថ្នាក់ជាតិ និងយុទ្ធសាស្ត្រជាតិ ឆ្នាំ២០១៩-២០២៣ នេះ ទៅក្នុងគោលនយោបាយ និងនីតិវិធីផ្ទៃក្នុងរបស់ពួកគេ។

### ១.២ ការកាត់បន្ថយបទល្មើសហិរញ្ញវត្ថុកើតឡើងពីលំហូរសាច់ប្រាក់ចេញ-ចូលខុសច្បាប់

ការសម្អាតប្រាក់ជាទម្រង់ពាណិជ្ជកម្ម (Trade-Based Money Laundering-TBML) គឺជាមធ្យោបាយសំខាន់មួយ ដែលឧក្រិដ្ឋជននិងអ្នកផ្តល់ហិរញ្ញប្បទានភេរវកម្មអាចប្រើប្រាស់ ដើម្បីរួមបញ្ចូលមូលនិធិបានមកពីប្រភពខុសច្បាប់ចូលទៅក្នុងសេដ្ឋកិច្ចផ្លូវការ។ ប្រទេសកម្ពុជាបាត់បង់ចំណូលពន្ធដារយ៉ាងសន្ធឹកសន្ធាប់ដោយសារលំហូរសាច់ប្រាក់ចេញ-ចូលខុសច្បាប់ និងនៅតែបន្ត ប្រសិនបើបញ្ហានេះមិនបានដោះស្រាយ។ ដូច្នេះ យុទ្ធសាស្ត្រជាតិ ឆ្នាំ២០១៩-២០២៣ បានរំលេចពីតម្រូវការយល់ដឹង និងដោះស្រាយបញ្ហានេះ។

#### ១.២.១ ការយល់ដឹងពីហានិភ័យទាក់ទងនឹងការសម្អាតប្រាក់ជាទម្រង់ពាណិជ្ជកម្ម

របាយការណ៍វាយតម្លៃអញ្ញមញ្ញឆ្នាំ២០១៦ បានកត់សម្គាល់ថា ការវាយតម្លៃហានិភ័យថ្នាក់ជាតិមិនបានគ្របដណ្តប់លើការវាយតម្លៃពីការគំរាមកំហែងពី ស.ប.ហ.ភ ជាទម្រង់ពាណិជ្ជកម្ម។ គ្រប់ភាគីពាក់ព័ន្ធត្រូវយល់ដឹងពីហានិភ័យ ស.ប.ហ.ភ ជាពិសេសពាក់ព័ន្ធនឹងការសម្អាតប្រាក់ជាទម្រង់ពាណិជ្ជកម្មជាមុនសិន ទើបអាចទទួលជោគជ័យក្នុងការប្រឈមនឹងការគំរាមកំហែងពី ស.ប.ហ.ភ ជាទម្រង់ពាណិជ្ជកម្ម។

ដូច្នេះ ការវាយតម្លៃហានិភ័យថ្នាក់ជាតិលើកក្រោយ អាជ្ញាធរពាក់ព័ន្ធត្រូវបញ្ចូលការវាយតម្លៃពីហានិភ័យ ស.ប.ហ.ភ ពាក់ព័ន្ធនឹងការសម្អាតប្រាក់ជាទម្រង់ពាណិជ្ជកម្ម។

**១.២.២ ពង្រឹងការយល់ដឹងអំពីហានិភ័យនៃការរត់ពន្ធសាច់ប្រាក់**

សាច់ប្រាក់នៅតែជាជម្រើសទីមួយរបស់ឧក្រិដ្ឋជនក្នុងការសម្រួលដល់ការសម្អាតប្រាក់។ ប្រទេសកម្ពុជាមានទន្លេមេគង្គ ដែលហូរកាត់ប្រទេសចិន ឡាវ មីយ៉ាន់ម៉ា ថៃ និងវៀតណាម ក្នុងប្រវែង ៤.៣៥០ គីឡូម៉ែត្រ ព្រមទាំងមានព្រំដែនគោកជាមួយប្រទេសឡាវ ថៃ និងវៀតណាម។ តាមបណ្តោយព្រំប្រទល់ទាំងនេះជាឱកាសដល់ក្រុមឧក្រិដ្ឋកម្មឆ្លងដែនមានការចាត់តាំង ក្នុងការរត់ពន្ធសាច់ប្រាក់ដែលជាផលនៃបទល្មើស។ ប្រទេសកម្ពុជាបាននិងកំពុងពង្រឹងការត្រួតពិនិត្យការឆ្លងកាត់ព្រំដែន ដើម្បីប្រឆាំងការរត់ពន្ធសាច់ប្រាក់។ តាមរយៈរបាយការណ៍វាយតម្លៃហានិភ័យថ្នាក់ជាតិ ការដឹកជញ្ជូនសាច់ប្រាក់ឆ្លងដែនខុសច្បាប់មានហានិភ័យកម្រិត *ទាប* ដូច្នេះ អាជ្ញាធរពាក់ព័ន្ធត្រូវបន្តសិក្សាពីហានិភ័យនេះ ពេលវាយតម្លៃហានិភ័យថ្នាក់ជាតិលើកក្រោយទៀត។

## ២. វិធានការទប់ស្កាត់ និងការត្រួតពិនិត្យបុគ្គលរាយការណ៍

គោលបំណងជាយុទ្ធសាស្ត្រកម្រិតខ្ពស់របស់អាជ្ញាធរត្រួតពិនិត្យលើបុគ្គលរាយការណ៍ និងការអនុវត្តវិធានការណ៍ទប់ស្កាត់របស់បុគ្គលរាយការណ៍ត្រូវបានគាំទ្រដោយសសរស្តម្ភចំនួន៣ ដូចខាងក្រោម៖

សសរស្តម្ភទី១ ៖ អាជ្ញាធរត្រួតពិនិត្យត្រូវគ្រប់គ្រងការផ្តល់អាជ្ញាប័ណ្ណ ការចុះបញ្ជី ឬការត្រួតពិនិត្យផ្សេងៗឲ្យបានសមស្រប ដើម្បីទប់ស្កាត់ក្រុមឧក្រិដ្ឋជន និងសមាគតរបស់ពួកគេមិនឲ្យកាន់កាប់ ឬគ្រប់គ្រងផលប្រយោជន៍សំខាន់ៗ ឬកាន់កាប់តួនាទីជាគណៈគ្រប់គ្រងនៅក្នុងបុគ្គលរាយការណ៍។

សសរស្តម្ភទី២ ៖ ស.ហ.ក និងអ្នកត្រួតពិនិត្យបទប្បញ្ញត្តិប្រុងប្រយ័ត្ន ត្រូវត្រួតពិនិត្យបុគ្គលរាយការណ៍ឲ្យបានសមស្រប។ អ្នកត្រួតពិនិត្យត្រូវកំណត់អត្តសញ្ញាណ និងស្វែងយល់អំពីហានិភ័យ ស.ប.ហ.ភ ចំពោះវិស័យដែលពួកគេត្រួតពិនិត្យ ដោយប្រើប្រាស់វិធីសាស្ត្រផ្អែកលើហានិភ័យ ដើម្បីតាមដាននិងត្រួតពិនិត្យបុគ្គលរាយការណ៍អំពីការគ្រប់គ្រង និងកាត់បន្ថយការគំរាមកំហែង ស.ប.ហ.ភ។ ក្នុងករណីរកឃើញការមិនប្រតិបត្តិតាមរបស់បុគ្គលរាយការណ៍ អ្នកត្រួតពិនិត្យត្រូវចាត់វិធានការកែតម្រូវ និងដាក់ទណ្ឌកម្មឲ្យមានប្រសិទ្ធភាព។

សសរស្តម្ភទី៣ ៖ បុគ្គលរាយការណ៍ត្រូវស្វែងយល់អំពីកាតព្វកិច្ចប្រឆាំង ស.ប.ហ.ភ និងហានិភ័យ ស.ប.ហ.ភ និងបង្កើតគោលនយោបាយ និងនីតិវិធីផ្អែកលើហានិភ័យឲ្យបានសមស្រប ដើម្បីគ្រប់គ្រង និងកាត់បន្ថយហានិភ័យទាំងនេះ។ បុគ្គលរាយការណ៍ត្រូវអនុវត្តវិធានការយកចិត្តទុកដាក់បន្ថែម ចំពោះបុគ្គលពាក់ព័ន្ធនយោបាយ បច្ចេកវិទ្យាថ្មី ការផ្ទេរប្រាក់តាមអេឡិចត្រូនិក ការដាក់ទណ្ឌកម្មហិរញ្ញវត្ថុតាមគោលដៅទាក់ទងនឹងហិរញ្ញប្បទានភេរវកម្ម និងប្រទេសដែលមានហានិភ័យខ្ពស់ អតិថិជន ឬផលិតផលកំណត់ដោយ គ.ស.ហ ឬ ស.ហ.ក ឬអាជ្ញាធរត្រួតពិនិត្យផ្សេងៗ ឬប្រព័ន្ធគ្រប់គ្រងហានិភ័យរបស់បុគ្គលរាយការណ៍។ បុគ្គលរាយការណ៍ក៏ត្រូវបង្កើតប្រព័ន្ធ និងនីតិវិធី ដើម្បីអនុវត្តកាតព្វកិច្ចរាយការណ៍របស់ខ្លួន ដូចមានចែងនៅក្នុងច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម។

យុទ្ធសាស្ត្រជាតិឆ្នាំ២០១៣-២០១៧ មានគោលបំណងអភិវឌ្ឍរបបត្រួតពិនិត្យការប្រឆាំង ស.ប.ហ.ភ តាមរយៈការកំណត់អត្តសញ្ញាណបុគ្គលរាយការណ៍ពាក់ព័ន្ធទាំងអស់ ការកំណត់អំពីតួនាទីរបស់បញ្ញត្តិករពាក់ព័ន្ធក្នុងការត្រួតពិនិត្យការប្រឆាំង ស.ប.ហ.ភ និងការប្រើប្រាស់ម៉ូដែលត្រួតពិនិត្យដ៏សមស្របមួយ។ អាជ្ញាធរនិងបុគ្គលរាយការណ៍ត្រូវបន្តអភិវឌ្ឍប្រព័ន្ធត្រួតពិនិត្យ តាមរយៈការជំរុញការកាត់បន្ថយចំណុចខ្វះខាតនៅក្នុងក្របខ័ណ្ឌបទប្បញ្ញត្តិប្រឆាំង ស.ប.ហ.ភ ការបង្កើនសមត្ថភាពរបស់អ្នកត្រួតពិនិត្យពាក់ព័ន្ធទាំងអស់ និងការលើកកម្ពស់សមត្ថភាពរបស់គ្រឹះស្ថានហិរញ្ញវត្ថុ និងមុខរបរនិងវិជ្ជាជីវៈមិនមែនហិរញ្ញវត្ថុអនុវត្តកាតព្វកិច្ចប្រឆាំង ស.ប.ហ.ភ របស់ពួកគេ ដូចមានចែងក្នុងច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម។

ចាប់តាំងពីបានបង្កើតមក ស.ហ.ក មានភារកិច្ចចម្បងលើការត្រួតពិនិត្យការប្រឆាំង ស.ប.ហ.ភ ដោយសហការជាមួយ គណៈកម្មការមូលបត្រកម្ពុជា (អាជ្ញាធរត្រួតពិនិត្យលើវិស័យមូលបត្រ) ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (អាជ្ញាធរត្រួតពិនិត្យលើវិស័យធានារ៉ាប់រង កាស៊ីណូ និងអចលនទ្រព្យ) និងគណៈមេធាវីកម្ពុជា (អាជ្ញាធរគ្រប់គ្រងលើមេធាវីកម្ពុជា) ជាដើម។ ស.ហ.ក ជាអាជ្ញាធរត្រួតពិនិត្យលើការប្រឆាំង ស.ប.ហ.ភ ចំពោះគ្រឹះស្ថានហិរញ្ញវត្ថុ និងមុខរបរនិងវិជ្ជាជីវៈមិនមែនហិរញ្ញវត្ថុទាំងអស់។

អាជ្ញាធរត្រួតពិនិត្យភាគច្រើន (រួមទាំងអាជ្ញាធរត្រួតពិនិត្យបទប្បញ្ញត្តិប្រុងប្រយ័ត្ន) ទើបតែចាប់ផ្តើមអនុវត្តការងារបានក្នុងរយៈពេលខ្លីប៉ុណ្ណោះ និងកំពុងជួបប្រទះបញ្ហាប្រឈមជាច្រើនក្នុងការអនុវត្តភារកិច្ចរបស់ខ្លួន។ បញ្ហាប្រឈមចម្បង គឺកង្វះខាតធនធានមនុស្សទាំងចំនួនបុគ្គលិក និងសមត្ថភាព។ ដូច្នេះ អាជ្ញាធរត្រួតពិនិត្យត្រូវកំណត់សកម្មភាពបង្កើនធនធានជាសកម្មភាពអាទិភាពមួយ ក្នុងចំណោមសកម្មភាពជាអាទិភាពជាច្រើន។

### ២.១ ការកែលម្អការអនុវត្តវិធានការប្រឆាំងការសម្អាតប្រាក់របស់បុគ្គលរាយការណ៍និងឧស្សាហកម្ម

វិស័យឯកជន ជាដៃគូសំខាន់ក្នុងការប្រឆាំង ស.ប.ហ.ភ។ នៅពេលសេដ្ឋកិច្ចជាតិរីកចម្រើនយ៉ាងឆាប់រហ័ស ប្រទេសកម្ពុជាត្រូវតែទាក់ទាញនូវអាជីវកម្មដែលមានគុណភាពខ្ពស់ និងនិរន្តរភាពដោយឈរលើគោលការណ៍អនុវត្តដែលមានក្នុងបញ្ញត្តិនៅក្នុងច្បាប់។ ដើម្បីសម្រេចបាននូវគោលបំណងនេះ វិស័យឯកជនត្រូវមានឧបករណ៍ចាំបាច់មួយសម្រាប់អនុវត្តកាតព្វកិច្ចរបស់ខ្លួនដូចជា៖ ១/- តាមរយៈការចូលរួមជាមួយវិស័យឯកជនក្នុងការបញ្ជ្រាបការយល់ដឹងអំពីច្បាប់និងបទប្បញ្ញត្តិផ្សេងៗ និងជំរុញឲ្យអនុវត្តប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព និង២/- តាមរយៈការត្រួតពិនិត្យប្រកបដោយប្រសិទ្ធភាពដោយផ្តោតលើវិស័យដែលមានហានិភ័យខ្ពស់។

#### ២.១.១ ការកែលម្អក្របខ័ណ្ឌច្បាប់សម្រាប់វិធានការទប់ស្កាត់ការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម

ទោះបីមានការផ្លាស់ប្តូរយ៉ាងច្រើនលើក្របខ័ណ្ឌច្បាប់ នៅក្នុងរយៈពេលប៉ុន្មានឆ្នាំថ្មីៗនេះក៏ដោយ ក៏ប្រទេសកម្ពុជាចាំបាច់ត្រូវពង្រឹងក្របខ័ណ្ឌច្បាប់បន្ថែមទៀត។ ជាក់ស្តែង ច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម នៅពុំទាន់បានបញ្ចូលការតម្រូវនៃការរាយការណ៍ប្រតិបត្តិការ និងការជំរុញការយកចិត្តទុកដាក់បន្ថែម ស្របតាមអនុសាសន៍ទី១២ នៃស្តង់ដាររបស់ FATF ទេ។ លើសពីនេះ បទប្បញ្ញត្តិប្រឆាំង ស.ប.ហ.ភ ចាំបាច់ត្រូវកែលម្អបន្ថែម ដូចជាការធានាថា កម្រិតកំណត់សម្រាប់ការអនុវត្តការយកចិត្តទុកដាក់ស្គាល់អតិថិជនមិនមានលក្ខណៈធូរស្រាលជាងស្តង់ដាអន្តរជាតិ។ ការកែលម្អនេះនឹងបង្កើនសមត្ថភាពរបស់អាជ្ញាធក្នុងការស្វែងរក ការស៊ើបអង្កេត ការចោទប្រកាន់បទល្មើសហិរញ្ញវត្ថុ ទោះបីបទល្មើសនោះកើតឡើង នៅក្នុងស្រុកនិងក្រៅស្រុកក៏ដោយ។

### ២.១.២ ការបង្កើនការយល់ដឹងលើការប្រឆាំងការសម្អាតប្រាក់លើគ្រប់វិស័យហិរញ្ញវត្ថុ និងមុខរបរនិងវិជ្ជាជីវៈមិនមែនហិរញ្ញវត្ថុ

វិស័យហិរញ្ញវត្ថុកំពុងតែរីកចម្រើនយ៉ាងឆាប់រហ័ស ដែលតម្រូវឲ្យមានការបង្កើនសមត្ថភាពយល់ដឹងឲ្យបានស៊ីជម្រៅអំពីកម្រិតហានិភ័យពាក់ព័ន្ធ ស.ប.ហ.ភ និងទម្រង់ផ្សេងទៀតនៃបទល្មើសហិរញ្ញវត្ថុ។ ទោះជាប្រទេសកម្ពុជាខិតខំប្រឹងប្រែងជំរុញការយល់ដឹងអំពីការប្រឆាំង ស.ប.ហ.ភ និងស្តង់ដារបស់ FATF ក៏ដូចជាការវាយតម្លៃអញ្ញមញ្ញដោយ APG នាពេលថ្មីៗនេះ បានរកឃើញថាការយល់ដឹងអំពីហានិភ័យ ស.ប.ហ.ភ របស់ឈ្មួញជួញដូរលោហធាតុនិងត្បូងថ្មមានតម្លៃ ក្រុមហ៊ុនអចលនទ្រព្យ និងកាស៊ីណូមួយចំនួន នៅមានកម្រិតទាបនៅឡើយ។ លើសពីនេះទៀត ការត្រួតពិនិត្យការប្រឆាំងការសម្អាតប្រាក់នៅតែមានកម្រិតទាបនៅឡើយ ក្នុងវិស័យមុខរបរនិងវិជ្ជាវៈមិនមែនហិរញ្ញវត្ថុ និងគ្រឹះស្ថានហិរញ្ញវត្ថុមួយចំនួន។ ទិដ្ឋភាពសំខាន់មួយនៃយុទ្ធសាស្ត្រជាតិ ឆ្នាំ២០១៩-២០២៣ នេះគឺការលើកកម្ពស់កិច្ចសហការជាមួយវិស័យឯកជន ដើម្បីផ្តល់ការណែនាំស្តីពីការអនុវត្តច្បាប់ និងការកាត់បន្ថយហានិភ័យ។

### ២.២ ការកែលម្អប្រព័ន្ធត្រួតពិនិត្យផ្អែកលើហានិភ័យ

ប្រទេសកម្ពុជាបានបោះជំហានដ៏មានសារៈសំខាន់ក្នុងការបង្កើត និងអភិវឌ្ឍក្របខ័ណ្ឌច្បាប់និងត្រួតពិនិត្យ ដើម្បីប្រឆាំង ស.ប.ហ.ភ ដូចជាការដាក់ឲ្យប្រើប្រាស់ច្បាប់ ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និងច្បាប់ស្តីពីការប្រឆាំងភេរវកម្ម នៅឆ្នាំ២០០៧ និងការបង្កើត ស.ហ.ក នៅឆ្នាំ២០០៨។ វឌ្ឍនភាពបន្ទាប់មកទៀត ប្រទេសកម្ពុជាក៏បានចេញផ្សាយបទប្បញ្ញត្តិប្រឆាំង ស.ប.ហ.ភ ដូចជាប្រកាសស្តីពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ឆ្នាំ២០០៨ និងប្រកាសស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម សម្រាប់បុគ្គលរាយការណ៍មិនស្ថិតក្រោមការគ្រប់គ្រងរបស់ធនាគារជាតិនៃកម្ពុជា ឆ្នាំ២០១០។

ប្រទេសកម្ពុជាយល់ដឹងអំពីសារៈសំខាន់នៃការពិនិត្យតាមដាន វិស័យហិរញ្ញវត្ថុនិងវិជ្ជាជីវៈជាអ្នកផ្តល់ការអនុញ្ញាតឬសម្របសម្រួលឲ្យប្រកបមុខរបរ (Gatekeeper)។ ក្នុងនាមជាអ្នកត្រួតពិនិត្យការប្រឆាំង ស.ប.ហ.ភ ស.ហ.ក បន្តបង្កើនសមត្ថភាពរបស់ខ្លួន រួមមានការបង្កើតឲ្យមានឧបករណ៍ត្រួតពិនិត្យថ្មីៗ និងការជំរុញការទំនាក់ទំនងជាមួយភ្នាក់ងារផ្សេងៗ និងវិស័យឯកជន។ ប៉ុន្តែ ដោយសារកង្វះខាតធនធាន និងតម្រូវការផ្តល់អាទិភាពចំពោះការត្រួតពិនិត្យ ស.ហ.ក បាននិងកំពុងផ្តោតការយកចិត្តទុកដាក់យ៉ាងខ្លាំងលើការត្រួតពិនិត្យធនាគារ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ។ ការអនុវត្តការត្រួតពិនិត្យចំពោះគ្រឹះស្ថានហិរញ្ញវត្ថុមិនមែនធនាគារ និងមុខរបរនិងវិជ្ជាជីវៈមិនមែនហិរញ្ញវត្ថុនៅមានកម្រិតតិចតួចនៅឡើយ។

### ២.២.១ ធានាការធ្វើតេស្តលើភាពសមស្របនិងត្រឹមត្រូវ ពេលចូលទីផ្សារ

ទោះបីប្រទេសកម្ពុជា មានយន្តការត្រួតពិនិត្យភាពសមស្រប និងត្រឹមត្រូវ ដើម្បីកាត់បន្ថយលទ្ធភាពចូលទីផ្សាររបស់ឧក្រិដ្ឋជននិងសមាគតក៏ដោយ ក៏វិស័យអាជីវកម្មប្តូរប្រាក់ និងវិស័យមានហានិភ័យខ្ពស់ផ្សេងទៀតនៅមានកង្វះខាតវិធានការត្រួតពិនិត្យសមស្រប និងត្រឹមត្រូវបែបនេះនៅឡើយ។ កង្វះខាតនេះបានបន្ថយប្រសិទ្ធភាពនៃប្រព័ន្ធចុះបញ្ជី និងផ្តល់អាជ្ញាប័ណ្ណ ដោយសារហានិភ័យកើតឡើងពីវិស័យទាំងនេះជាពិសេសវិស័យកាស៊ីណូ។ បន្ថែមលើនេះ បទប្បញ្ញត្តិដែលចែងពីវិធានការភាពសមស្របនិងត្រឹមត្រូវ ដែលអ្នកត្រួតពិនិត្យត្រូវអនុវត្តក្នុងពេលផ្តល់អាជ្ញាប័ណ្ណដល់គ្រឹះស្ថានហិរញ្ញវត្ថុ នៅពុំទាន់មានភាពគ្រប់គ្រាន់នៅឡើយ។ អាជ្ញាធរត្រួតពិនិត្យទទួលខុសត្រូវផ្តល់អាជ្ញាប័ណ្ណ និង/ឬចុះបញ្ជីបុគ្គលរាយការណ៍ដូចមានចែងក្នុងច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ត្រូវពិនិត្យឡើងវិញពីការតម្រូវអំពីភាពសមស្រប និងត្រឹមត្រូវដែលមានចែងនៅក្នុងច្បាប់ និងប្រកាសនានា និងត្រូវបំពេញបន្ថែមចំណុចខ្វះចន្លោះ និងចំណុចខ្វះខាតដែលបានរកឃើញ។

### ២.២.២ ការធានាការត្រួតពិនិត្យផ្អែកលើមូលដ្ឋានវេយិទភាពហានិភ័យលើគ្រប់វិស័យ

បច្ចុប្បន្ន ការត្រួតពិនិត្យផ្អែកលើហានិភ័យបានអនុវត្តតែចំពោះវិស័យធនាគារប៉ុណ្ណោះ។ ចាប់តាំងពីឆ្នាំ២០១៥ ការត្រួតពិនិត្យផ្អែកលើហានិភ័យបានអនុវត្តមួយចំនួនចំពោះវិស័យធានារ៉ាប់រង។ គ្រឹះស្ថានហិរញ្ញវត្ថុមិនមែនធនាគារផ្សេងទៀតពុំទាន់ក្លាយជាកម្មវត្ថុនៃការត្រួតពិនិត្យផ្អែកលើហានិភ័យនៅឡើយ។ ដូច្នេះ អាជ្ញាធរត្រួតពិនិត្យទាំងអស់ចាំបាច់ត្រូវបង្កើនការយល់ដឹងអំពីហានិភ័យ ស.ប.ហ.ភ និងចាត់វិធានការទប់ស្កាត់ដោយរួមបញ្ចូលទាំងការរឹតបន្តឹងការផ្តល់អាជ្ញាប័ណ្ណ និងការអនុវត្តការត្រួតពិនិត្យផ្អែកលើហានិភ័យចំពោះវិស័យហិរញ្ញវត្ថុនិងមិនមែនហិរញ្ញវត្ថុពាក់ព័ន្ធនានា។

ការត្រួតពិនិត្យការប្រឆាំង ស.ប.ហ.ភ លើគ្រប់វិស័យហិរញ្ញវត្ថុទាំងអស់នៅមានកម្រិត ដោយសារកង្វះខាតធនធាន។ ស.ហ.ក បានត្រួតពិនិត្យតែលើគ្រឹះស្ថានធនាគារមួយចំនួនប៉ុណ្ណោះ និងនៅពុំទាន់បានអនុវត្តទៅលើវិស័យផ្សេងៗនៅឡើយ។ ទន្ទឹមនេះ ការត្រួតពិនិត្យលើឯកសារនៅមានកម្រិតយ៉ាងខ្លាំង ទោះបី ស.ហ.ក កំពុងអនុវត្តការត្រួតពិនិត្យលើឯកសារចំពោះគ្រឹះស្ថានធនាគារក៏ដោយ។ អាជ្ញាធរនានាបានទទួលស្គាល់ពីសារៈសំខាន់នៃការត្រួតពិនិត្យលើវិស័យហិរញ្ញវត្ថុទាំងមូល ជាពិសេសវិស័យដែលងាយរងគ្រោះពីសកម្មភាព ស.ប.ហ.ភ។ អត្រាកំណើនយ៉ាងឆាប់រហ័សរបស់ប្រទេសកម្ពុជាមានន័យថាការគំរាមកំហែងនៃការសម្អាតប្រាក់ក៏អាចកើនឡើងយ៉ាងឆាប់រហ័សចំពោះវិស័យ ដែលសកម្មផងដែរ។ ដូច្នេះ អាជ្ញាធរពាក់ព័ន្ធត្រូវដាក់ចេញផែនការសកម្មភាព ដើម្បីត្រួតពិនិត្យឲ្យកាន់តែមានប្រសិទ្ធភាពថែមទៀត ចំពោះគ្រប់វិស័យពាក់ព័ន្ធទាំងអស់។

លើសពីនេះ មុខរបរនិងវិជ្ជាជីវៈមិនមែនហិរញ្ញវត្ថុក៏មានសារៈសំខាន់ផងដែរ ក្នុងការចូលរួមប្រឆាំង ស.ប.ហ.ភ។ មុខរបរនិងវិជ្ជាជីវៈមិនមែនហិរញ្ញវត្ថុត្រូវបានចាត់ទុកជាអ្នកផ្តល់ការអនុញ្ញាតឬសម្របសម្រួលឲ្យប្រកបមុខរបរ (Gatekeeper) សម្រាប់វិស័យមួយចំនួន ហើយដើរតួនាទីសំខាន់ក្នុងការកំណត់សកម្មភាពមិនប្រក្រតីមុនចូលទីផ្សារ និងធានាថាមានព័ត៌មានចាំបាច់សម្រាប់ប្រឆាំងបទល្មើសហិរញ្ញវត្ថុ។ អាជ្ញាធរក៏ត្រូវត្រួតពិនិត្យមុខរបរនិងវិជ្ជាជីវៈមិនមែនហិរញ្ញវត្ថុ ដើម្បីធានាថាពួកគេកំពុងបំពេញភារកិច្ចជាអ្នកផ្តល់ការអនុញ្ញាតឬសម្របសម្រួលឲ្យប្រកបមុខរបរ (Gatekeeper) បានពេញលេញ។

### ២.២.៣ ការពង្រឹងសមត្ថភាព និងវិធីសាស្រ្តត្រួតពិនិត្យ

អាជ្ញាធរត្រួតពិនិត្យត្រូវមានបុគ្គលិក និងថវិកាគ្រប់គ្រាន់ ដើម្បីអនុវត្តមុខងារត្រួតពិនិត្យរបស់ខ្លួនឲ្យមានប្រសិទ្ធភាព។ ទោះបីទទួលភារកិច្ចតាមដានគ្រប់វិស័យហិរញ្ញវត្ថុ និងមុខរបរនិងវិជ្ជាជីវៈមិនមែនហិរញ្ញវត្ថុក៏ដោយ នាយកដ្ឋានតាមដានការប្រតិបត្តិ និងសហប្រតិបត្តិការរបស់ ស.ហ.ក មានធនធានមនុស្សនៅមានកម្រិត។ អាជ្ញាធរត្រួតពិនិត្យផ្សេងទៀតក៏មានកង្វះខាតដូចគ្នានេះដែរ។

អាជ្ញាធរត្រួតពិនិត្យក៏បានបង្ហាញពីបញ្ហាប្រឈមក្នុងការជួយដល់វិស័យរបស់ពួកគេ ដើម្បីអនុវត្តឲ្យបានជោគជ័យនូវវិធានការប្រឆាំង ស.ប.ហ.ភ ដូចមានចែងនៅក្នុងច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម។ ចុងក្រោយ ការរាំងស្ទះ និងការពន្យារពេលនៃការចែករំលែកព័ត៌មាន (រួមមាន ការចូលយកព័ត៌មានអំពីលិខិតថ្កោលទោស និងម្ចាស់កម្មសិទ្ធិក្រុមហ៊ុន) ក៏ជាការរាំងស្ទះចំពោះការផ្តល់អាជ្ញាប័ណ្ណ និងការត្រួតពិនិត្យប្រកបដោយប្រសិទ្ធភាពលើគ្រប់វិស័យ និងវិជ្ជាជីវៈពាក់ព័ន្ធទាំងអស់។ យុទ្ធសាស្រ្តជាតិ ឆ្នាំ២០១៩-២០២៣ នេះមានគោលបំណងដោះស្រាយរាល់កង្វះខាត ដែលអ្នកត្រួតពិនិត្យជួបប្រទះក្នុងការបំពេញភារកិច្ចរបស់ពួកគេ តាមរយៈផែនការសកម្មភាពច្បាស់លាស់។

ដើម្បីអនុវត្តការត្រួតពិនិត្យឲ្យមានប្រសិទ្ធភាព បញ្ញត្តិករត្រូវតែបំពាក់ឧបករណ៍គ្រប់គ្រាន់ ដើម្បីជំរុញការអនុវត្តតាមបញ្ញត្តិនានាដែលមានចែងក្នុងច្បាប់និងប្រកាស ស្តីពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម។ ឧបករណ៍ត្រួតពិនិត្យនេះត្រូវមានអំណាចចូលយកព័ត៌មាន និងដាក់ទណ្ឌកម្មរាល់ការមិនប្រតិបត្តិតាម ព្រមទាំងមានប្រព័ន្ធផ្ទៃក្នុង ដើម្បីណែនាំអាជ្ញាធរត្រួតពិនិត្យឲ្យអនុវត្តមុខងារ-ភារកិច្ចរបស់ខ្លួនប្រកបដោយប្រសិទ្ធភាព។

## ៣. ការបង្កើនតម្លាភាពស្ថាប័ន

ការសម្អាតប្រាក់ និងបទល្មើសហិរញ្ញវត្ថុផ្សេងៗអាចប្រព្រឹត្តបានអាស្រ័យលើសមត្ថភាពរបស់ឧក្រិដ្ឋជន ក្នុងការបិទបាំងភាពជាម្ចាស់កម្មសិទ្ធិទ្រព្យសម្បត្តិរបស់ពួកគេ តាមរយៈរចនាសម្ព័ន្ធសហគ្រាសមិនច្បាស់លាស់។ ការរកឲ្យឃើញម្ចាស់កម្មសិទ្ធ អត្ថគាហក: ពិតប្រាកដរបស់សាជីវកម្ម និងកិច្ចសម្របសម្រួលផ្នែកច្បាប់ គឺជាភារកិច្ចដ៏ប្រឈមមុខខ្ពស់បំផុតរបស់មន្ត្រីប្រតិបត្តិ។ គោលបំណងសំខាន់របស់យុទ្ធសាស្ត្រជាតិ ឆ្នាំ២០១៩-២០២៣ នេះ គឺជំរុញឲ្យមាននិងទទួលបានព័ត៌មានពីអត្ថគាហក:។

### ៣.១ បង្កើតក្របខ័ណ្ឌគោលនយោបាយអំពីអត្ថគាហក:

ព័ត៌មានរបស់អត្ថគាហក: ដែលមានសុក្រឹត្យភាព និងគុណភាពខ្ពស់អាចរកបាន លុះត្រាតែអាជ្ញាធរពាក់ព័ន្ធមានការយល់ដឹង និងប្រទាក់ក្រឡាគ្នាច្បាស់លាស់នូវទស្សនទានអំពីអត្ថគាហក:។ ទស្សនទានអំពីអត្ថគាហក:ជាទស្សនទានថ្មី សម្រាប់ភ្នាក់ងារពាក់ព័ន្ធ។ ក្រសួងពាណិជ្ជកម្មដែលរក្សាទុកព័ត៌មានមូលដ្ឋានរបស់អត្ថគាហក: ត្រូវពិចារណាឲ្យបានម៉ត់ចត់ពីមធ្យោបាយនានា ដែលស្ថិតនៅក្នុងក្របខ័ណ្ឌច្បាប់ និងពីមធ្យោបាយនានាដែលក្រសួងពាណិជ្ជកម្មអាចប្រើប្រាស់ព័ត៌មានចុះបញ្ជី ដើម្បីប្រមូលព័ត៌មានរបស់អត្ថគាហក:ផងដែរ។ ការបណ្តុះបណ្តាលពីសញ្ញាណនៃព័ត៌មានរបស់អត្ថគាហក: ក៏ដូចជា ការបណ្តុះបណ្តាលពីមធ្យោបាយនិងវិធីសាស្ត្រត្រូវរៀបចំសម្រាប់គ្រប់បញ្ញត្តិករ និងភ្នាក់ងារពាក់ព័ន្ធពីលទ្ធភាពនៃការប្រមូលព័ត៌មាន និងរក្សាព័ត៌មានអត្ថគាហក:ទាំងនេះ។

បច្ចុប្បន្ននេះ មានតែតម្រូវការកំណត់អត្តសញ្ញាណអតិថិជន ក្រោមនីតិវិធីនៃការប្រឆាំង ស.ប.ហ.ភ តែប៉ុណ្ណោះ ដែលអាចប្រមូលព័ត៌មានរបស់អត្ថគាហក:។ ព័ត៌មានរបស់អត្ថគាហក: មិនបានតម្រូវឲ្យផ្តល់ក្នុងពេលចុះបញ្ជីក្រុមហ៊ុនទេ ឬក្រុមហ៊ុនខ្លួនឯងផ្ទាល់ក៏មិនបានរក្សាទុកព័ត៌មានទាំងនេះដែរ។ ទោះបីជាយ៉ាងនេះ មធ្យោបាយនេះមិនបានផ្តល់លទ្ធផលគ្រប់គ្រាន់ ត្រឹមត្រូវ និងមានបច្ចុប្បន្នភាពពីព័ត៌មានរបស់អត្ថគាហក:ទេ។ ដូច្នេះ ភ្នាក់ងារពាក់ព័ន្ធទាំងអស់ត្រូវពិនិត្យឡើងវិញ និងពិចារណាលើវិធីសាស្ត្រផ្សេងៗទៀតដើម្បីធានាពីភាពគ្រប់គ្រាន់ ត្រឹមត្រូវ និងបច្ចុប្បន្នភាពនៃព័ត៌មានអត្ថគាហក:ទាំងនេះ។

ភ្នាក់ងារពាក់ព័ន្ធទាំងអស់ត្រូវធ្វើការរួមគ្នា ដើម្បីរៀបចំនិងអនុវត្តក្របខ័ណ្ឌគោលនយោបាយឲ្យមានសង្គតិភាពពីព័ត៌មានអត្ថគាហក:ឲ្យបានច្បាស់លាស់។

### ៣.២ បង្កើនគុណភាព និងភាពសម្បូរបែបនៃព័ត៌មានរបស់អត្ថគាហក:

ផ្អែកតាមកាតព្វកិច្ចនៃគ្រប់ក្រុមហ៊ុននិងដៃគូទាំងអស់ ដែលបង្កើតឡើងក្រោមច្បាប់សហគ្រាសពាណិជ្ជកម្ម ត្រូវទំនាក់ទំនងជាមួយភ្នាក់ងារចុះបញ្ជីជាប្រចាំ ហើយព័ត៌មានរបស់អត្ថគាហក:ត្រូវបានប្រមូលស្របតាមកាតព្វកិច្ចការយកចិត្តទុកដាក់ស្គាល់អតិថិជនក្រោមនីតិវិធីប្រឆាំង ស.ប.ហ.ភ។ ប៉ុន្តែ

ការអនុវត្តវិធានការប្រឆាំង ស.ប.ហ.ភ របស់បុគ្គលរាយការណ៍ដែលមិនមែនជាគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ នៅតែជាបញ្ហាប្រឈម។ ដូច្នេះ ការវាយតម្លៃពីគុណភាពនៃព័ត៌មានរបស់អត្ថគាហកៈ តាមរយៈកាតព្វកិច្ចការយកចិត្តទុកដាក់ស្គាល់អតិថិជននៅមិនទាន់បានធ្វើនៅឡើយ។ ដើម្បីធានាឲ្យការប្រមូលព័ត៌មានអត្ថគាហកៈប្រកបដោយប្រសិទ្ធភាព អាជ្ញាធរត្រួតពិនិត្យ ស.ប.ហ.ភ ត្រូវពិនិត្យឲ្យបានទៀងទាត់ថាតើបុគ្គលរាយការណ៍បានកំណត់អត្តសញ្ញាណ អត្ថគាហកៈរបស់អតិថិជនឬទេ។

ច្បាប់អនុញ្ញាតផងដែរពីការចេញផ្សាយមូលបត្រស្ថិតក្នុងទ្រង់ទ្រាយគាហកៈ ហើយមិនបានហាមឃាត់ ការចាត់ចែងនៃការកាន់កាប់ភាគហ៊ុន ឬអភិបាលកិច្ចមានតែនាម។ របាយការណ៍វាយតម្លៃអញ្ញមញ្ញ ឆ្នាំ២០១៧ បានផ្តល់អនុសាសន៍ថា ប្រទេសកម្ពុជាត្រូវហាមឃាត់ ឬបង្កើតយន្តការ ដើម្បីដាក់បញ្ញត្តិកម្មចំពោះ មូលបត្រស្ថិតក្នុងទ្រង់ទ្រាយគាហកៈ និងការកាន់កាប់ភាគហ៊ុន ឬអភិបាលកិច្ចមានតែនាម ដើម្បីធានាថា ភាគហ៊ុនទាំងនេះមិនត្រូវបានប្រើប្រាស់ខុស ក្នុងគោលបំណង ស.ប.ហ.ភ។ ស្របគ្នានេះដែរ អាជ្ញាធរពាក់ព័ន្ធត្រូវវាយតម្លៃឡើងវិញពីភាពគំរាមកំហែងនៃ ស.ប.ហ.ភ ដែលកើតចេញពីមូលបត្រស្ថិតក្នុងទ្រង់ទ្រាយគាហកៈ និងការកាន់កាប់ភាគហ៊ុន ឬអភិបាលកិច្ចមានតែនាម។ អាជ្ញាធរពាក់ព័ន្ធក៏ត្រូវពិចារណាចាត់វិធានការកាត់បន្ថយ ឬគ្រប់គ្រងហានិភ័យរួមមាន ការលុបបំបាត់ ឬការរឹតបន្តឹង ការប្រើប្រាស់មូលបត្រស្ថិតក្នុងទ្រង់ទ្រាយគាហកៈ និងការចាត់ចែងនៃការកាន់កាប់ភាគហ៊ុន ឬអភិបាលកិច្ចមានតែនាម។

## ៤. ការប្រមូល ការវិភាគ និងការបញ្ជូនព័ត៌មានស៊ើបការណ៍ហិរញ្ញវត្ថុដែលមានសារៈប្រយោជន៍

ការប្រមូល ការវិភាគ ការបញ្ជូន និងការប្រើប្រាស់ព័ត៌មានស៊ើបការណ៍ហិរញ្ញវត្ថុ គឺជាផ្នែកសំខាន់មួយនៃការស៊ើបអង្កេត និងការចោទប្រកាន់ ស.ប.ហ.ភ ដែលមានប្រសិទ្ធភាព។ ស.ហ.ក ត្រូវប្រមូល និងបញ្ជូនព័ត៌មានស៊ើបការណ៍ហិរញ្ញវត្ថុ និងព័ត៌មានពាក់ព័ន្ធផ្សេងទៀតទៅឲ្យអាជ្ញាធរអនុវត្តច្បាប់ ដោយស្ម័គ្រចិត្ត (Spontaneous Dissemination) ឬតាមការស្នើសុំ។ ព័ត៌មានដែលបានបញ្ជូនត្រូវបំពេញតាមសំណូមពររបស់អាជ្ញាធរអនុវត្តច្បាប់ និងមានភាពគ្រប់គ្រាន់ដែលអាចឲ្យផ្តួចផ្តើមបើកការស៊ើបអង្កេតការសម្អាតប្រាក់ ឬសំអាងនៃបទល្មើស ឬដំណើរការនៃបណ្តឹងប្រមូលពន្ធមកវិញ ហើយអាចជួយកំណត់អត្តសញ្ញាណ និងតាមដានផលនៃបទល្មើសដែលពាក់ព័ន្ធ ស.ប.ហ.ភ និងសំអាងនៃបទល្មើស។

ការវិភាគព័ត៌មានស៊ើបការណ៍ហិរញ្ញវត្ថុមានគោលបំណងផ្តល់ការយល់ដឹងស៊ីជម្រៅ អំពីនិន្នាការ និងការវិវត្តនៃ ស.ប.ហ.ភ ដែលមានផលប៉ះពាល់ ជាអវិជ្ជមានដល់ប្រទេសកម្ពុជា ហើយអាចប្រើប្រាស់ជាព័ត៌មានសម្រាប់រៀបចំគោលនយោបាយជាតិ ស្តីពីការប្រឆាំង ស.ប.ហ.ភ។

### ៤.១ ការពង្រឹងសមត្ថភាពរបស់អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា

ស.ហ.ក ត្រូវបានបង្កើតឡើងជាអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុ តាមច្បាប់ស្តីពីការប្រឆាំង ស.ប.ហ.ភ ឆ្នាំ២០០៧។ ស.ហ.ក ជាអង្គភាពមួយដែលធ្វើប្រតិបត្តិការដោយឯករាជ្យ មានទីតាំងស្ថិតនៅធនាគារជាតិនៃកម្ពុជា។

ស.ហ.ក គឺជាអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុបែបរដ្ឋបាល ដែលមានភារកិច្ច និងសិទ្ធិអំណាចក្នុងការប្រមូល និងបញ្ជូនព័ត៌មានស៊ើបការណ៍ហិរញ្ញវត្ថុ ដែលជាមុខងារ "ស្នូល" របស់ ស.ហ.ក ស្របតាមច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម។ ការងារបន្ថែមលើមុខងារស្នូលរបស់ខ្លួន ស.ហ.ក មានការទទួលខុសត្រូវដូចតទៅះ

- ត្រួតពិនិត្យការប្រឆាំង ស.ប.ហ.ភ លើបុគ្គលរាយការណ៍
- តំណាងប្រទេសកម្ពុជា ក្នុងកិច្ចប្រជុំអន្តរជាតិពាក់ព័ន្ធការប្រឆាំង ស.ប.ហ.ភ ដូចជា គណៈកម្មាធិការ FATF APG និងក្រុមអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុ Egmont និង
- ចូលរួមចំណែកក្នុងគម្រោងប្រឆាំង ស.ប.ហ.ភ ក្នុងស្រុក និងរៀបចំនិងសម្របសម្រួលការងារមួយចំនួនដូចជាការវាយតម្លៃហានិភ័យថ្នាក់ជាតិ ការវាយតម្លៃអញ្ញមញ្ញរបស់ប្រទេសកម្ពុជាពាក់ព័ន្ធស្តង់ដារអន្តរជាតិ ប្រតិបត្តិការរបស់ គ.ស.ហ និងក្រុមការងារបច្ចេកទេសផ្សេងៗ។

អ្នកវិភាគបានអនុវត្តមុខងារ-ភារកិច្ចបន្ថែមទាំងនេះ ដែលធ្វើឲ្យប៉ះពាល់ដល់ពេលវេលានៃការអនុវត្តមុខងារស្នូលរបស់ ស.ហ.ក។

ស.ហ.ក មិនមានធនធានគ្រប់គ្រាន់ ដើម្បីសម្រេចបានគោលបំណងយុទ្ធសាស្រ្តគន្លឹះដែលបានលើកឡើងខាងលើ។ ស.ហ.ក មិនមានធនធានគ្រប់គ្រាន់សម្រាប់ការវិភាគជាយុទ្ធសាស្ត្រនៅឡើយ។ ស.ហ.ក មិនទាន់មានលទ្ធភាពវិភាគប្រតិបត្តិការសង្ស័យ ដែលបានទទួលឲ្យទាន់ពេលវេលា ឬមានប្រសិទ្ធភាព ហើយមិនទាន់មានសមត្ថភាពផ្តល់របាយការណ៍វិភាគហិរញ្ញវត្ថុ ដោយស្ម័គ្រចិត្តឲ្យបានច្រើនទៅអាជ្ញាធរអនុវត្តច្បាប់នៅឡើយ។ ដូច្នេះ ស.ហ.ក ត្រូវបង្កើនធនធាន ដើម្បីអនុវត្តគោលនយោបាយ និងមុខងារដូចបានកំណត់ខាងក្រោម។

### ៤.១.១ ការបង្កើនធនធានរបស់ ស.ហ.ក

បច្ចុប្បន្ន ស.ហ.ក មិនទាន់មានធនធានគ្រប់គ្រាន់សម្រាប់ការងារវិភាគ ដើម្បីឆ្លើយតបនឹងចំនួនប្រតិបត្តិការសាច់ប្រាក់និងសង្ស័យ កំណើននៃសំណើសុំព័ត៌មានពីនគរបាល និងពីដៃគូអន្តរជាតិ។ ជាងនេះទៀត នៅពេលអនុវត្តយុទ្ធសាស្ត្រជាតិ ឆ្នាំ២០១៩-២០២៣ នេះ តម្រូវការរបស់ ស.ហ.ក ទំនងជាកើនឡើងបន្ថែមទៀត ដោយសារប្រតិបត្តិការជាច្រើនត្រូវបានរាយការណ៍ដោយបុគ្គលរាយការណ៍ និងតម្រូវការពីអាជ្ញាធរអនុវត្តច្បាប់សម្រាប់ព័ត៌មានស៊ើបការណ៍ហិរញ្ញវត្ថុកើនឡើង (ទាំងចំនួននៃការស្នើសុំ និងភាពស្មុគស្មាញនៃការវិភាគ)។ នៅក្នុងប៉ុន្មានឆ្នាំកន្លងមកនេះ ការរីកចម្រើនឥតឈប់ឈរនៃវិស័យធនាគារនិងហិរញ្ញវត្ថុផ្សេងទៀតបានបង្កើនទំហំនៃព័ត៌មានហិរញ្ញវត្ថុ ដែល ស.ហ.ក ចាំបាច់ត្រូវប្រើប្រាស់ព័ត៌មានទាំងនេះ។ ដូច្នេះ យុទ្ធសាស្ត្រជាតិឆ្នាំ២០១៩-២០២៣នេះផ្តល់ជាអនុសាសន៍ឲ្យរៀបចំផែនការពង្រីកការិយាល័យវិភាគហិរញ្ញវត្ថុរបស់ ស.ហ.ក ដោយបង្កើនចំនួនមន្ត្រីវិភាគឲ្យបានពីរដង និងបន្តបង្កើនចំនួនមន្ត្រីដែលមានបច្ចុប្បន្នឲ្យបានរហូតដល់១២រូប នៅត្រឹមខែមេសាឆ្នាំ២០១៩ ដើម្បីអនុវត្តមុខងារស្នូល[2]របស់ ស.ហ.ក។ ស.ហ.ក ត្រូវរៀបចំផែនការពង្រីកការិយាល័យវិភាគដោយត្រូវបង្កើនចំនួនមន្ត្រីវិភាគឲ្យបានយ៉ាងហោចណាស់ ៣០រូប ក្នុងអំឡុងពេលបញ្ចប់យុទ្ធសាស្ត្រជាតិនេះ[3]។

### ៤.១.២ ជំរុញសមត្ថភាពវិភាគរបស់ ស.ហ.ក

មន្ត្រីវិភាគរបស់ ស.ហ.ក ត្រូវទទួលការបណ្តុះបណ្តាលជាបន្តបន្ទាប់ ដើម្បីធានាថាពួកគេមានភាពស៊ាំជាមួយបច្ចេកទេសវិភាគថ្មីៗបំផុត និងយល់ដឹងអំពីតម្រូវការផ្នែកស៊ើបអង្កេតរបស់ភ្នាក់ងារអនុវត្តច្បាប់។ មន្ត្រីវិភាគរបស់ ស.ហ.ក ត្រូវទទួលបានការបណ្តុះបណ្តាល និងមានមធ្យោបាយដើម្បីមានលទ្ធភាពអនុវត្តការវិភាគជាយុទ្ធសាស្ត្រ និងអាចឲ្យជួយដល់អាជ្ញាធរក្នុងការកំណត់អត្តសញ្ញាណឲ្យបានកាន់តែ

---

២ ការទទួល ការវិភាគ និងការបញ្ជូនរបាយការណ៍ស៊ើបការណ៍ហិរញ្ញវត្ថុទៅអាជ្ញាធរអនុវត្តច្បាប់អំពីការសង្ស័យនៃការសម្អាតប្រាក់ និងសំអាងនៃ បទល្មើសពាក់ព័ន្ធ និងហិរញ្ញប្បទានភេរវកម្ម។

៣ ការផ្តល់អនុសាសន៍លើការបង្កើនធនធានផ្អែកលើកម្រិតនៃចំនួនមន្ត្រីរបស់អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុ ដែលអនុវត្ត មុខងារស្នូលនៅបណ្តាប្រទេសដែលមានវិស័យហិរញ្ញវត្ថុ និងកម្រិតរាយការណ៍ប្រហាក់ប្រហែលនឹងប្រទេសកម្ពុជា។

ប្រសើរពីហានិភ័យ និងនិន្នាការនៃ ស.ប.ហ.ភ កើតឡើងថ្មីៗ។ នៅពេលមានធនធានច្រើន ស.ហ.ក អាចបង្កើនការយល់ដឹងដល់បុគ្គលរាយការណ៍ និងសាធារណជនអំពីនិន្នាការ និងគំរូសិក្សា (Typologies) នៃ ស.ប.ហ.ភ ដែលកើតឡើងថ្មីៗ តាមរយៈការផ្សព្វផ្សាយរបាយការណ៍វិភាគជាយុទ្ធសាស្ត្រ ជូនរាជរដ្ឋាភិបាល និងវិស័យឯកជន។

### ៤.១.៣ ការអភិវឌ្ឍប្រព័ន្ធបច្ចេកវិទ្យាដើម្បីគាំទ្រមុខងារស្នូលរបស់ ស.ហ.ក

ស.ហ.ក មានប្រព័ន្ធផ្ទុកទិន្នន័យ (Database Solution) ដែលអាចផ្ទុកព័ត៌មានហិរញ្ញវត្ថុដែលប្រមូលបានពីបុគ្គលរាយការណ៍ ក្នុងទម្រង់ដែលអាចស្វែងរកបាន។ ប្រការនេះបានបង្ហាញពីធនធានដ៏មានសារៈប្រយោជន៍ចំពោះមន្ត្រីវិភាគ។ ប៉ុន្តែ ឧបករណ៍វិភាគដែលមានស្រាប់ សម្រាប់បកស្រាយនិងវិភាគទិន្នន័យនៅមានកម្រិត។ ស.ហ.ក ត្រូវស្វែងរកវិធីសាស្ត្រ ដើម្បីកែលម្អ បណ្ដុំទិន្នន័យ និងឧបករណ៍វិភាគ និងត្រូវមានធនធានគ្រប់គ្រាន់ប្រើប្រាស់ឧបករណ៍នេះ ដើម្បីបង្កើតរបាយការណ៍ស៊ើបការណ៍ហិរញ្ញវត្ថុដែលមានភាពទូលំទូលាយ គ្រប់ជ្រុងជ្រោយសម្រាប់បញ្ជូនឲ្យអាជ្ញាធរអនុវត្តច្បាប់។ ប្រព័ន្ធផ្ទុកទិន្នន័យណាមួយដែលបានបំពាក់ ត្រូវមានមធ្យោបាយដែលអាចចូលយកព័ត៌មានក្នុងទម្រង់ជាឌីជីថលពីបណ្ដុំទិន្នន័យរបស់រដ្ឋាភិបាល។

## ៤.២ ស.ហ.ក គាំទ្រដល់ការអនុវត្តសកម្មភាពប្រឆាំង ស.ប.ហ.ភ

នៅក្នុងយុត្តាធិការមួយ ដើម្បីឲ្យសមស្របទៅនឹងក្របខ័ណ្ឌអនុវត្តការប្រឆាំង ស.ប.ហ.ភ អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុមួយត្រូវយល់ដឹងពីវិធីសាស្ត្រស៊ើបអង្កេតហិរញ្ញវត្ថុ និងការចោទប្រកាន់ ដែលស្របតាមច្បាប់និងនីតិវិធីរបស់យុត្តាធិការនោះ។ ក្នុងន័យនេះ ការបង្កើនចំណេះដឹងដល់ ស.ហ.ក នឹងបង្កើនប្រសិទ្ធភាពរៀបចំរបាយការណ៍ស៊ើបការណ៍ហិរញ្ញវត្ថុ ដែលអាចជួយអ្នកស៊ើបអង្កេតតាមដាន និងប្រមូលភស្តុតាងអំពីករណីទាំងនេះ។

ស.ហ.ក ត្រូវផ្ដោតការយកចិត្តទុកដាក់ខ្ពស់លើការប្រមូល និងវិភាគព័ត៌មានស៊ើបការណ៍ហិរញ្ញវត្ថុ ពាក់ព័ន្ធនឹងការស៊ើបអង្កេតពីសំអាងនៃបទល្មើសដែលមានហានិភ័យខ្ពស់និងការសម្អាតប្រាក់ពាក់ព័ន្ធនឹងសំអាងនៃបទល្មើសនេះ ការសម្អាតប្រាក់ដោយតតីយភាគី (third party money laundering) និងការសម្អាតផលនៃបទល្មើសពីបរទេស។ ដូចនេះ ស.ហ.ក ត្រូវពង្រឹង និងពង្រីកទំនាក់ទំនងជាមួយអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុបរទេស និងប្រើប្រាស់បណ្ដាញក្រុម Egmont ឲ្យកាន់តែទូលំទូលាយជាងមុន។

### ៤.២.១ ការបង្កើនការយល់ដឹងរបស់ ស.ហ.ក ពីតម្រូវការរបស់អាជ្ញាធរអនុវត្តច្បាប់

ស.ហ.ក ត្រូវបន្តពង្រឹងសមត្ថភាពយល់ដឹងរបស់ខ្លួនពីតម្រូវការរបស់អាជ្ញាធរអនុវត្តច្បាប់ តាមរយៈការបណ្ដុះបណ្ដាល ការចូលរួមក្នុងក្រុមការងារអនុវត្តច្បាប់ និងទទួលយកមតិឆ្លើយតបលើរបាយការណ៍ស៊ើបការណ៍ហិរញ្ញវត្ថុដែលបញ្ជូនដោយ ស.ហ.ក។ ស.ហ.ក បានទទួលសំណើ និងចែករំលែកព័ត៌មាន និងផ្ដល់មតិឆ្លើយតបទៅអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុបរទេសតាមបណ្ដាញ ដែលបង្កើតឡើងដោយក្រុម Egmont។

### ៤.២.២ ការបង្កើនកិច្ចសហប្រតិបត្តិការរវាង ស.ហ.ក និងអាជ្ញាធរអនុវត្តច្បាប់

ស.ហ.ក ត្រូវបន្តបង្កើនទំនាក់ទំនងជាមួយអាជ្ញាធរអនុវត្តច្បាប់ឲ្យកាន់តែប្រសើរឡើង និងបន្តរៀបចំនីតិវិធីប្រតិបត្តិការរបស់ខ្លួនឲ្យមានលក្ខណៈស្តង់ដា តាមរយៈការបង្កើតនីតិវិធីប្រតិបត្តិការស្តង់ដា (SOP)។

### ៤.២.៣ ការបង្កើនការបញ្ជូនព័ត៌មានស៊ើបការណ៍របស់ ស.ហ.ក

ស.ហ.ក ត្រូវបង្កើនការបញ្ជូនព័ត៌មានស៊ើបការណ៍ទៅអាជ្ញាធរអនុវត្តច្បាប់ឲ្យបានច្រើននៅក្នុងអំឡុងពេលនៃការអនុវត្តយុទ្ធសាស្ត្រជាតិ ឆ្នាំ២០១៩-២០២៣ នេះ ជាពិសេសព័ត៌មានស៊ើបការណ៍ដែលពាក់ព័ន្ធនឹងការសម្អាតប្រាក់ ឬសំអាងនៃបទល្មើស ដែលបានកំណត់នៅក្នុងយុទ្ធសាស្ត្រជាតិថាជាប្រភេទបទល្មើសដែលបង្កើតផលនៃបទល្មើសច្រើន។

## ៥. ប្រសិទ្ធភាពនៃការស៊ើបអង្កេតការសម្អាតប្រាក់ និងសំអាងបទល្មើស

ក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩ បានបញ្ចូលបទសម្អាតប្រាក់។ បន្ទាប់មក ច្បាប់ស្តីពីវិសោធនកម្ម មាត្រា៣ មាត្រា២៩ និងមាត្រា៣០ នៃច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ឆ្នាំ២០១៣ បានដាក់ទោសបទសម្អាតប្រាក់មានភាពលម្អិតជាងមុន។ ច្បាប់ទាំងនេះចាំបាច់ត្រូវអនុវត្តយ៉ាងហ្មត់ចត់។ អាជ្ញាធរអនុវត្តច្បាប់ដែលទទួលខុសត្រូវលើការស៊ើបអង្កេតការសម្អាតប្រាក់ ដូចជា អង្គភាពប្រឆាំងអំពើពុករលួយ ដែលទទួលខុសត្រូវលើបទសម្អាតប្រាក់កើតឡើងពីអំពើពុករលួយ អគ្គស្នងការដ្ឋាននគរបាលជាតិ និងភ្នាក់ងារស៊ើបអង្កេតផ្សេងទៀត ដែលទទួលខុសត្រូវលើបទសម្អាតប្រាក់កើតពីសំអាងនៃបទល្មើសផ្សេងៗ ត្រូវកំណត់អត្តសញ្ញាណ និងស៊ើបអង្កេតករណីសម្អាតប្រាក់ (ការស៊ើបអង្កេតសំអាងនៃបទល្មើស ឬការស៊ើបអង្កេតស្របគ្នា)។

អាជ្ញាធរអនុវត្តច្បាប់ ត្រូវស៊ើបអង្កេតនិងចោទប្រកាន់សកម្មភាពសម្អាតប្រាក់ឲ្យបានទូលំទូលាយ (ទាំងបទសម្អាតប្រាក់ និងសំអាងនៃបទល្មើសផ្សេងទៀត) ស្របជាមួយការគំរាមកំហែងនៃការសម្អាតប្រាក់ ដែលបានរកឃើញ ក្នុងរបាយការណ៍វាយតម្លៃហានិភ័យថ្នាក់ជាតិ និងត្រូវបានកំណត់ជាអាទិភាពខ្ពស់នៅក្នុងយុទ្ធសាស្ត្រជាតិ ឆ្នាំ២០១៩-២០២៣ នេះ។ ការសម្អាតប្រាក់ដោយតតីយភាគី និងបុគ្គលដែលប៉ុនប៉ងសម្អាតផលនៃបទល្មើសពីបរទេសត្រូវដាក់ជាអាទិភាពខ្ពស់។ ការស៊ើបអង្កេតការសម្អាតប្រាក់ត្រូវស៊ើបអង្កេតទាំងរូបវន្តបុគ្គលនិងនីតិបុគ្គលដែលពាក់ព័ន្ធសកម្មភាពសម្អាតប្រាក់។

អាជ្ញាធរស៊ើបអង្កេតត្រូវមានទំនាក់ទំនងជាប្រចាំជាមួយក្រសួង-ស្ថាប័នផ្សេងទៀត ចំពោះការស៊ើបអង្កេត ព្រោះក្នុងករណីដែលមិនអាចកាត់ទោសការសម្អាតប្រាក់ឬសំអាងនៃបទល្មើសបាន អាជ្ញាធរស៊ើបអង្កេត អាចសហការជាមួយក្រសួង-ស្ថាប័នទាំងនោះដើម្បីចាត់វិធានការច្បាប់ផ្សេងទៀត ដូចជា អនុវត្តដំណើរការបណ្តឹងប្រមូលពន្ធត្រលប់មកវិញ ជាដើម។

ប្រភពព័ត៌មានស៊ើបការណ៍ដែលអាចរកបាន និងដែលមាននៅ ស.ហ.ក អាជ្ញាធរអនុវត្តច្បាប់ត្រូវយកទៅប្រើប្រាស់ជាប្រចាំ ឲ្យទាន់ពេលវេលា និងមានប្រសិទ្ធភាព សម្រាប់ការស៊ើបអង្កេត និងចោទប្រកាន់បទសម្អាតប្រាក់ និងបទហិរញ្ញប្បទានភេរវកម្ម និងការរឹបអូសផលនៃបទល្មើស។ ទន្ទឹមនេះ អាជ្ញាធរអនុវត្តច្បាប់ត្រូវសកម្មក្នុងការស្វែងរកព័ត៌មានស៊ើបការណ៍ នៅរាល់ពេលផ្តួចផ្តើមការស៊ើបអង្កេតណាមួយ ឬនៅពេលទទួលបានព័ត៌មានស៊ើបការណ៍ដោយស្ម័គ្រចិត្ត (Spontaneous Dissemination) ពី ស.ហ.ក។ អាជ្ញាធរអនុវត្តច្បាប់ត្រូវប្រើប្រាស់របាយការណ៍ស៊ើបការណ៍ហិរញ្ញវត្ថុជាមូលដ្ឋាន ដើម្បីបង្កើតគោលនយោបាយ និងកម្មវិធីស៊ើបអង្កេត។

## ៥.១ ការកសាងធនធាននិងសមត្ថភាពរបស់អាជ្ញាធរទទួលខុសត្រូវការស៊ើបអង្កេតការសម្អាតប្រាក់ និងសំអាងនៃបទល្មើស (អគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គនាយកដ្ឋានពន្ធដារ អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា អង្គភាពប្រឆាំងអំពើពុករលួយ)

អាជ្ញាធរអនុវត្តច្បាប់សំខាន់ៗមួយចំនួនមានសិទ្ធិអំណាចស៊ើបអង្កេតសំអាងបទល្មើស និងការសម្អាតប្រាក់ពាក់ព័ន្ធ ឬបទសម្អាតប្រាក់ឯកឯង [4]។ ទោះជាយ៉ាងណា អាជ្ញាធរអនុវត្តច្បាប់បានស៊ើបអង្កេតបទសម្អាតប្រាក់ក្នុងចំនួនតិចតួច ហើយការកាត់ទោសមានតែមួយករណីប៉ុណ្ណោះ[5] ក្រោយពេលបទសម្អាតប្រាក់មានចែងក្នុងច្បាប់ ស្តីពីវិសោធនកម្មមាត្រា ៣ មាត្រា ២៩ និងមាត្រា ៣០ នៃច្បាប់ ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ឆ្នាំ២០១៣។ អាជ្ញាធរអនុវត្តច្បាប់មានសិទ្ធិអំណាចគ្រប់គ្រាន់ក្នុងការស៊ើបអង្កេតបទសម្អាតប្រាក់ និងសំអាងនៃបទល្មើសប្រកបដោយប្រសិទ្ធភាព។ ច្បាប់បានផ្តល់សិទ្ធិអំណាចអាជ្ញាធរអនុវត្តច្បាប់ តាមដាន និងកំណត់អត្តសញ្ញាណទ្រព្យសម្បត្តិ ចុះស្រាវជ្រាវ ប្រមូលចម្លើយសាក្សី និងការពារភស្តុតាង។

អាជ្ញាធរអនុវត្តច្បាប់ស៊ើបអង្កេតផលនៃបទល្មើសជាច្រើនធ្វើជារៀងរាល់ឆ្នាំ ក៏ប៉ុន្តែការចោទប្រកាន់ករណីសម្អាតប្រាក់ ឬការរឹបអូសផលនៃបទល្មើសមានតិចតួចប៉ុណ្ណោះ។ មន្ត្រីនគរបាលនិងអ្នកស៊ើបអង្កេតផ្សេងទៀតមានកង្វះខាតការយល់ដឹងអំពីបទសម្អាតប្រាក់ ឬរបៀបសម្អាតប្រាក់ ដែលបណ្តាលឲ្យមានការស៊ើបអង្កេតបទល្មើសនេះពុំបានត្រឹមត្រូវ។ កង្វះខាតសមត្ថភាពក្នុងការស៊ើបអង្កេត ធនធានមនុស្ស និងហិរញ្ញវត្ថុនៅមានកម្រិត ជាបញ្ហាប្រឈមមួយ ដោយសារមានការខ្វះខាតការគាំទ្រពីមន្ត្រីជាន់ខ្ពស់ក្នុងការបន្តតាមដានករណីសម្អាតប្រាក់។ បញ្ហាទាំងអស់នេះ ចាំបាច់ត្រូវដោះស្រាយ។

### ៥.១.១ ការបង្កើនធនធានដើម្បីគាំទ្រការស៊ើបអង្កេតការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម

តម្រូវការធនធាន និងមូលនិធិបន្ថែមសម្រាប់ការអនុវត្តការប្រឆាំង ស.ប.ហ.ភ ចាំបាច់ត្រូវមាន ដើម្បីដោះស្រាយជាមួយនឹងកំណើននៃតម្រូវការស៊ើបអង្កេតការសម្អាតប្រាក់ ដែលបណ្តាលមកពីបទល្មើសហិរញ្ញវត្ថុ ដែលកើតចេញពីកំណើនសេដ្ឋកិច្ច វិស័យទេសចរណ៍ និងកត្តាដទៃទៀតរបស់ប្រទេសកម្ពុជា ដែលធ្វើឲ្យទាក់ទាញដល់ការសម្អាតប្រាក់ ដូចជា ការកើនឡើងនៃវិស័យកាស៊ីណូ អចលនទ្រព្យ និងវិស័យ

---

៤ អគ្គស្នងការដ្ឋាននគរបាលជាតិ នាពេលថ្មីៗនេះបានបង្កើតនាយកដ្ឋានឧក្រិដ្ឋកម្មឆ្លងដែន ដើម្បីស៊ើបអង្កេតការសម្អាតប្រាក់ និងការរឹបអូសទ្រព្យសម្បត្តិដែលជាផលនៃបទល្មើស។ ការិយាល័យសម្អាតប្រាក់ស៊ើបអង្កេតស្របគ្នាជាមួយនឹងអង្គភាពប្រឆាំងបទល្មើសរបស់អគ្គស្នងការដ្ឋាននគរបាលជាតិ (គ្រឿងញៀន ក្លែងបន្លំ និងផ្នែកបទល្មើសផ្សេងៗទៀត) ដែលធ្វើការផ្តោតសំខាន់ទៅលើការស៊ើបអង្កេតសម្រាប់ការចោទប្រកាន់បទសម្អាតប្រាក់ និងកំណត់ផលនៃបទល្មើស និងរឹបអូសទ្រព្យសម្បត្តិដែលពាក់ព័ន្ធនឹងបទល្មើស។ អគ្គនាយកដ្ឋានពន្ធដារ ស៊ើបអង្កេតការសម្អាតប្រាក់ពាក់ព័ន្ធនឹងការគេចពន្ធ ដែលរួមមានការស៊ើបអង្កេត ការឃាត់ទុក និងបង្កកទ្រព្យសម្បត្តិពាក់ព័ន្ធការសម្អាតប្រាក់។ អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា អាចស៊ើបអង្កេតសំអាងនៃបទល្មើស ឃាត់ទុក និងបង្កកទ្រព្យសម្បត្តិពាក់ព័ន្ធការសម្អាតប្រាក់និងសំអាងនៃបទល្មើស។ អង្គភាពប្រឆាំងអំពើពុករលួយ អាចស៊ើបអង្កេត តាមដាន និងឃាត់ទុកទ្រព្យសម្បត្តិ ផលនៃបទល្មើសទាក់ទងនឹងបទពុករលួយ។

៥ ការផ្តន្ទាទោសលើកដំបូងបង្អស់ លើការសម្អាតប្រាក់ត្រូវបានធ្វើឡើងនៅខែមិថុនា ឆ្នាំ២០១៨។

ធនាគារ។ នៅបណ្ដាប្រទេសជាច្រើន ក្រុមការងារពិសេសប្រឆាំងការសម្អាតប្រាក់ ឬអង្គភាពផ្សេងទៀត បានខិតខំស៊ើបអង្កេតការសម្អាតប្រាក់ និងបទល្មើសហិរញ្ញវត្ថុ រួមមាន ក្រុមប្រឆាំងការរត់ពន្ធសាច់ប្រាក់នៅតាមព្រលានយន្តហោះ និងតាមព្រំដែន។ ក្រុមការងារទាំងនេះអាចរ៉ាប់រងការចំណាយប្រតិបត្តិការរបស់ខ្លួនតាមរយៈការរឹបអូសសាច់ប្រាក់រត់ពន្ធ និងផលនៃបទល្មើសផ្សេងទៀតដែលបានរកឃើញនៅក្នុងពេលបំពេញការងារ។ គ.ស.ហ ត្រូវបង្កើតយន្តការទ្រទ្រង់ការចំណាយក្នុងការអនុវត្តការប្រឆាំង ស.ប.ហ.ភ ពីផលនៃបទល្មើស និងឧបករណ៍ប្រព្រឹត្តបទល្មើសដែលបានរឹបអូស ហើយដាក់សំណើបង្កើតយន្តការនេះជូនរដ្ឋាភិបាល។

### ៥.១.២ ការកសាងសមត្ថភាពតាមរយៈការបណ្ដុះបណ្ដាល

អាជ្ញាធរអនុវត្តច្បាប់ត្រូវទទួលការបណ្ដុះបណ្ដាល និងមានធនធានឯកទេសគ្រប់គ្រាន់ ដើម្បីអនុវត្តការស៊ើបអង្កេតហិរញ្ញវត្ថុដែលមានភាពស្មុគស្មាញ តាមមុខងារនិងភារកិច្ចរបស់ខ្លួន។ ជំហានដំបូង អាជ្ញាធរអនុវត្តច្បាប់ត្រូវវាយតម្លៃពីតម្រូវការរបស់ខ្លួនទាំងការបណ្ដុះបណ្ដាល និងការអភិវឌ្ឍសមត្ថភាព។ អាជ្ញាធរត្រូវបង្កើត និងអនុវត្តផែនការ ដើម្បីទទួលបានមូលនិធិជាចាំបាច់ សម្រាប់ការបណ្ដុះបណ្ដាល និងការកសាងសមត្ថភាព។

### ៥.១.៣ ការបង្កើតក្រុមការងារពិសេសទទួលបន្ទុកស៊ើបអង្កេតការសម្អាតប្រាក់

ដើម្បីទទួលបានជោគជ័យ ការស៊ើបអង្កេតការសម្អាតប្រាក់ទាមទារឲ្យមានកិច្ចខិតខំប្រឹងប្រែងស៊ើបអង្កេតដោយយកចិត្តទុកដាក់។ មធ្យោបាយមួយក្នុងការសម្រេចបានភាពជោគជ័យនេះគឺត្រូវបង្កើតឲ្យមានអង្គភាពទទួលបន្ទុករួមគ្នាដោយមានអាណត្តិច្បាស់លាស់មួយ ដើម្បីអនុវត្តការស៊ើបអង្កេតការសម្អាតប្រាក់។ អង្គភាពទាំងនេះអាចចេញសេចក្ដីណែនាំ ឬគាំទ្រការស៊ើបអង្កេតបទសម្អាតប្រាក់ ឬបទល្មើសហិរញ្ញវត្ថុផ្សេងទៀតទៅឲ្យអង្គភាពស៊ើបអង្កេតសំអាងនៃបទល្មើស ដែលនឹងជួយដល់អាជ្ញាធរអនុវត្តច្បាប់ក្នុងការស៊ើបអង្កេតស្របគ្នា លើសំអាងនៃបទល្មើសពាក់ព័ន្ធការសម្អាតប្រាក់ឲ្យបានជោគជ័យ។

អាជ្ញាធរអនុវត្តច្បាប់ ដែលទទួលខុសត្រូវការស៊ើបអង្កេតការសម្អាតប្រាក់ពាក់ព័ន្ធនឹងសំអាងនៃបទល្មើសដែលមានហានិភ័យខ្ពស់ ត្រូវពិនិត្យឡើងវិញនូវរចនាសម្ព័ន្ធដែលមានស្រាប់។ ដូច្នេះ អាជ្ញាធរត្រូវសម្រួលការងារទទួលខុសត្រូវផ្ទៃក្នុងដើម្បីបង្កើនប្រសិទ្ធភាពនៃការបែងចែកការទទួលខុសត្រូវរបស់ខ្លួន។ ឧទាហរណ៍ អគ្គស្នងការដ្ឋាននគរបាលជាតិអាចពិចារណាថា តើការបែងចែកការទទួលខុសត្រូវបច្ចុប្បន្ននេះឲ្យទៅនាយកដ្ឋានប្រឆាំងគ្រឿងញៀន ដើម្បីស៊ើបអង្កេតការសម្អាតប្រាក់ជាវិធីដ៏មាន ប្រសិទ្ធភាពខ្ពស់ ឬទេ។ អង្គភាពប្រឆាំងអំពើពុករលួយ និងអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ត្រូវអនុវត្តសកម្មភាពដូចគ្នានេះដែរ។

### ៥.១.៤ ពិចារណាលើការបង្កើតក្រុមការងារពិសេសអន្តរក្រសួង

ចរិតលក្ខណៈស្មុគស្មាញ នៃការស៊ើបអង្កេតការសម្អាតប្រាក់ទាមទារឲ្យអាជ្ញាធរអនុវត្តច្បាប់ពាក់ព័ន្ធខិតខំប្រឹងប្រែងសហការគ្នា ដើម្បីអនុវត្តការស៊ើបអង្កេតឲ្យមានប្រសិទ្ធភាព។ មធ្យោបាយមួយដើម្បីសម្រេចបានជោគជ័យ គឺត្រូវបង្កើតក្រុមការងារពិសេសមួយ ដែលមានអាណត្តិច្បាស់លាស់ដើម្បីស៊ើបអង្កេតបទសម្អាតប្រាក់ឲ្យបានម៉ត់ចត់។

មធ្យោបាយនេះទទួលស្គាល់ដោយ FATF និងបានបង្ហាញពីប្រសិទ្ធភាពនៅប្រទេសជាច្រើនដែលបានបង្កើតក្រុមការងារពិសេសនេះ។ ក្រុមការងារពិសេសនេះមានសមាសភាពមកពីអ្នកស៊ើបអង្កេតផ្នែកហិរញ្ញវត្ថុ ដែលជាភ្នាក់ងារពាក់ព័ន្ធការប្រឆាំងការសម្អាតប្រាក់សំខាន់ៗ ដូចជា មន្ត្រីនគរបាល មន្ត្រីពន្ធដារ មន្ត្រីគយ ព្រះរាជអាជ្ញា និងអ្នកស៊ើបអង្កេតសំអាងនៃបទល្មើសផ្សេងៗទៀត (ដូចជា ផ្នែកគ្រឿងញៀន ប្រឆាំងអំពើពុករលួយ និងប្រឆាំងបទល្មើសបរិស្ថាន ជាដើម) និងអាចមានតំណាងមកពីអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុផងដែរ។ ពេលបង្កើតបានរួចហើយ ក្រុមការងារពិសេសរួមស្ដីពីការប្រឆាំង ស.ប.ហ.ភ នឹងដឹកនាំការស៊ើបអង្កេត ស.ប.ហ.ភ ដែលទទួលខុសត្រូវការស៊ើបអង្កេតពហុយុត្តាធិការ ឬអន្តរជាតិ ឬការស៊ើបអង្កេតពាក់ព័ន្ធករណី ស.ប.ហ.ភ ធំនិងស្មុគស្មាញ ។ ក្រុមការងារពិសេសនេះអាចប្រើប្រាស់ទេពកោសល្យ និងសិទ្ធិអំណាចរបស់ខ្លួនរួមគ្នា ដើម្បីកំណត់គោលដៅសំអាងនៃបទល្មើសដែលមានហានិភ័យខ្ពស់ និងសកម្មភាពសម្អាតប្រាក់ពាក់ព័ន្ធផងដែរ។ ក្រុមការងារពិសេសអន្តរក្រសួង-ស្ថាប័ននេះមិនអាចជំនួសអង្គភាព ដែលបង្កើតឡើងសម្រាប់សំអាងនៃបទល្មើសរបស់អាជ្ញាធរអនុវត្តច្បាប់បានទេ (ឧទាហរណ៍ ការិយាល័យស៊ើបអង្កេតឧក្រិដ្ឋកម្មរបស់ អគ្គស្នងការដ្ឋាននគរបាលជាតិ ដែលបង្កើតអង្គភាពមួយសម្រាប់ការរឹបអូសទ្រព្យសម្បត្តិ)។

ដើម្បីអនុវត្តតាមស្តង់ដារបស់ FATF និងជំរុញប្រសិទ្ធភាពនៃអាជ្ញាធរអនុវត្តច្បាប់ក្នុងការស៊ើបអង្កេត ស.ប.ហ.ភ ប្រទេសកម្ពុជា ត្រូវបង្កើតក្រុមការងារពិសេស ដែលមានសមាសភាពពី អគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ ព្រះរាជអាជ្ញា អង្គភាពប្រឆាំងអំពើពុករលួយ ស.ហ.ក និងក្រសួង-ស្ថាប័នដ៏ទៃទៀត។

ឧទាហរណ៍ ក្រុមការងារពិសេសប្រឆាំង ស.ប.ហ.ភ ពាក់ព័ន្ធការរត់ពន្ធសាច់ប្រាក់ឆ្លងដែន ត្រូវឈរជើងតាមព្រលានយន្តហោះអន្តរជាតិ និងតំបន់ព្រំដែនសំខាន់ៗ ដូចជា អាកាសយានដ្ឋានអន្តរជាតិភ្នំពេញនិងសៀមរាប និងតំបន់ឆ្លងកាត់ព្រំដែនប៉ោយប៉ែត ជាដើម។ ក្រុមការងារពិសេសនេះ ដឹកនាំដោយ អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា និងមានសមាជិកជាអ្នកស៊ើបអង្កេតមកពី អគ្គនាយកដ្ឋានពន្ធដារ អគ្គស្នងការដ្ឋាននគរបាលជាតិ ព្រមទាំងគាំទ្រដោយ ស.ហ.ក។ ក្រុមការងារពិសេសនេះមានសិទ្ធិអំណាចស្វែងរកការរត់ពន្ធសាច់ប្រាក់ឆ្លងដែន និងរៀបចំលទ្ធផលពីការស៊ើបអង្កេត ស.ប.ហ.ភ។

ក្រុមការងារពិសេសនេះត្រូវទទួលខុសត្រូវឆ្លើយតបសំណើសុំព័ត៌មាន ស.ប.ហ.ភ ពីដៃគូបរទេសពាក់ព័ន្ធការរត់ពន្ធសាច់ប្រាក់ឆ្លងដែនផងដែរ។

### ៥.២ ការបង្កើនការស៊ើបអង្កេតការសម្អាតប្រាក់ និងបទល្មើសហិរញ្ញវត្ថុ

អ្នកស៊ើបអង្កេតករណីសម្អាតប្រាក់ ត្រូវសហការយ៉ាងជិតស្និតជាមួយអ្នកទទួលបន្ទុកស៊ើបអង្កេតសំអាងនៃបទល្មើស (ឧ.អង្គភាពប្រឆាំងគ្រឿងញៀន) ដើម្បីសម្រេចបានជោគជ័យនៃការស៊ើបអង្កេតការសម្អាតប្រាក់ ការរឹបអូសទ្រព្យសម្បត្តិ និងការរក្សាភស្តុតាង សម្រាប់ការចោទប្រកាន់។ ការស៊ើបអង្កេតការសម្អាតប្រាក់ស្របគ្នាជាមួយនឹងការស៊ើបអង្កេតសំអាងនៃបទល្មើសនឹងបង្កភាពងាយស្រួល ដល់ការកំណត់ផលនៃបទល្មើស និងភស្តុតាងឲ្យបានទាន់ពេលវេលា ដើម្បីគាំទ្រករណីសម្អាតប្រាក់។ វិធីសាស្ត្រស៊ើបអង្កេតស្របគ្នានេះ ជំរុញឲ្យមានទំនាក់ទំនងដ៏មានប្រសិទ្ធភាពរវាងអ្នកស៊ើបអង្កេតការសម្អាតប្រាក់ និងអ្នកស៊ើបអង្កេតសំអាងនៃបទល្មើស និងកាត់បន្ថយហានិភ័យនៃការបំផ្លាញចោល ឬបិទបាំងភស្តុតាង ឬផលនៃបទល្មើស។

#### ៥.២.១ ការបង្កើតអាទិភាព និងយុទ្ធសាស្ត្រស៊ើបអង្កេតការសម្អាតប្រាក់ថ្នាក់ជាតិ

អាទិភាព រួមមានការធានាថា អាជ្ញាធរអនុវត្តច្បាប់នីមួយៗ ១/-មានធនធានគ្រប់គ្រាន់ ដូចបានកំណត់នៅក្នុងផ្នែក៥.១ សម្រាប់ការស៊ើបអង្កេតករណីសម្អាតប្រាក់ ២/-មានរចនាសម្ព័ន្ធចាត់តាំងសម្រាប់ការស៊ើបអង្កេតសម្អាតប្រាក់ឲ្យមានប្រសិទ្ធភាព ៣/- មានការបណ្តុះបណ្តាលអ្នកស៊ើបអង្កេតដូចមានចែងក្នុងផ្នែក៥.១.២ ទាក់ទងនឹងគោលនយោបាយ និងសៀវភៅណែនាំសម្រាប់ដំណើរការស៊ើបអង្កេតការសម្អាតប្រាក់ និង៤/-បង្កើតក្រុមការងារបច្ចេកទេស ដើម្បីគាំទ្រកិច្ចសហប្រតិបត្តិការថ្នាក់ជាតិលើការស៊ើបអង្កេតការសម្អាតប្រាក់។

#### ៥.២.២ ការបង្កើតគោលនយោបាយ និងយុទ្ធសាស្ត្រផ្ទៃក្នុងដើម្បីស៊ើបអង្កេតការសម្អាតប្រាក់

ក្រសួង-ស្ថាប័ននីមួយៗដែលទទួលខុសត្រូវ ការស៊ើបអង្កេតការសម្អាតប្រាក់ ឬសំអាងនៃបទល្មើសណាមួយ ត្រូវបង្កើតគោលនយោបាយ និងនីតិវិធីផ្ទៃក្នុងសមស្រប ដែលនឹងបណ្តាលឲ្យមានការស្វែងរក និងការស៊ើបអង្កេតការសម្អាតប្រាក់កាន់តែមានប្រសិទ្ធភាព។ គោលនយោបាយទាំងនេះ តម្រូវឲ្យអ្នកស៊ើបអង្កេតសំអាងនៃបទល្មើស យកចិត្តទុកដាក់លើការចោទប្រកាន់ការសម្អាតប្រាក់ជាពិសេសសំអាងនៃបទល្មើស ដែលមានហានិភ័យសម្អាតប្រាក់ខ្ពស់ និងការបញ្ជូនករណីពាក់ព័ន្ធការសម្អាតប្រាក់នេះទៅអង្គភាពជំនាញស៊ើបអង្កេតការសម្អាតប្រាក់។

## ៦. ការជំរុញប្រសិទ្ធភាពនៃការចោទប្រកាន់ការសម្អាតប្រាក់ និងសំអាងនៃបទល្មើស

ការសម្អាតប្រាក់ត្រូវបានចាត់ជាបទល្មើសព្រហ្មទណ្ឌនៅក្នុងក្រមព្រហ្មទណ្ឌចាប់តាំងពីឆ្នាំ២០០៩។ បន្ទាប់មក ច្បាប់ស្តីពីវិសោធនកម្មមាត្រា៣ មាត្រា២៩ និងមាត្រា៣០ នៃច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ឆ្នាំ២០១៣ បានកំណត់និយមន័យការសម្អាតប្រាក់ស្របតាមបទដ្ឋានអន្តរជាតិ និងដាក់ទោសទណ្ឌយ៉ាងធ្ងន់ធ្ងរចំពោះរូបវន្តបុគ្គល និងនីតិបុគ្គលណា ដែលបំប្លែងធ្វើលទ្ធកម្ម កាន់កាប់ ឬជួញដូរទ្រព្យសម្បត្តិ ដោយដឹងថា ទ្រព្យសម្បត្តិនេះជាផលនៃបទល្មើស (ទោះជាបានប្រព្រឹត្តនៅក្នុងប្រទេសកម្ពុជា ឬនៅបរទេស)។

ទោះជាយ៉ាងណា អាជ្ញាធរអនុវត្តច្បាប់ បានស៊ើបអង្កេតបទសម្អាតប្រាក់ ក្នុងចំនួនតិចតួច ហើយការចោទប្រកាន់ និងការកាត់ទោសរឹតតែមានចំនួនតិចតួចថែមទៀត។ ទោះបីបទសម្អាតប្រាក់បានប្រព្រឹត្តក្រោមរូបភាពជាច្រើន នៅពេលដែលមានសំអាងនៃបទល្មើស ប៉ុន្តែការស៊ើបអង្កេត និងការចោទប្រកាន់បទសម្អាតប្រាក់នៅមានចំនួនតិចតួច ។ បញ្ហានេះមិនមែនមានន័យថា ការចោទប្រកាន់ពីបទសម្អាតប្រាក់ ត្រូវធ្វើដោយស្វ័យប្រវត្តិភ្ជាប់ជាមួយនឹងការចោទប្រកាន់សំអាងនៃបទល្មើសនោះទេ។ សកម្មភាពសម្អាតប្រាក់ ដែលកើតចេញពីសំអាងនៃបទល្មើសជាច្រើនពុំមានស្ថានទម្ងន់ទោស ឬភាពស្មុគស្មាញគ្រប់គ្រាន់ ដើម្បីដាក់ទោសលើសពីទណ្ឌកម្មដែលបានដាក់ចំពោះសំអាងនៃបទល្មើសនោះឡើយ។

សម្រាប់មូលហេតុខាងលើ បទសម្អាតប្រាក់ ត្រូវកំណត់អត្តសញ្ញាណឲ្យបាននិងមានភស្តុតាងគ្រប់គ្រាន់ ដើម្បីគាំទ្រការចោទប្រកាន់ ហើយការចោទប្រកាន់បទល្មើសនេះត្រូវពិចារណាបន្ថែមលើរាល់ការចោទប្រកាន់សំអាងនៃបទល្មើស។ ការចោទប្រកាន់អ្នកសម្អាតប្រាក់តតិយភាគីពីបទសម្អាតប្រាក់ត្រូវចាត់ទុកជាអាទិភាពខ្ពស់បំផុត ជាពិសេស បុគ្គលរាយការណ៍ដូចមានចែងក្នុងមាត្រា៤ នៃច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្មឆ្នាំ២០០៧ ឬ អ្នកដែលពាក់ព័ន្ធនឹងការសម្អាតផលនៃបទល្មើសបរទេសនៅក្នុងប្រទេសកម្ពុជា។

### ៦.១ បង្កើនធនធានសម្រាប់ការចោទប្រកាន់បទសម្អាតប្រាក់ និងសំអាងនៃបទល្មើស

អាជ្ញាធរអនុវត្តច្បាប់ត្រូវផ្តល់អាទិភាព និងបង្កើនធនធាន សម្រាប់កិច្ចដំណើរការចោទប្រកាន់បទសម្អាតប្រាក់ និងសំអាងនៃបទល្មើសមានហានិភ័យខ្ពស់ដែលការអនុវត្តបែបនេះ ព្រះរាជអាជ្ញាអាចស៊ើបអង្កេត និងចោទប្រកាន់ករណីទាំងនេះបាន។

ស្ថាប័នអយ្យការត្រូវបង្កើតឲ្យមានគោលនយោបាយបំពេញបន្ថែម និងធនធានគ្រប់គ្រាន់សម្រាប់ការចោទប្រកាន់សំអាងនៃបទល្មើសមានហានិភ័យខ្ពស់ (ដូចជា ការបន្លំលួច អំពើពុករលួយ និងបទសម្អាតប្រាក់ពាក់ព័ន្ធផ្សេងទៀត) ស្របតាមការកំណត់របស់យុទ្ធសាស្ត្រជាតិ ឆ្នាំ២០១៩-២០២៣។

### ៦.១.១ ការបង្កើនធនធានសម្រាប់ចោទប្រកាន់បទសម្អាតប្រាក់

ស្ថាប័នអយ្យការត្រូវបង្កើនធនធានបន្ថែមទៀត ដើម្បីអនុវត្តការចោទប្រកាន់បទសម្អាតប្រាក់ដោយមិនឲ្យប៉ះពាល់ដល់ការបំពេញមុខងារផ្សេងទៀតរបស់ខ្លួន។

### ៦.១.២ ការកសាងសមត្ថភាពតាមរយៈការបណ្តុះបណ្តាល

ព្រះរាជអាជ្ញា ឬទីប្រឹក្សា ដែលត្រូវបានជ្រើសរើសជាអ្នកឯកទេសខាងការចោទប្រកាន់ការសម្អាតប្រាក់ ត្រូវទទួលការបណ្តុះបណ្តាលឲ្យបានទូលំទូលាយ។ ប៉ុន្តែ បច្ចុប្បន្ននេះការបណ្តុះបណ្តាលក្នុងប្រទេសមានការលំបាក ហើយមធ្យោបាយចម្បងនៃការបណ្តុះបណ្តាលជំនាញរឹបអូស នេះអាចធ្វើបានតាមរយៈការហ្វឹកហាត់ការងារ។ ហេតុនេះ ស្ថាប័នអយ្យការត្រូវជ្រើសរើសព្រះរាជអាជ្ញាដែលមានបទពិសោធន៍ផ្នែកបទល្មើសហិរញ្ញវត្ថុមកបំពេញភារកិច្ចនេះ។

មន្ត្រីបច្ចេកទេសត្រូវទទួលការបណ្តុះបណ្តាល អំពីក្របខ័ណ្ឌច្បាប់ទាក់ទងការចោទប្រកាន់បទសម្អាតប្រាក់ និងសំអាងនៃបទល្មើសដែលមានហានិភ័យខ្ពស់ ហើយការបណ្តុះបណ្តាលនេះត្រូវមានគោលនយោបាយ និងរចនាសម្ព័ន្ធច្បាស់លាស់។

### ៦.១.៣ ការបង្កើតក្រុមការងារពិសេសទទួលបន្ទុកការចោទប្រកាន់ការសម្អាតប្រាក់

ការអនុវត្តនៅក្នុងយុត្តាធិការជាច្រើនបានបង្ហាញថា ការប្រឹក្សាយោបល់ និងការគាំទ្រឯកទេសសម្រាប់ចោទប្រកាន់ការសម្អាតប្រាក់អាចធ្វើឡើងតាមរយៈ ការបង្កើតអង្គភាព ឬក្រុមការងារទទួលបន្ទុកនៅក្នុងស្ថាប័ននីមួយៗ និងពេលខ្លះតាមរយៈការបង្កើតក្រុមការងារពិសេសអន្តរក្រសួង-ស្ថាប័ន។ ស្ថាប័នអយ្យការត្រូវដោះស្រាយឲ្យត្រូវតាមស្ថានភាពការងាររបស់ពួកគេ។

អង្គភាពទទួលបន្ទុកការចោទប្រកាន់ការសម្អាតប្រាក់អាចបំពេញការងារលើការចោទប្រកាន់បទសម្អាតប្រាក់ដោយឯកឯង ឬការចោទប្រកាន់ រួមគ្នាឬស្របគ្នា ជាមួយសំអាងនៃបទល្មើស។ អង្គភាពនេះក៏ទទួលខុសត្រូវក្នុងការចោទប្រកាន់បទសម្អាតប្រាក់ ទាក់ទងនឹងការសម្អាតផលនៃបទល្មើសពីបរទេសនៅប្រទេសកម្ពុជា និងការចោទប្រកាន់ចំពោះបទសម្អាតប្រាក់របស់តតីយភាគីផងដែរ។

ព្រះរាជអាជ្ញាទទួលបន្ទុកចោទប្រកាន់ការសម្អាតប្រាក់ និងព្រះរាជអាជ្ញាទទួលបន្ទុកចោទប្រកាន់សំអាងនៃបទល្មើស និងអ្នកស៊ើបអង្កេតត្រូវបង្កើតឲ្យមានកិច្ចសម្របសម្រួល និងការទំនាក់ទំនងដើម្បីធានាប្រសិទ្ធភាពនៃការចោទប្រកាន់ការសម្អាតប្រាក់។

## ៦.២ ការកំណត់អាទិភាពការចោទប្រកាន់បទសម្អាតប្រាក់

ស្ថាប័នអយ្យការត្រូវបង្កើតគោលនយោបាយ ស្តីពីការចោទប្រកាន់បទសម្អាតប្រាក់ ដោយកំណត់អាទិភាពលើការចោទប្រកាន់បទសម្អាតប្រាក់ និងផ្តល់ការណែនាំដល់ព្រះរាជអាជ្ញាអំពីបទសម្អាតប្រាក់ដែលកើតចេញពីការចោទប្រកាន់សំអាងនៃបទល្មើស។

គោលនយោបាយទាំងនេះ តម្រូវឲ្យព្រះរាជអាជ្ញាទាំងអស់ពិចារណាឲ្យបានត្រឹមត្រូវមុនពេលដាក់ការចោទប្រកាន់ពីបទសម្អាតប្រាក់ ពេលដែលផលនៃបទល្មើសបានកើតឡើង។ គោលនយោបាយនេះត្រូវកំណត់ពីអាទិភាពខ្ពស់បំផុតចំពោះការចោទប្រកាន់បទសម្អាតប្រាក់ ទាក់ទងទៅនឹងសំអាងនៃបទល្មើសដែលមានហានិភ័យខ្ពស់ បទល្មើសដែលផលនៃបទល្មើសពីបរទេស និងបទសម្អាតប្រាក់ដែលបានប្រព្រឹត្តដោយតតិយភាគី។

## ៧. ការជំរុញប្រសិទ្ធភាពនៃការរឹបអូសផលនៃបទល្មើស

អាជ្ញាធរមានសមត្ថកិច្ច ស្ថាប័នអយ្យការ និងតុលាការ ទទួលខុសត្រូវក្នុងការស៊ើបអង្កេត ឬការចោទប្រកាន់ពីបទសម្អាតប្រាក់ និងសំអាងនៃបទល្មើសត្រូវមានគោលនយោបាយច្បាស់លាស់មួយតាមដានពីការរឹបអូសផល និងឧបករណ៍បានមកពីបទល្មើស។

ប្រទេសកម្ពុជាមានក្របខ័ណ្ឌច្បាប់សម្រាប់តាមដាន បង្កក និងឃាត់ទុកផលនិងឧបករណ៍នៃបទល្មើស ព្រមទាំងសម្រាប់ការរឹបអូសទ្រព្យសម្បត្តិទាំងនោះក្រោយពីកាត់ទោសបទសម្អាតប្រាក់ ឬសំអាងនៃបទល្មើស។ ក្របខ័ណ្ឌនេះជាសក្ខីកម្មនៃគោលនយោបាយកម្រិតខ្ពស់ក្នុងការគាំទ្រការរឹបអូសផលនិងឧបករណ៍នៃបទល្មើសនៅក្នុងប្រទេសកម្ពុជា។

ប៉ុន្តែ ស្ថិតិបានបង្ហាញថា ការអនុវត្តក្របខ័ណ្ឌច្បាប់នេះនៅមានកម្រិតនៅឡើយ។

ជាក់ស្តែង រាល់ឧបករណ៍ ឬផលនៃបទល្មើសបានពីបទល្មើសនីមួយៗ សុទ្ធតែជាគោលដៅនៃការរឹបអូសបន្ទាប់ពីកាត់ទោសរួច។

ដើម្បីជំរុញប្រសិទ្ធភាពនៃការរឹបអូសផលនៃបទល្មើស ក្រសួង-ស្ថាប័ននីមួយៗដែលទទួលខុសត្រូវស៊ើបអង្កេត ឬចោទប្រកាន់បទសម្អាតប្រាក់ ឬសំអាងនៃបទល្មើស ត្រូវបង្កើតគោលនយោបាយនិងនីតិវិធីផ្ទៃក្នុងសមស្រប ដែលនឹងជួយដល់ការអនុវត្តច្បាប់នៃការរឹបអូស កាន់តែមានប្រសិទ្ធភាព។

### ៧.១ ការពង្រឹងសមត្ថភាពស្ថាប័នទទួលខុសត្រូវក្នុងការរឹបអូសឧបករណ៍ និងផលនៃបទល្មើស

បទពិសោធន៍អន្តរជាតិ បានលើកឡើងថា ប្រព័ន្ធរឹបអូសទ្រព្យសម្បត្តិមួយមានប្រសិទ្ធភាពបំផុតគឺត្រូវអនុវត្តដោយអង្គភាពទទួលបន្ទុក ក្នុងការបំពេញការងាររឹបអូសទ្រព្យសម្បត្តិ ចាប់ពី ១/-ការតាមដាននិងកំណត់អត្តសញ្ញាណនៃផលនិងឧបករណ៍នៃបទល្មើស ២/-ការប្រមូលភស្តុតាង ដោយត្រូវកំណត់ឲ្យច្បាស់លាស់ពីការឃាត់ទុក ឬការទប់ស្កាត់ទ្រព្យសម្បត្តិនោះ និង៣/-ដំណើរការករណីរឹបអូសនេះតាមប្រព័ន្ធច្បាប់ ដើម្បីគ្រប់គ្រងនិងលក់ទ្រព្យសម្បត្តិដែលបានរឹបអូស។

អង្គភាពទាំងនេះត្រូវសហការជាមួយអង្គភាពស៊ើបអង្កេត និងស្ថាប័នអយ្យការ ដែលទទួលខុសត្រូវលើការស៊ើបអង្កេតនិងការចោទប្រកាន់សំអាងនៃបទល្មើសពាក់ព័ន្ធ ឲ្យមានប្រសិទ្ធភាព។ ដើម្បីសម្រេចការងារនេះបានជោគជ័យ អាជ្ញាធរត្រូវបែងចែកធនធាន ផ្តល់ការបណ្តុះបណ្តាល និងបង្កើតឲ្យមានគោលនយោបាយ និងក្របខ័ណ្ឌច្បាប់ ។

### ៧.១.១ ការកសាងសមត្ថភាពតាមរយៈការបណ្តុះបណ្តាល

ក្រុមការងារ ឬអង្គភាព ដែលទទួលខុសត្រូវក្នុងការរឹបអូសឧបករណ៍ និងផលនៃបទល្មើសត្រូវជ្រើសរើសសមាជិកមកទទួលការបណ្តុះបណ្តាលឲ្យបានពេញលេញ ពីឯកទេសនៃការរឹបអូស។ ប៉ុន្តែបច្ចុប្បន្ននេះ ការបណ្តុះបណ្តាលក្នុងប្រទេសមានការលំបាក ហើយមធ្យោបាយចម្បងនៃការបណ្តុះបណ្តាលជំនាញរឹបអូសនេះអាចធ្វើបានតាមរយៈការហ្វឹកហាត់ការងារ។ ហេតុនេះ អង្គភាពស៊ើបអង្កេត និងស្ថាប័នអយ្យការត្រូវជ្រើសរើសអ្នកស៊ើបអង្កេត និងព្រះរាជអាជ្ញាដែលមានបទពិសោធន៍ផ្នែកបទល្មើសហិរញ្ញវត្ថុមកបំពេញភារកិច្ចនេះ។

មន្ត្រីបច្ចេកទេសត្រូវទទួលការបណ្តុះបណ្តាលអំពីក្របខ័ណ្ឌច្បាប់ទាក់ទងការរឹបអូស ហើយការបណ្តុះបណ្តាលនេះត្រូវមាន គោលនយោបាយនិងរចនាសម្ព័ន្ធច្បាស់លាស់ ។

### ៧.១.២ អភិវឌ្ឍបុគ្គលិក និងអ្នកជំនាញ

ការអនុវត្តនៅក្នុងយុត្តាធិការជាច្រើនបានបង្ហាញថា ការប្រឹក្សាយោបល់ និងការគាំទ្រឯកទេសសម្រាប់ការរឹបអូសអាចធ្វើឡើងតាមរយៈ ការបង្កើតអង្គភាព ឬ ក្រុមការងារទទួលបន្ទុក នៅក្នុងស្ថាប័ននីមួយៗ និងពេលខ្លះ តាមរយៈការបង្កើតក្រុមការងារពិសេសអន្តរក្រសួង-ស្ថាប័ន។ អង្គភាពស៊ើបអង្កេត និងស្ថាប័នអយ្យការត្រូវដោះស្រាយឲ្យត្រូវតាមស្ថានភាពការងាររបស់ពួកគេ។

អាជ្ញាធរអនុវត្តច្បាប់ និងស្ថាប័នអយ្យការត្រូវបង្កើនធនធានបន្ថែមទៀត ដើម្បីអនុវត្តការរឹបអូសដោយមិនឲ្យប៉ះពាល់ដល់ការបំពេញមុខងារផ្សេងទៀតរបស់ខ្លួន។

## ៧.២ ការកំណត់អាទិភាពការរឹបអូសផលនៃបទល្មើស

### ៧.២.១ ការបង្កើតគោលនយោបាយ ឬយុទ្ធសាស្ត្រជាតិរឹបអូសសាច់ប្រាក់ឆ្លងដែនដែលធ្វើប្រតិវេទន៍ក្លែងបន្លំ

ក្របខ័ណ្ឌច្បាប់បានដាក់ឲ្យអនុវត្តការរាយការណ៍សាច់ប្រាក់ និងឧបករណ៍អាចជួញដូរបានឆ្លងដែន ហើយបានរកឃើញថាពុំមានការធ្វើប្រតិវេទន៍ ឬការធ្វើប្រតិវេទន៍ក្លែងបន្លំនៃសាច់ប្រាក់ឆ្លងដែនជាច្រើន។ អាជ្ញាធរអនុវត្តច្បាប់បានអនុវត្តយ៉ាងទូលំទូលាយនូវក្របខ័ណ្ឌច្បាប់ទាក់ទងជាមួយការមិនធ្វើប្រតិវេទន៍ ឬការធ្វើប្រតិវេទន៍ក្លែងបន្លំលើសាច់ប្រាក់ ឬឧបករណ៍អាចជួញដូរបានឆ្លងដែន ហើយការអនុវត្តនេះទទួលបានការវាយតម្លៃថា ប្រតិបត្តិតាមបានភាគច្រើន (Largely Compliant) នៅក្នុងរបាយការណ៍វាយតម្លៃអញ្ញមញ្ញ ឆ្នាំ២០១៧។ ប៉ុន្តែ ក្របខ័ណ្ឌច្បាប់នេះមិនទាន់ដំណើរការពេញលេញដូចការរំពឹងទុកពាក់ព័ន្ធការរឹបអូស ឬការចោទប្រកាន់បទសម្អាតប្រាក់នៅឡើយ។ អាជ្ញាធរអនុវត្តច្បាប់ត្រូវបង្កើតក្រុមការងារពិសេសមួយ ដែលមានសមាសភាពមកពី អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា អគ្គស្នងការដ្ឋាននគរបាលជាតិ អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អង្គភាពប្រឆាំងអំពើពុករលួយ (និងស្ថាប័នពាក់ព័ន្ធផ្សេងទៀត) ដើម្បីបង្កើតក្របខ័ណ្ឌច្បាប់ គោលនយោបាយ និងការពង្រឹងក្របខ័ណ្ឌផ្សេងៗ

ដែលអាចអនុវត្តបានចំពោះការរឹបអូសសាច់ប្រាក់ឆ្លងដែន ឬឧបករណ៍អាចជួញដូរបានឆ្លងដែន ដែលមិនបានធ្វើប្រតិវេទន៍ ឬបានធ្វើប្រតិវេទន៍ក្លែងបន្លំ។ ក្រុមការងារពិសេសត្រូវផ្តល់អនុសាសន៍ដល់ គ.ស.ហ ស្តីពីការកែលម្អការអនុវត្តក្របខ័ណ្ឌច្បាប់នេះឲ្យមានប្រសិទ្ធភាពសម្រាប់ការស្វែងរក ឃាត់ទុក និងការរឹបអូសសាច់ប្រាក់ និងឧបករណ៍អាចជួញដូរបានឆ្លងដែន ដែលមិនបានធ្វើប្រតិវេទន៍ ឬបានធ្វើប្រតិវេទន៍ក្លែងបន្លំទាំងនេះ។

**៧.២.២ ការបង្កើតគោលនយោបាយនិងយុទ្ធសាស្ត្រផ្ទៃក្នុងរបស់អាជ្ញាធរអនុវត្តច្បាប់ ដើម្បីរឹបអូសផលនៃបទល្មើស**

អ្នកស៊ើបអង្កេត និងស្ថាប័នអយ្យការត្រូវបង្កើតគោលនយោបាយផ្ទៃក្នុងសម្រាប់ដោះស្រាយបញ្ហាដូចជា៖ ១/-ការពិចារណាពីជម្រើសនៃការរឹបអូសដែលអ្នកស៊ើបអង្កេតសំអាងនៃបទល្មើសអាចធ្វើបាន ២/-ការចាត់វិធានការសមស្របតាមដំណាក់កាលនៅក្នុងដំណើការស៊ើបអង្កេតការសម្អាតប្រាក់ និងសំអាងនៃបទល្មើស ដើម្បីតាមដានផលនៃបទល្មើស ៣/-ការចាត់វិធានការសមស្របតាមដំណាក់កាលសម្រាប់ការបង្កក ឬឃាត់ទុកផលនៃបទល្មើស និងឧបករណ៍ប្រព្រឹត្តបទល្មើស ពេលរកឃើញក្នុងអំឡុងពេលនៃការស៊ើបអង្កេតលើបទសម្អាតប្រាក់ ឬសំអាងនៃបទល្មើស ៤/-អ្នកជំនាញស៊ើបអង្កេតការរឹបអូស ឬព្រះរាជអាជ្ញាត្រូវទំនាក់ទំនងគ្នាឲ្យបានទាន់ពេលវេលា ៥/-ព្រះរាជអាជ្ញាត្រូវគ្រប់គ្រងករណីរឹបអូសឲ្យបានត្រឹមត្រូវ និង៦/-ព្រះរាជអាជ្ញាចោទប្រកាន់សំអាងនៃបទល្មើស ព្រះរាជអាជ្ញាទទួលបន្ទុកការរឹបអូស និងអ្នកស៊ើបអង្កេតត្រូវទំនាក់ទំនងគ្នាឲ្យបានទាន់ពេលវេលា។

## ៨. កិច្ចសហប្រតិបត្តិការអន្តរជាតិ

ក្រោមទម្រង់ផ្សេងៗនៃបទល្មើសហិរញ្ញវត្ថុ ការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្មមានវិសាលភាពឆ្លងដែន។ ដូច្នេះ ការស្វែងរកនិងប្រមូលភស្តុតាងចំពោះករណី ស.ប.ហ.ភ ត្រូវមានជំនួយសហការពីអាជ្ញាធរអនុវត្តច្បាប់បរទេស។ យុទ្ធសាស្ត្រជាតិ ឆ្នាំ២០១៩-២០២៣ នឹងដោះស្រាយរាល់ឧបសគ្គទាំងឡាយ ដើម្បីឲ្យប្រទេសកម្ពុជាអាចស្វែងរក ទទួល និងផ្តល់ជំនួយអន្តរជាតិ ។

អាជ្ញាធរកណ្តាល ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងយុត្តិធម៌ មានតួនាទីទទួលសំណើចូលនិងចេញ និងសម្របសម្រួលជាមួយយុត្តាធិការបរទេសក្នុងការស៊ើបអង្កេត ឬចោទប្រកាន់។ អាជ្ញាធរកណ្តាលត្រូវតែបង្កើនធនធាន ដើម្បីចូលរួមជំរុញការងាររៀបចំសេចក្តីព្រាងច្បាប់ស្តីពីជំនួយផ្នែកច្បាប់ទៅវិញទៅមកក្នុងវិស័យព្រហ្មទណ្ឌ និងទទួលការបណ្តុះបណ្តាលស្តីពីតិចនិក និងនីតិវិធីក្នុងការផ្តល់ជំនួយផ្នែកច្បាប់ទៅវិញទៅមកក្នុងវិស័យព្រហ្មទណ្ឌ។

### ៨.១ កែលម្អក្របខ័ណ្ឌគតិយុត្ត ដើម្បីធ្វើកិច្ចសហប្រតិបត្តិការអន្តរជាតិ

ទោះបីជា ប្រទេសកម្ពុជាខិតខំប្រឹងប្រែងផ្តល់ជំនួយដល់បណ្តាប្រទេសដទៃទៀតក្នុងការប្រឆាំងការសម្អាតប្រាក់និងសំអាងនៃបទល្មើស និងហិរញ្ញប្បទានភេរវកម្ម ក៏ប្រទេសកម្ពុជានៅតែមិនទាន់ប្រើប្រាស់ជំនួយពីដៃគូសន្ធិសញ្ញារបស់ខ្លួនឲ្យអស់លទ្ធភាព ក្នុងការស្វែងរកបទល្មើសបែបនេះនៅក្នុងយុត្តាធិការរបស់ខ្លួនដែរ។ ប្រទេសកម្ពុជាជួបឧបសគ្គក្នុងការស្វែងរកជំនួយអន្តរជាតិ ដោយសារពុំទាន់មានច្បាប់ស្តីពីជំនួយផ្នែកច្បាប់ទៅវិញទៅមកក្នុងវិស័យព្រហ្មទណ្ឌ និងមិនទាន់មានធនធានគ្រប់គ្រាន់។ ដូច្នេះ អាជ្ញាធរត្រូវធានាថាក្របខ័ណ្ឌច្បាប់ត្រូវផ្តល់ជាមូលដ្ឋានគតិយុត្តដ៏រឹងមាំមួយ សម្រាប់ការផ្តល់ជំនួយផ្នែកច្បាប់ទៅវិញទៅមកក្នុងវិស័យព្រហ្មទណ្ឌ។

### ៨.២ សហប្រតិបត្តិការអន្តរជាតិ

អាជ្ញាធរកណ្តាលត្រូវបង្កើតនីតិវិធីអនុវត្តស្តង់ដា ក្នុងការដោះស្រាយសំណើចូលនិងចេញឲ្យមានប្រសិទ្ធភាព និងបញ្ចូលបញ្ញត្តិស្តីពីការផ្តល់ជំនួយដល់អ្នកស៊ើបអង្កេត និងព្រះរាជអាជ្ញា ដែលផ្តើម ឬឆ្លើយតបទៅនឹងសំណើជំនួយផ្នែកច្បាប់ទៅវិញទៅមកក្នុងវិស័យព្រហ្មទណ្ឌ។

អាជ្ញាធរកណ្តាលក៏ត្រូវបង្កើតប្រព័ន្ធគ្រប់គ្រងករណី ឬសំណុំរឿង (Case Management System) សម្រាប់តាមដាន និងកំណត់អាទិភាពលើសំណើជំនួយផ្នែកច្បាប់ទៅវិញទៅមកក្នុងវិស័យព្រហ្មទណ្ឌទាំងចូលនិងចេញ ដោយធានាថាការស្នើសុំនិងឆ្លើយតបសំណើទាំងនោះបានទាន់ពេលវេលា។ ប្រព័ន្ធនេះក៏ត្រូវរក្សាទុកស្ថិតិសំណើចូលនិងចេញ និងកត់ត្រាប្រសិទ្ធភាពនៃការស្នើសុំនិងឆ្លើយតបសំណើនីមួយៗ។

ប្រទេសកម្ពុជាត្រូវជំរុញការចែករំលែកព័ត៌មានក្រៅផ្លូវការរវាង ស.ហ.ក អាជ្ញាធរស៊ើបអង្កេត ស្ថាប័នអយ្យការ និងដៃគូបរទេសពាក់ព័ន្ធ។

## ៩. ការប្រឆាំងហិរញ្ញប្បទានភេរវកម្មនិងហិរញ្ញប្បទាននៃការរីកសាយភាយអាវុធមហាប្រល័យ

ក្នុងនាមសមាជិកអង្គការសហប្រជាជាតិ ប្រទេសកម្ពុជាមានកាតព្វកិច្ចអនុវត្តវិធានការទប់ស្កាត់ប្រឆាំងហិរញ្ញប្បទានភេរវកម្ម រួមមាន៖ ១/-ការបង្កកទ្រព្យសម្បត្តិរបស់ភេរវករដោយគ្មានបង្អង់ ស្របតាមសេចក្ដីសម្រេចចិត្តរបស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ (អ.ស.ប) លេខ ១២៦៧ (ពួកតាលីបង់ និង ISIL) ២/-ការបង្កើតនីតិវិធីសម្រាប់ចុះបញ្ជីនិងការបង្កកទ្រព្យសម្បត្តិភេរវករក្នុងស្រុក ស្របតាមសេចក្ដីសម្រេចចិត្តរបស់ក្រុមប្រឹក្សាសន្តិសុខ អ.ស.ប លេខ ១៣៧៣ និង៣/-ការអនុវត្តវិធានការទប់ស្កាត់តាមរយៈការរាយការណ៍ប្រតិបត្តិការហិរញ្ញវត្ថុ ដោយបុគ្គលរាយការណ៍ និងការបង្កកមូលនិធិរបស់ពួកសកម្មប្រយុទ្ធភេរវករបរទេស។ ប្រទេសកម្ពុជាមានក្របខ័ណ្ឌច្បាប់ក្នុងស្រុក ដែលអនុវត្តតាមសេចក្ដីសម្រេចចិត្តរបស់ក្រុមប្រឹក្សាសន្តិសុខ អ.ស.ប និងធានាថាវិធានការទាំងនោះ អនុវត្តបានត្រឹមត្រូវ។

### ៩.១ កែលម្អក្របខ័ណ្ឌគតិយុត្ត ដើម្បីប្រឆាំងហិរញ្ញប្បទានការរីកសាយភាយអាវុធមហាប្រល័យ

សេចក្ដីសម្រេចចិត្តរបស់ក្រុមប្រឹក្សាសន្តិសុខ អ.ស.ប ក៏បានណែនាំផងដែរអំពីតម្រូវការចាំបាច់សម្រាប់ប្រទេសជាសមាជិកអនុវត្តទណ្ឌកម្មហិរញ្ញវត្ថុមានគោលដៅ ដើម្បីប្រឆាំងការរីកសាយភាយអាវុធមហាប្រល័យ។ ប្រទេសកម្ពុជាមិនទាន់មានក្របខ័ណ្ឌច្បាប់សម្រាប់ការអនុវត្តវិធានការទាំងនោះនៅឡើយទេ។ ដូច្នេះ ការបង្កើតក្របខ័ណ្ឌច្បាប់ជាការងារអាទិភាពមួយដែលត្រូវរៀបចំឲ្យបានឆាប់រហ័ស។

អាជ្ញាធរអនុវត្តច្បាប់មានក្របខ័ណ្ឌច្បាប់គ្រប់គ្រាន់ និងទូលំទូលាយសម្រាប់ការស៊ើបអង្កេតហិរញ្ញប្បទានភេរវកម្ម និងបង្កកទ្រព្យសម្បត្តិប្រកបដោយប្រសិទ្ធភាព។ ស.ហ.ក និងអាជ្ញាធរអនុវត្តច្បាប់ប្រឆាំងហិរញ្ញប្បទានភេរវកម្ម បាននិងកំពុងអនុវត្តក្របខ័ណ្ឌច្បាប់ពាក់ព័ន្ធសេចក្ដីសម្រេចចិត្តរបស់ក្រុមប្រឹក្សាសន្តិសុខ អ.ស.ប លេខ១២៦៧ និង ១៣៧៣។ បច្ចុប្បន្ននេះ ប្រទេសកម្ពុជាពុំទាន់រកឃើញទ្រព្យសម្បត្តិណាដូចមានកំណត់ក្នុងសេចក្ដីសម្រេចចិត្តរបស់ក្រុមប្រឹក្សាសន្តិសុខ អ.ស.ប លេខ ១២៦៧ ឬសេចក្ដីសម្រេចចិត្តបន្តបន្ទាប់នៅឡើយទេ។

របាយការណ៍វាយតម្លៃអញ្ញមញ្ញឆ្នាំ២០១៧ និងមតិយោបល់របស់ភាគីពាក់ព័ន្ធការងារប្រឆាំង ស.ប.ហ.ភ បញ្ជាក់ថា ក្របខ័ណ្ឌច្បាប់ និងយន្តការ ដែលអនុវត្តចំពោះការដាក់ទណ្ឌកម្មហិរញ្ញវត្ថុគោលដៅប្រឆាំងនឹងហិរញ្ញប្បទានភេរវកម្មអាចឆ្លើយតបនឹងករណីហិរញ្ញប្បទានភេរវកម្ម ដែលរកឃើញនៅក្នុងប្រទេសកម្ពុជាប្រកបដោយប្រសិទ្ធភាព។ របាយការណ៍វាយតម្លៃអញ្ញមញ្ញឆ្នាំ២០១៧ កត់សម្គាល់នូវចំណុចខ្វះខាតមួយចំនួនតូចពាក់ព័ន្ធការអនុវត្តការដាក់ទណ្ឌកម្មហិរញ្ញវត្ថុគោលដៅប្រឆាំងហិរញ្ញប្បទានភេរវកម្មដែលត្រូវពិនិត្យឡើងវិញ និងដោះស្រាយដោយប្រុងប្រយ័ត្ន។

### ៩.២ សហការជាមួយវិស័យឯកជន ដើម្បីប្រឆាំងហិរញ្ញប្បទានការរីកសាយភាយអាវុធមហាប្រល័យ

លេខាធិការដ្ឋានគណៈកម្មាធិការជាតិប្រឆាំងភេរវកម្ម នាយកដ្ឋានប្រឆាំងភេរវកម្មនិងឧក្រិដ្ឋកម្មឆ្លងដែននៃអគ្គស្នងការដ្ឋាននគរបាលជាតិ ស.ហ.ក និងក្រសួង-ស្ថាប័នពាក់ព័ន្ធដទៃទៀត ត្រូវពិនិត្យឡើងវិញនូវនីតិវិធីនិងយន្តការនានាដែលចាំបាច់ ដើម្បីអនុវត្តក្របខ័ណ្ឌគតិយុត្តពាក់ព័ន្ធនឹងការផ្តល់ហិរញ្ញប្បទានការរីកសាយភាយអាវុធមហាប្រល័យ ក៏ដូចជាលើកយោបល់ជូន គ.ស.ហ ពីតម្រូវការធនធាន និងយន្តការដើម្បីអនុវត្តក្របខ័ណ្ឌនេះ។ ធនធាននិងយន្តការទាំងនោះត្រូវមានមុនការដាក់ឲ្យអនុវត្តក្របខ័ណ្ឌគតិយុត្តពាក់ព័ន្ធនឹងការផ្តល់ហិរញ្ញប្បទានការរីកសាយភាយអាវុធមហាប្រល័យ។

## ១០. ការគ្រប់គ្រងកម្មវិធីជាតិស្តីពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម

ផ្នែកទី១០ នៃយុទ្ធសាស្ត្រជាតិ ឆ្នាំ២០១៩-២០២៣ នឹងជួយដោះស្រាយបញ្ហាក្នុងការអនុវត្តប្រកបដោយប្រសិទ្ធភាពនូវកម្មវិធីជាតិស្តីពីការប្រឆាំង ស.ប.ហ.ភ ដែលមានភាពប្រទាក់ក្រឡាគ្នារវាងការអនុវត្តច្បាប់និងបទប្បញ្ញត្តិ ក្រសួង-ស្ថាប័នអនុវត្ត គោលនយោបាយ នីតិវិធី និងសេចក្តីណែនាំជាដើម។ ផ្នែកនេះ កំណត់ពីសកម្មភាពការងារសម្រាប់ធានាការអនុវត្តឲ្យបានសមស្របនូវយុទ្ធសាស្ត្រជាតិ ឆ្នាំ២០១៩-២០២៣ និងគោលដៅប្រឆាំង ស.ប.ហ.ភ ដែលមិនមាននៅក្នុងផ្នែកផ្សេងទៀតនៃយុទ្ធសាស្ត្រនេះ។

### ១០.១ ការតាមដានការអនុវត្តយុទ្ធសាស្ត្រជាតិស្តីពីការប្រឆាំង ស.ប.ហ.ភ

យុទ្ធសាស្ត្រជាតិ ឆ្នាំ២០១៩-២០២៣ នេះ ត្រូវមានយន្តការតាមដានការអនុវត្តផែនការសកម្មភាព ដើម្បីធានាថារាល់គោលបំណងជាយុទ្ធសាស្ត្រទាំងអស់អាចសម្រេចបានតាមកាលកំណត់។

#### ១០.១.១ ក្រុមការងារទទួលបន្ទុកតាមដានការអនុវត្ត

គ.ស.ហ ត្រូវបង្កើតក្រុមការងាររដ្ឋបាលដែលមានធនធានគ្រប់គ្រាន់ ដើម្បីបន្តតាមដានការអនុវត្តយុទ្ធសាស្ត្រជាតិនេះ និងរាយការណ៍លទ្ធផលជូន គ.ស.ហ។ គ.ស.ហ និងមន្ត្រីជាន់ខ្ពស់ត្រូវដោះស្រាយរាល់បញ្ហាពាក់ព័ន្ធនឹងការអនុវត្តផែនការសកម្មភាពជាអាទិភាព។

#### ១០.១.២ កម្មវិធីប្រជុំរបស់ គ.ស.ហ

គ.ស.ហ ត្រូវរៀបចំកម្មវិធីប្រជុំប្រចាំគ្រា ដើម្បីពិនិត្យរបាយការណ៍ពីក្រុមការងារទទួលបន្ទុកតាមដានការអនុវត្ត និងពិភាក្សាដោះស្រាយបញ្ហាដែលកើតឡើង ជាពិសេសបញ្ហាពាក់ព័ន្ធនឹងការអនុវត្តផែនការសកម្មភាពជាអាទិភាព។

### ១០.២ ថវិកាគាំទ្រការអនុវត្តយុទ្ធសាស្ត្រជាតិ ឆ្នាំ២០១៩-២០២៣

សកម្មភាពជាច្រើនត្រូវការបុគ្គលិក និងធនធានបន្ថែមផ្សេងទៀតដែលក្រសួង-ស្ថាប័ន ដែលមានតួនាទីសំខាន់ៗក្នុងការអនុវត្តកម្មវិធីប្រឆាំងស.ប.ហ.ភ។ សកម្មភាពនីមួយៗនឹងបន្ថែមចំណាយរបស់រាជរដ្ឋាភិបាល។

អាជ្ញាធរអនុវត្តច្បាប់ អាជ្ញាធរត្រួតពិនិត្យវិស័យហិរញ្ញវត្ថុ និងក្រសួង-ស្ថាប័ន ដែលមានតួនាទីសំខាន់ក្នុងការអនុវត្តកម្មវិធីជាតិស្តីពីការប្រឆាំង ស.ប.ហ.ភ ត្រូវការបន្ថែមបុគ្គលិកនិងធនធានផ្សេងទៀតសម្រាប់អនុវត្តផែនការសកម្មភាពនៃយុទ្ធសាស្ត្រជាតិ ឆ្នាំ២០១៩-២០២៣ ដោយប្រើប្រាស់ថវិកាជាតិ។ បន្ថែមលើយន្តការស្នើសុំថវិការបស់ក្រសួង-ស្ថាប័ននីមួយៗដែលមានស្រាប់ គ.ស.ហ ត្រូវបង្កើតយន្តការបន្ថែមផ្នែកហិរញ្ញវត្ថុ ដើម្បីបង្កើនថវិកាគាំទ្រការអនុវត្តសកម្មភាពនៅក្នុងយុទ្ធសាស្ត្រជាតិ ឆ្នាំ២០១៩-២០២៣ សម្រាប់រយៈពេល ៥ឆ្នាំ ដោយបែងចែកធនធាន រវាងក្រសួង-ស្ថាប័ននានាឲ្យបានត្រឹមត្រូវល្អក្នុងការសម្រេចនូវគោលបំណងនៃយុទ្ធសាស្ត្រជាតិនេះ។

ក្រសួង-ស្ថាប័ននីមួយៗត្រូវរាយការណ៍ជូន គ.ស.ហ ពេលត្រូវការមូលនិធិ សម្រាប់ផែនការដែលមានអាទិភាពខ្ពស់ ដែលមិនអាចទទួលបានតាមរយៈដំណើការថវិកាធម្មតា។

# ផែនការសកម្មភាព

## យុទ្ធសាស្ត្រជាតិស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម
## ឆ្នាំ២០១៩-២០២៣

**កំណត់សម្គាល់ពីកម្រិតអាទិភាព ៖**

- ១ : អាទិភាពខ្ពស់ (ចុងឆ្នាំ២០១៩)
- ២ : អាទិភាពមធ្យម (ចុងឆ្នាំ២០២១)
- ៣ : អាទិភាពទាប (ចុងឆ្នាំ២០២៣)

| គោលបំណង | សកម្មភាព | អាទិភាព | ពេលវេលា | ក្រសួង-ស្ថាប័នដឹកនាំ | ក្រសួង-ស្ថាប័នពាក់ព័ន្ធ |
|---|---|---|---|---|---|
| **១.ការយល់ដឹងនិងការកាត់បន្ថយហានិភ័យសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ( ស.ប.ហ.ភ )** | | | | | |
| **១.១** | **កាត់បន្ថយហានិភ័យ ស.ប.ហ.ភ តាមវិស័យនិងស្ថាប័ន** | | | | |
| **១.១.១** | **កំណត់រកហានិភ័យតាមវិស័យមួយចំនួន** | | | | |
| ១.១.១.១ | វាយតម្លៃហានិភ័យវិស័យអង្គការមិនស្វែងរកប្រាក់ចំណេញ | ១ | កក្កដា-ធ្នូ ២០១៩ | -ក្រសួងមហាផ្ទៃ(នាយកដ្ឋានកិច្ចការសមាគមនិងគណបក្សនយោបាយ)<br>-ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ | -ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ<br>-ធនាគារជាតិនៃកម្ពុជា |
| ១.១.១.២ | វាយតម្លៃហានិភ័យឈ្មួញជួញដូរលោហធាតុនិងត្បូងថ្មមានតម្លៃ | ៣ | មករា - ធ្នូ ២០២២ | -ក្រសួងពាណិជ្ជកម្ម<br>-ធនាគារជាតិនៃកម្ពុជា | - អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា<br>- អគ្គនាយកដ្ឋានពន្ធដារ |

| គោលបំណង | សកម្មភាព | អាទិភាព | ពេលវេលា | ក្រសួង-ស្ថាប័នដឹកនាំ | ក្រសួង-ស្ថាប័នពាក់ព័ន្ធ |
|---|---|---|---|---|---|
| ១.១.១.៣ | វាយតម្លៃហានិភ័យវិស័យអចលនទ្រព្យ | ១ | មករា-ធ្នូ ២០១៩ | -ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (វិស័យអចលនទ្រព្យ) | - ក្រសួងពាណិជ្ជកម្ម<br>- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ |
| ១.១.១.៤ | វាយតម្លៃហានិភ័យវិស័យកាស៊ីណូ | ១ | មករា-ធ្នូ ២០១៩ | -ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (វិស័យកាស៊ីណូ) | -ក្រសួងពាណិជ្ជកម្ម |
| ១.១.២ | ពង្រឹងការយល់ដឹងអំពីហានិភ័យរបស់នីតិបុគ្គលនិងកិច្ចសម្របសម្រួលផ្នែកច្បាប់ | | | | |
| ១.១.២.១ | វាយតម្លៃហានិភ័យ ស.ប.ហ.ភ ចំពោះនីតិបុគ្គល | ១ | មករា-ធ្នូ ២០១៩ | - ក្រសួងពាណិជ្ជកម្ម<br>- អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា | - បញ្ញត្តិករទាំងអស់<br>- អគ្គនាយកដ្ឋានពន្ធដារ<br>- ក្រុមប្រឹក្សាជាតិគណនេយ្យ<br>- គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា |
| ១.១.២.២ | វាយតម្លៃហានិភ័យ ស.ប.ហ.ភ ចំពោះកិច្ចសម្របសម្រួលផ្នែកច្បាប់ (ទាំងក្នុងស្រុកនិងបរទេស) | ១ | មករា-ធ្នូ ២០១៩ | -ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (វិស័យបរធនបាល) | - អគ្គនាយកដ្ឋានពន្ធដារ<br>- ក្រុមប្រឹក្សាជាតិគណនេយ្យ<br>- គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា |
| ១.១.២.៣ | បង្កើនការយល់ដឹងពីហានិភ័យ ស.ប.ហ.ភ. | ១ | អនុវត្តជាប្រចាំ | - គណៈកម្មាធិការសម្របសម្រួលថ្នាក់ជាតិប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម | -អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា |
| ១.១.២.៤ | ផ្សព្វផ្សាយហានិភ័យរកឃើញក្នុងរបាយការណ៍ការវាយតម្លៃហានិភ័យថ្នាក់ជាតិស្តីពី ស.ប.ហ.ភ ជូនក្រសួង-ស្ថាប័ន។ | ១ | ភ្លាមៗ | - គណៈកម្មាធិការសម្របសម្រួលថ្នាក់ជាតិប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម | -អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា |

| គោលបំណង | សកម្មភាព | អាទិភាព | ពេលវេលា | ក្រសួង-ស្ថាប័នដឹកនាំ | ក្រសួង-ស្ថាប័នពាក់ព័ន្ធ |
|---|---|---|---|---|---|
| ១.១.២.៥ | ចែករំលែករបាយការណ៍សង្ខេបការវាយតម្លៃហានិភ័យថ្នាក់ជាតិស្តីពី ស.ប.ហ.ភ ដល់បុគ្គលរាយការណ៍និងសាធារណជន | ១ | ភ្លាមៗ | - គណៈកម្មាធិការសម្របសម្រួលថ្នាក់ជាតិប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម | -អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា |
| ១.២ | កាត់បន្ថយបទល្មើសហិរញ្ញវត្ថុដែលកើតឡើងពីលំហូរសាច់ប្រាក់ចេញ-ចូលខុសច្បាប់ | | | | |
| ១.២.១ | វាយតម្លៃហានិភ័យ ស.ប.ហ.ភ ទាក់ទងនឹងការសម្អាតប្រាក់ជាទម្រង់ពាណិជ្ជកម្ម | ២ | មិថុនា-ធ្នូ ២០២១ | - អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា | - ក្រសួងពាណិជ្ជកម្ម (កាំកុងត្រូល)<br>- អគ្គនាយកដ្ឋានពន្ធដារ |
| ១.២.២ | វាយតម្លៃហានិភ័យ ស.ប.ហ.ភ ទាក់ទងការរត់ពន្ធសាច់ប្រាក់ | ២ | មិថុនា-ធ្នូ ២០២១ | - អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា | - ធនាគារជាតិនៃកម្ពុជា |
| **២.វិធានការទប់ស្កាត់និងការត្រួតពិនិត្យបុគ្គលរាយការណ៍** | | | | | |
| ២.១ | កែលម្អការអនុវត្តវិធានការប្រឆាំង ស.ប.ហ.ភ របស់បុគ្គលរាយការណ៍និងតាមវិស័យ | | | | |
| ២.១.១ | កែលម្អក្របខ័ណ្ឌច្បាប់ទាក់ទងវិធានការទប់ស្កាត់សម្រាប់ការប្រឆាំង ស.ប.ហ.ភ | | | | |
| ២.១.១.១ | វិសោធនកម្មច្បាប់និងប្រកាសស្តីពីការប្រឆាំង ស.ប.ហ.ភ ដើម្បីបំពេញគ្រប់តម្រូវការនៃការរាយការណ៍ប្រតិបត្តិការនិងការយកចិត្តទុកដាក់ស្គាល់អតិថិជន | ១ | មករា-ធ្នូ ២០១៩ | - ក្រុមការងារបច្ចេកទេសអន្តរក្រសួងប្រឆាំងការសម្អាត ប្រាក់និងហិរញ្ញប្បទានភេរវកម្ម (ផ្នែកច្បាប់) | |
| ២.១.១.២ | ចេញបទប្បញ្ញត្តិឬប្រកាសតាមការចាំបាច់ដើម្បីផ្តល់ការណែនាំបន្ថែមពីតម្រូវការយកចិត្តទុកដាក់ស្គាល់អតិថិជនចំពោះបុគ្គលរាយការណ៍ ឬ | ២ | មករា-ធ្នូ ២០២០ | - ក្រុមការងារអន្តរក្រសួងប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម (ផ្នែកច្បាប់) | |

| គោលបំណង | សកម្មភាព | អាទិភាព | ពេលវេលា | ក្រសួង-ស្ថាប័នដឹកនាំ | ក្រសួង-ស្ថាប័នពាក់ព័ន្ធ |
|---|---|---|---|---|---|
| | តាមផ្នែកផ្សេងៗ | | | | |
| ២.១.២ | បង្កើនការយល់ដឹងអំពីការប្រឆាំង ស.ប.ហ.ភ ចំពោះវិស័យហិរញ្ញវត្ថុនិងមុខរបរនិងវិជ្ជាជីវៈមិនមែនហិរញ្ញវត្ថុ (ជាពិសេសការទទួលខុសត្រូវរបស់បុគ្គលរាយការណ៍ ប៉ុន្តែអាជ្ញាធរត្រួតពិនិត្យត្រូវជួយផ្តល់សេចក្តីណែនាំនិងយោបល់ត្រលប់) | | | | |
| ២.១.២.១ | ចេញសេចក្តីណែនាំនិងយោបល់ត្រលប់លើការត្រួតពិនិត្យនិងការអនុវត្តវិធានការប្រឆាំង ស.ប.ហ.ភ | ២ | មករា-ធ្នូ ២០២០ | -អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា | -គ្រប់ភាគីពាក់ព័ន្ធរួមទាំងបុគ្គលរាយការណ៍ |
| ២.១.២.២ | អាជ្ញាធរត្រួតពិនិត្យតាមវិស័យ និង ស.ហ.ភ ត្រូវបង្កើតវេទិកា ឬយន្តការសម្រាប់ទំនាក់ទំនងជាប្រចាំជាមួយបុគ្គលរាយការណ៍ ដើម្បីធ្វើបច្ចុប្បន្នភាពការយល់ដឹងរបស់ពួកគេពីការវិវឌ្ឍន៍ថ្មីៗនៃ ស.ប.ហ.ភ ហានិភ័យ និងនិន្នាការនិងកាតព្វកិច្ចប្រឆាំង ស.ប.ហ.ភ | ១ | មិថុនា-ធ្នូ២០១៩ | -អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា<br>-អាជ្ញាធរត្រួតពិនិត្យតាមវិស័យទាំងអស់ | -បុគ្គលរាយការណ៍និងវិស័យពាក់ព័ន្ធនានា |
| ២.២ | កែលម្អប្រព័ន្ធត្រួតពិនិត្យលើហានិភ័យ | | | | |
| ២.២.១ | ធានាឲ្យមានការត្រួតពិនិត្យការចូលទៅកាន់ទីផ្សារឲ្យបានត្រឹមត្រូវ | | | | |
| ២.២.១.១ | អនុវត្តការត្រួតពិនិត្យការចូលទៅកាន់ទីផ្សាររួមទាំងការធ្វើតេស្តលើភាពសមស្រប និងត្រឹមត្រូវចំពោះអាជីវករប្តូរប្រាក់ | ១ | មីនា ២០១៩ -<br>មីនា២០២០ | -ធនាគារជាតិនៃកម្ពុជា | - ក្រសួងពាណិជ្ជកម្ម |

| គោលបំណង | សកម្មភាព | អាទិភាព | ពេលវេលា | ក្រសួង-ស្ថាប័នដឹកនាំ | ក្រសួង-ស្ថាប័នពាក់ព័ន្ធ |
|---|---|---|---|---|---|
| ២.២.១.២ | អនុវត្តការត្រួតពិនិត្យការចូលទៅកាន់ទីផ្សាររួមទាំងការធ្វើតេស្តលើភាពសមស្រប និងត្រឹមត្រូវចំពោះកាស៊ីណូ | ១ | មករា-ធ្នូ ២០១៩ | - ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (វិស័យកាស៊ីណូ) | - ក្រសួងពាណិជ្ជកម្ម |
| ២.២.១.៣ | អនុវត្តការត្រួតពិនិត្យការចូលទៅកាន់ទីផ្សាររួមទាំងការធ្វើតេស្តលើភាពសមស្រប និងត្រឹមត្រូវចំពោះវិស័យអចលនទ្រព្យ | ១ | មករា-ធ្នូ ២០១៩ | - ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (វិស័យអចលនទ្រព្យ) | - ក្រសួងពាណិជ្ជកម្ម |
| ២.២.១.៤ | អនុវត្តការត្រួតពិនិត្យការចូលទៅកាន់ទីផ្សាររួមទាំងការធ្វើតេស្តលើភាពសមស្រប និងត្រឹមត្រូវចំពោះវិស័យផ្សេងៗ | ២ | មករា - ធ្នូ ២០២១ | គ្រប់អាជ្ញាធរពាក់ព័ន្ធ | |
| ២.២.២ | ការធានាការត្រួតពិនិត្យផ្អែកលើមូលដ្ឋានវេយិទភាពហានិភ័យលើគ្រប់វិស័យ | | | | |
| ២.២.២.១ | រៀបចំផែនការសម្រាប់អនុវត្តការត្រួតពិនិត្យការប្រឆាំង ស.ប.ហ.ភ ផ្អែកលើហានិភ័យសម្រាប់គ្រប់វិស័យ ចាប់ពីវិស័យដែលមានហានិភ័យខ្ពស់ | ១ | មករា-ធ្នូ ២០១៩ | -អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា | -អាជ្ញាធរត្រួតពិនិត្យតាមវិស័យទាំងអស់ |
| ២.២.២.២ | រៀបចំផែនការសម្រាប់អនុវត្តការត្រួតពិនិត្យការប្រឆាំង ស.ប.ហ.ភ ផ្អែកលើហានិភ័យសម្រាប់វិស័យកាស៊ីណូ | ១ | មករា-ធ្នូ ២០១៩ | - ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (វិស័យកាស៊ីណូ)<br>-អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា | |
| ២.២.២.៣ | រៀបចំផែនការសម្រាប់អនុវត្តការត្រួតពិនិត្យការប្រឆាំង ស.ប.ហ.ភ ផ្អែកលើហានិភ័យសម្រាប់វិស័យអចលនទ្រព្យ | ១ | មករា-ធ្នូ ២០១៩ | - ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (វិស័យអចលនទ្រព្យ)<br>-អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា | |

| គោលបំណង | សកម្មភាព | អាទិភាព | ពេលវេលា | ក្រសួង-ស្ថាប័នដឹកនាំ | ក្រសួង-ស្ថាប័នពាក់ព័ន្ធ |
|---|---|---|---|---|---|
| ២.២.២.៤ | រៀបចំផែនការសម្រាប់អនុវត្តការត្រួតពិនិត្យការប្រឆាំង ស.ប.ហ.ភ ផ្អែកលើហានិភ័យសម្រាប់វិស័យផ្សេងទៀត | ២ | មករា-ធ្នូ ២០២០ | -អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា | -អាជ្ញាធរត្រួតពិនិត្យតាមវិស័យទាំងអស់ |
| ២.២.៣ | កែលម្អការត្រួតពិនិត្យការប្រឆាំង ស.ប.ហ.ភ ផ្អែកលើហានិភ័យសម្រាប់វិស័យធនាគារ | | | | |
| ២.២.៣.១ | បង្កើតប្រព័ន្ធត្រួតពិនិត្យលើឯកសារដើម្បីវាយតម្លៃហានិភ័យស.ប.ហ.ភ របស់ធនាគារ | ១ | ភ្លាមៗ | -អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា | |
| ២.២.៣.២ | អនុវត្តប្រព័ន្ធត្រួតពិនិត្យលើឯកសារសម្រាប់វិស័យធនាគារ | ១ | ភ្លាមៗ | -អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា | |
| ២.២.៣.៣ | កែលម្អនីតិវិធីត្រួតពិនិត្យដល់ទីកន្លែងសម្រាប់ការត្រួតពិនិត្យដល់ទីកន្លែង | ១ | មករា -មីនា ២០១៩ | - អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា | -ធនាគារជាតិនៃកម្ពុជា |
| ២.២.៣.៤ | បង្កើតកាលវិភាគត្រួតពិនិត្យផ្អែកលើហានិភ័យនិងចាប់ផ្តើមការត្រួតពិនិត្យដល់ទីកន្លែង | ១ | មករា-ធ្នូ ២០១៩ | - ធនាគារជាតិនៃកម្ពុជា<br>-អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា | |
| ២.២.៣.៥ | កែសម្រួលកម្មវិធីដាក់ទណ្ឌកម្ម ចំពោះបុគ្គលរាយការណ៍ដែលមិនប្រតិបត្តិតាម | ២ | មករា-ធ្នូ២០២០ | -អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា<br>-អាជ្ញាធរត្រួតពិនិត្យតាមវិស័យទាំងអស់ | -គ្រប់ភាគីពាក់ព័ន្ធរួមទាំងបុគ្គលរាយការណ៍ |

| គោលបំណង | សកម្មភាព | អាទិភាព | ពេលវេលា | ក្រសួង-ស្ថាប័នដឹកនាំ | ក្រសួង-ស្ថាប័នពាក់ព័ន្ធ |
|---|---|---|---|---|---|
| **៣.ការបង្កើនតម្លាភាពស្ថាប័ន** | | | | | |
| ៣.១ | បង្កើតក្របខ័ណ្ឌគោលនយោបាយអំពីអត្ថគាហកៈសម្រាប់គ្រប់ភាគីទាំងអស់ | | | | |
| ៣.១.១ | ផ្តល់ការបណ្តុះបណ្តាលដល់ក្រសួងពាណិជ្ជកម្ម និងភ្នាក់ងារពាក់ព័ន្ធអំពីការប្រមូល ឬកាន់កាប់ព័ត៌មានរបស់អត្ថគាហកៈទាក់ទងនឹងទស្សនទាននៃអត្ថគាហកៈនិងក្របខ័ណ្ឌច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម | ២ | មករា ២០២០ - ធ្នូ ២០២១ | - អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា | -បញ្ញត្តិករទាំងអស់ |
| ៣.១.២ | រៀបចំការវិភាគ GAP ពីភាពគ្រប់គ្រាន់ត្រឹមត្រូវនិងបច្ចុប្បន្នកម្មនៃព័ត៌មានអត្ថគាហកៈ | ២ | មករា-ធ្នូ២០២១ | - ក្រសួងពាណិជ្ជកម្ម<br>- អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា<br>- បញ្ញត្តិករទាំងអស់ | |
| ៣.១.៣ | បង្កើតក្របខ័ណ្ឌគោលនយោបាយពីព័ត៌មានរបស់អត្ថគាហកៈឲ្យបានច្បាស់លាស់ដែលធានាចាប់យកព័ត៌មានអត្ថគាហកៈរបស់និតិបុគ្គលនិងកិច្ចសម្របសម្រួលផ្លូវច្បាប់តាមរយៈច្បាប់ស្តីពីស.ប.ហ.ភច្បាប់ទាក់ទងសាជីវកម្ម និងផ្សេងទៀត | ២ | មករា ២០២២-ធ្នូ ២០២៣ | - ក្រសួងពាណិជ្ជកម្ម<br>- អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា<br>-បញ្ញត្តិករទាំងអស់ | |

| គោលបំណង | សកម្មភាព | អាទិភាព | ពេលវេលា | ក្រសួង-ស្ថាប័នដឹកនាំ | ក្រសួង-ស្ថាប័នពាក់ព័ន្ធ |
|---|---|---|---|---|---|
| ៣.២ | បង្កើនគុណភាពនិងភាពសំបូរបែបនៃព័ត៌មានរបស់អត្ថគាហកៈ | | | | |
| ៣.២.១ | បញ្ញត្តិករ ស.ប.ហ.ភ ត្រូវវាយតម្លៃពីគុណភាពនៃព័ត៌មានរបស់អត្ថគាហកៈប្រមូលបានដោយបុគ្គលរាយការណ៍តាមរយៈការយកចិត្តទុកដាក់ស្គាល់អតិថិជន | ២ | មករា ២០២០ - ធ្នូ ២០២១ | - អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា<br>-បញ្ញត្តិករទាំងអស់ | |
| ៣.២.២ | ពិនិត្យឡើងវិញពីការប្រើប្រាស់មូលបត្រស្អិតក្នុងទ្រង់ទ្រាយគាហកៈនិងពិចារណាពីការលុបបំបាត់ចោលមូលបត្រស្អិតក្នុងទ្រង់ទ្រាយគាហកៈនេះឬក៏មានយន្តការណាដើម្បីទប់ស្កាត់ការប្រើប្រាស់ខុស | ៣ | មករា-ធ្នូ ២០២៣ | - ក្រសួងពាណិជ្ជកម្ម<br>- គណៈកម្មាធិការសម្របសម្រួលថ្នាក់ជាតិប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម | - អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា<br>-បញ្ញត្តិករទាំងអស់ |
| **៤. ការប្រមូល ការវិភាគ និងការបញ្ជូនព័ត៌មានស៊ើបការណ៍ហិរញ្ញវត្ថុដែលមានសារៈប្រយោជន៍** | | | | | |
| ៤.១ | ពង្រឹងសមត្ថភាពរបស់ស.ហ.ក | | | | |
| ៤.១.១ | បង្កើនធនធានការិយាល័យវិភាគរបស់ ស.ហ.ក ជាបណ្តើរៗឲ្យបាន ៣០រូប ក្នុងរយៈពេល ៥ឆ្នាំ ដើម្បីអនុវត្តការងារឲ្យមានប្រសិទ្ធភាព | ១ | មករា ២០១៩-ធ្នូ ២០២៣ | - អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា | |
| ៤.១.២ | បំពាក់ឧបករណ៍បច្ចេកវិទ្យាព័ត៌មានបន្ថែមដើម្បីពង្រឹងមុខងារវិភាគ ការគ្រប់គ្រងទិន្នន័យនិង | ១ | មករា-មីនា ២០១៩ | - អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា | |

| គោលបំណង | សកម្មភាព | អាទិភាព | ពេលវេលា | ក្រសួង-ស្ថាប័នដឹកនាំ | ក្រសួង-ស្ថាប័នពាក់ព័ន្ធ |
|---|---|---|---|---|---|
| | ការរៀបចំរបាយការណ៍ស៊ើបការណ៍ហិរញ្ញវត្ថុរបស់ ស.ហ.ក បញ្ជូនទៅអាជ្ញាធរមានសមត្ថកិច្ចនិងភាគីពាក់ព័ន្ធ | | | | |
| ៤.១.៣ | ស.ហ.ក ចុះអនុស្សរណៈយោគយល់ដើម្បីទទួលបានទិន្នន័យដោយផ្ទាល់ពីរដ្ឋាភិបាល ដើម្បីជួយដល់ការវិភាគហិរញ្ញវត្ថុ ហើយគួរមានឧបករណ៍វិភាគបន្ថែមទៀត ដើម្បីជួយដល់ការងារវិភាគនិងការបញ្ជូនរបាយការណ៍ស៊ើបការណ៍ហិរញ្ញវត្ថុ | ២ | មករា ២០២០-កក្កដា ២០២១ | - អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា | |
| ៤.១.៤ | បណ្តុះបណ្តាលមន្ត្រី ស.ហ.ក ពីរបៀបវិភាគហិរញ្ញវត្ថុនិងអនុវត្តការងារជាមួយភាគីសំខាន់ៗក្នុងការប្រឆាំង ស.ប.ហ.ភ ឲ្យមានប្រសិទ្ធភាព | ១ | ភ្លាមៗ | - អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា | |
| ៤.១.៥ | បង្កើនសមត្ថភាពមន្ត្រី ស.ហ.ក ដើម្បីបង្កើតផលិតផលវិភាគជាយុទ្ធសាស្ត្រពីការប្រឆាំងស.ប.ហ.ភ | ២ | មករា-ធ្នូ ២០២០ | - អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា | |
| ៤.១.៦ | បង្កើតការផ្សព្វផ្សាយពីនិន្នាការនិងគំរូសិក្សា (Typology) ស.ប.ហ.ភ ដោយចេញផ្សាយរបាយការណ៍ វិភាគ យុទ្ធសាស្ត្រ សម្រាប់រដ្ឋាភិបាល វិស័យឯកជន និងសាធារណៈជន | ២ | មករា-ធ្នូ ២០២១ | - អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា | |

| គោលបំណង | សកម្មភាព | អាទិភាព | ពេលវេលា | ក្រសួង-ស្ថាប័នដឹកនាំ | ក្រសួង-ស្ថាប័នពាក់ព័ន្ធ |
|---|---|---|---|---|---|
| ៤.២ | ពង្រឹងសមត្ថភាពមន្ត្រី ស.ហ.ក ដើម្បីគាំទ្រដល់សកម្មភាពអនុវត្តច្បាប់ប្រឆាំង ស.ប.ហ.ភ | | | | |
| ៤.២.១ | បង្កើនការយល់ដឹងរបស់ ស.ហ.ក ពីតម្រូវការនៃការអនុវត្តច្បាប់ | | | | |
| ៤.២.១.១ | បង្កើតផលិតផលស៊ើបការណ៍ចំពោះវិស័យដែលមានហានិភ័យ ស.ប.ហ.ភ ខ្ពស់មានក្នុងរបាយការណ៍វាយតម្លៃហានិភ័យថ្នាក់ជាតិ | ១ | ភ្លាមៗ | - អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា | |
| ៤.២.១.២ | បង្កើតនីតិវិធីប្រតិបត្តិការស្តង់ដាឆ្លើយតបទៅនឹងសំណើសុំ និងដាក់សំណើសុំព័ត៌មានពីអន្តរជាតិតាមរយៈក្រុម Egmont | ១ | ភ្លាមៗ | - អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា | |
| ៤.២.១.៣ | ស.ហ.ក ត្រូវបញ្ចប់អនុស្សរណៈយោគយល់ស្តីពីការផ្លាស់ប្តូរព័ត៌មានហិរញ្ញវត្ថុជាមួយអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុបរទេសសំខាន់ៗបន្ថែមទៀត | ២ | មករា ២០២០-ធ្នូ ២០២២ | - អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា | |

| គោលបំណង | សកម្មភាព | អាទិភាព | ពេលវេលា | ក្រសួង-ស្ថាប័នដឹកនាំ | ក្រសួង-ស្ថាប័នពាក់ព័ន្ធ |
|---|---|---|---|---|---|
| ៤.២.២ | បង្កើនកិច្ចសហប្រតិបត្តិការរវាង ស.ហ.ក និងអាជ្ញាធរអនុវត្តច្បាប់ | | | | |
| ៤.២.២.១ | បង្កើតក្រុមការងារអនុវត្តច្បាប់ ដើម្បីជំរុញប្រតិបត្តិការរវាង ស.ហ.ក និង ដៃគូក្នុងស្រុកនីមួយៗឲ្យមានប្រសិទ្ធភាពរួមមានៈ អគ្គស្នងការដ្ឋាននគរបាលជាតិ ក្រសួងយុត្តិធម៌ អង្គភាពប្រឆាំងអំពើពុករលួយ អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ លេខាធិការដ្ឋានគណៈកម្មាធិការជាតិប្រឆាំងភេរវកម្ម ជាដើម | ៣ | មករា-ធ្នូ២០២៣ | - អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា | -អាជ្ញាធរអនុវត្តច្បាប់ទាំងអស់ |
| ៤.២.២.២ | ជំរុញប្រសិទ្ធភាពនៃការផ្តល់យោបល់ត្រលប់ទៅអាជ្ញាធរអនុវត្តច្បាប់ចំពោះផលិតផលស៊ើបការណ៍របស់ ស.ហ.ក និងអនុវត្តនីតិវិធីប្រតិបត្តិការ ស្តង់ដាសម្រាប់អាជ្ញាធរអនុវត្តច្បាប់ស្នើសុំទៅ ស.ហ.ក | ១ | មករា-មីនា ២០១៩ | - អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា | |
| ៤.២.២.៣ | បង្កើតនីតិវិធីប្រតិបត្តិការស្តង់ដាណែនាំអ្នកវិភាគឲ្យរៀបចំរបាយការណ៍ស៊ើបការណ៍ហិរញ្ញវត្ថុតាមតម្រូវការរបស់អាជ្ញាធរអនុវត្តច្បាប់ | ១ | ភ្លាមៗ | - អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា | |

| គោលបំណង | សកម្មភាព | អាទិភាព | ពេលវេលា | ក្រសួង-ស្ថាប័នដឹកនាំ | ក្រសួង-ស្ថាប័នពាក់ព័ន្ធ |
|---|---|---|---|---|---|
| ៤.២.៣ | បង្កើនការប្រើប្រាស់ព័ត៌មានស៊ើបការណ៍ហិរញ្ញវត្ថុ | | | | |
| ៤.២.៣.១ | បង្កើនការបញ្ជូនព័ត៌មានស៊ើបការណ៍របស់ ស.ហ.ក៖ បង្កើនរបាយការណ៍ស៊ើបការណ៍ហិរញ្ញវត្ថុ ពាក់ព័ន្ធនឹងសំអាងនៃបទល្មើសដែលមានហានិភ័យខ្ពស់ឲ្យបាន១៥ភាគរយក្នុងមួយឆ្នាំក្នុងរយៈពេលយុទ្ធសាស្ត្រជាតិ ឆ្នាំ២០១៩-២០២៣ | ១ | ភ្លាមៗ | - អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា | |
| **៥.ប្រសិទ្ធភាពនៃការស៊ើបអង្កេតការសម្អាតប្រាក់និងសំអាងនៃបទល្មើស** | | | | | |
| ៥.១ | កសាងធនធាននិងពង្រឹងសមត្ថភាពដល់ភ្នាក់ងារស៊ើបអង្កេតដែលទទួលខុសត្រូវការស៊ើបអង្កេតការសម្អាតប្រាក់ និងសំអាងបទល្មើស (អគ្គស្នងការដ្ឋាននគរបាលជាតិ, អគ្គនាយកដ្ឋានពន្ធដារ, អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា,អង្គភាពប្រឆាំងអំពើពុករលួយ, គ.ស.ហ) | | | | |
| ៥.១.១ | បង្កើនធនធានដើម្បីគាំទ្រការស៊ើបអង្កេតបទល្មើស ស.ប.ហ.ភ | | | | |
| ៥.១.១.១ | បង្កើនថវិកាសម្រាប់ការស៊ើបអង្កេតបទល្មើស ស.ប.ហ.ភ និងការស៊ើបអង្កេតសំអាងនៃបទល្មើស ដែលមានហានិភ័យខ្ពស់ | ១ | មករា ២០១៩- មករា ២០២០ | -ក្រុមការងារបច្ចេកទេសអន្តរក្រសួងប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម (ផ្នែកអនុវត្តច្បាប់) | -អាជ្ញាធរអនុវត្តច្បាប់ទាំងអស់ |
| ៥.១.១.២ | ពិចារណាបង្កើតមូលនិធិនៃទ្រព្យដែលរឹបអូសបានដើម្បីគាំទ្រដល់ការស៊ើបអង្កេតនិងការចោទប្រកាន់បទល្មើសហិរញ្ញវត្ថុនិងការរឹបអូសទ្រព្យ | ២ | មករា - ធ្នូ ២០២១ | -គណៈកម្មាធិការសម្របសម្រួលថ្នាក់ជាតិប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម | -ក្រុមការងារបច្ចេកទេសអន្តរក្រសួងប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម |

| គោលបំណង | សកម្មភាព | អាទិភាព | ពេលវេលា | ក្រសួង-ស្ថាប័នដឹកនាំ | ក្រសួង-ស្ថាប័នពាក់ព័ន្ធ |
|---|---|---|---|---|---|
| ៥.១.២ | កសាងសមត្ថភាពតាមរយៈការបណ្តុះបណ្តាល | | | | |
| ៥.១.២.១ | វាយតម្លៃពីតម្រូវការបណ្តុះបណ្តាលចាំបាច់សម្រាប់ឲ្យអាជ្ញាធរអនុវត្តច្បាប់មានលទ្ធភាព | ១ | មករា ២០១៩-មករា ២០២០ | -ក្រុមការងារអន្តរក្រសួងប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម (ផ្នែកអនុវត្តច្បាប់) | -អាជ្ញាធរអនុវត្តច្បាប់ទាំងអស់ |
| ៥.១.២.២ | បណ្តុះបណ្តាលសមត្ថភាពអ្នកស៊ើបអង្កេតការប្រឆាំង ស.ប.ហ.ភ រួមទាំងការបណ្តុះបណ្តាលគ្រូបង្គោល | ២ | មករា ២០១៩-មករា ២០២១ | -ក្រុមការងារអន្តរក្រសួងប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម (ផ្នែកអនុវត្តច្បាប់) | -អាជ្ញាធរអនុវត្តច្បាប់ទាំងអស់ |
| ៥.១.២.៣ | បង្កើតនិងអនុវត្តនីតិវិធីប្រតិបត្តិការស្តង់ដានិងក្បួនសម្រាប់រៀបចំការស៊ើបអង្កេតបទល្មើស ស.ប.ហ.ភ | ១ | តុលា ២០១៨-មករា ២០២០ | -ក្រុមការងារអន្តរក្រសួងប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម (ផ្នែកអនុវត្តច្បាប់) | -អាជ្ញាធរអនុវត្តច្បាប់ទាំងអស់ |
| ៥.១.២.៤ | បង្កើតបណ្តាញទំនាក់ទំនងប្រតិបត្តិការឲ្យមានប្រសិទ្ធភាពរវាងអាជ្ញាធរអនុវត្តច្បាប់ | ១ | មករា ២០១៩-មករា ២០២០ | -ក្រុមការងារអន្តរក្រសួងប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម (ផ្នែកអនុវត្តច្បាប់) | -អាជ្ញាធរអនុវត្តច្បាប់ទាំងអស់ |
| ៥.១.២.៥ | បង្កើតក្រុមការងារបច្ចេកទេសអន្តរក្រសួងផ្នែកអាជ្ញាធរអនុវត្តច្បាប់ដើម្បីជំរុញកិច្ចសហប្រតិបត្តិការជាតិ | ១ | មករា ២០១៩-មករា ២០២០ | -ក្រុមការងារអន្តរក្រសួងប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម (ផ្នែកអនុវត្តច្បាប់) | -អាជ្ញាធរមានសមត្ថកិច្ចទាំងអស់ |
| ៥.១.២.៦ | បង្កើតក្រុមការងារពិសេសសម្រាប់ការស៊ើបអង្កេតការតេពន្ធសាច់ប្រាក់ឆ្លងដែនឲ្យមានប្រសិទ្ធភាព | ១ | មករា-ធ្នូ ២០១៩ | -អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា | -អាជ្ញាធរអនុវត្តច្បាប់ទាំងអស់ |

| គោលបំណង | សកម្មភាព | អាទិភាព | ពេលវេលា | ក្រសួង-ស្ថាប័នដឹកនាំ | ក្រសួង-ស្ថាប័នពាក់ព័ន្ធ |
|---|---|---|---|---|---|
| ៥.១.២.៧ | ពង្រឹងការចូលយកកំណត់ត្រារបស់ក្រសួង-ស្ថាប័នពាក់ព័ន្ធ សម្រាប់ការស៊ើបអង្កេតការសម្អាតប្រាក់របស់អាជ្ញាធរអនុវត្តច្បាប់ | ១ | មករា ២០១៩- មករា ២០២១ | -ក្រុមការងារអន្តរក្រសួងប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម (ផ្នែកអនុវត្តច្បាប់) | -អាជ្ញាធរអនុវត្តច្បាប់ទាំងអស់ |
| ៥.១.៣ | បង្កើតក្រុមការងារពិសេសទទួលបន្ទុកស៊ើបអង្កេតបទល្មើសសម្អាតប្រាក់ | | | | |
| ៥.១.៣.១ | ពង្រីកសមត្ថភាពរួមទាំងធនធានមនុស្សរបស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ដើម្បីអនុវត្តការស៊ើបអង្កេតបទល្មើសឆ្លងដែនទាក់ទង ស.ប.ហ.ភ | ១ | មករា - ធ្នូ ២០១៩ | -អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា | -អាជ្ញាធរអនុវត្តច្បាប់ទាំងអស់ |
| ៥.១.៣.២ | បង្កើតរចនាសម្ព័ន្ធមួយដែលមានប្រសិទ្ធភាពសម្រាប់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា រួមទាំងការផ្តល់ការបណ្តុះបណ្តាលគ្រូបង្គោល និងបង្កើតក្បួននិងគោលនយោបាយនិងនីតិវិធីសម្រាប់ស៊ើបអង្កេតការសម្អាតប្រាក់ទម្រង់ជាពាណិជ្ជកម្មនិងការរត់ពន្ធសាច់ប្រាក់ទាក់ទង ស.ប.ហ.ភ | ១ | មករា - ធ្នូ ២០១៩ | -អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា | -អាជ្ញាធរអនុវត្តច្បាប់ទាំងអស់ |
| ៥.១.៣.៣ | បង្កើនធនធាននិងបង្កើតក្រុមការងារពិសេសធ្វើការរួមគ្នាជាមួយ ស.ហ.ក និងអាជ្ញាធរអនុវត្តច្បាប់សម្រាប់កំណត់គោលដៅនិងអនុវត្តការស៊ើបអង្កេតការរត់ពន្ធសាច់ប្រាក់ទាក់ទង ស.ប.ហ.ភ | ១ | វិច្ឆិកា ២០១៨ - មករា ២០២០ | -អាជ្ញាធរអនុវត្តច្បាប់ទាំងអស់ | -អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា |

| គោលបំណង | សកម្មភាព | អាទិភាព | ពេលវេលា | ក្រសួង-ស្ថាប័នដឹកនាំ | ក្រសួង-ស្ថាប័នពាក់ព័ន្ធ |
|---|---|---|---|---|---|
| ៥.១.៤ | ពិចារណាបង្កើតក្រុមការងារពិសេសអន្តរក្រសួង ដើម្បីទទួលខុសត្រូវស៊ើបអង្កេតពហុយុត្តាធិការឬអន្តរជាតិឬការស៊ើបអង្កេតពាក់ព័ន្ធ ករណី ស.ប.ហ.ភ ធំនិងស្មុគស្មាញ  រួមមាន អគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ ក្រសួងយុត្តិធម៌ អង្គភាពប្រឆាំងអំពើពុករលួយ និងអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា[6] ជាដើម | | | | |
| ៥.១.៤.១ | ពិចារណាបង្កើតក្រុមការងារអន្តរក្រសួងសម្រាប់ស៊ើបអង្កេតបទល្មើសរត់ពន្ធសាច់ប្រាក់ឆ្លងដែន រួមមានអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ អគ្គស្នងការដ្ឋាននគរបាលជាតិ | ១ | មករា - ធ្នូ ២០១៩ | -អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា | -ក្រសួងមហាផ្ទៃ<br>-អគ្គនាយកដ្ឋានពន្ធដារ<br>-អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា |
| ៥.២ | បង្កើនការស៊ើបអង្កេតការសម្អាតប្រាក់ និងបទល្មើសហិរញ្ញវត្ថុ | | | | |
| ៥.២.១ | វិភាគពីតម្រូវការថ្នាក់ជាតិនិងផែនការយុទ្ធសាស្ត្រស្របតាមរបាយការណ៍វាយតម្លៃហានិភ័យថ្នាក់ជាតិដើម្បីកំណត់រករចនាសម្ព័ន្ធគោលនយោបាយនិងនីតិវិធីធនធានការបណ្តុះបណ្តាលអ្នកស៊ើបអង្កេតថវិកានិងតម្រូវការផ្សេងទៀត ដែលធានាឲ្យអាជ្ញាធរមានលទ្ធភាព ធ្វើការស៊ើបអង្កេតចោទប្រកាន់ កាត់ទោសនិងរឹបអូសផលនៃបទល្មើសសម្អាតប្រាក់និងសំអាងនៃបទល្មើសផ្សេងៗទៀតប្រកបដោយប្រសិទ្ធភាព | ២ | មករា - ធ្នូ ២០២១ | -អាជ្ញាធរអនុវត្តច្បាប់ទាំងអស់<br>-អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា | -គ្រប់ភាគីពាក់ព័ន្ធ |

[6] ដឹកនាំដោយ អគ្គស្នងការដ្ឋាននគរបាលជាតិ និងស្ថិតនៅទីតាំងសំខាន់

| គោលបំណង | សកម្មភាព | អាទិភាព | ពេលវេលា | ក្រសួង-ស្ថាប័នដឹកនាំ | ក្រសួង-ស្ថាប័នពាក់ព័ន្ធ |
|---|---|---|---|---|---|
| ៥.២.២ | បង្កើតក្រុមការងារពិសេស សម្រាប់អាជ្ញាធរអនុវត្តច្បាប់ដោយផ្តល់ធនធានគ្រប់គ្រាន់ (ថវិកា និងបុគ្គលិក) ចាំបាច់សម្រាប់ការស៊ើបអង្កេតការសម្អាតប្រាក់ការបណ្តុះបណ្តាល ការបង្កើតក្បួននិងគោលនយោបាយនិងនីតិវិធី | ១ | មករា ២០១៩-មករា ២០២០ | -អាជ្ញាធរអនុវត្តច្បាប់ទាំងអស់ | -ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ |
| ៥.២.៣ | បង្កើតគោលនយោបាយនិងយុទ្ធសាស្ត្រផ្ទៃក្នុងសម្រាប់អ្នកស៊ើបអង្កេតបទល្មើសសម្អាតប្រាក់ | ១ | មករា ២០១៩-មករា ២០២១ | -អាជ្ញាធរអនុវត្តច្បាប់ទាំងអស់ | |
| **៦.ការជំរុញប្រសិទ្ធភាពនៃការចោទប្រកាន់ការសម្អាតប្រាក់និងសំអាងនៃបទល្មើស** | | | | | |
| ៦.១ | បង្កើនធនធានសម្រាប់ការចោទប្រកាន់ពីបទសម្អាតប្រាក់និងសំអាងនៃបទល្មើស | | | | |
| ៦.១.១ | បង្កើនធនធានសម្រាប់ចោទប្រកាន់បទសម្អាតប្រាក់ | | | | |
| ៦.១.១.១ | ផ្តល់មូលនិធិបន្ថែមដើម្បីគាំទ្រដល់ការចោទប្រកាន់ការសម្អាតប្រាក់និងសំអាងនៃបទល្មើសដែលមានហានិភ័យខ្ពស់ | ១ | មករា - ធ្នូ ២០១៩ | -ក្រសួងយុត្តិធម៌ | -ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ |
| ៦.១.២ | កសាងសមត្ថភាពតាមរយៈការបណ្តុះបណ្តាល | | | | |
| ៦.១.២.១ | បង្កើតកម្មវិធីបណ្តុះបណ្តាលឯកទេសលើការចោទប្រកាន់ផ្នែកហិរញ្ញវត្ថុដល់មន្ត្រីទទួលបន្ទុកករណីសម្អាតប្រាក់ | ១ | មករា - ធ្នូ ២០១៩ | -ក្រសួងយុត្តិធម៌ | -ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ |

| គោលបំណង | សកម្មភាព | អាទិភាព | ពេលវេលា | ក្រសួង-ស្ថាប័នដឹកនាំ | ក្រសួង-ស្ថាប័នពាក់ព័ន្ធ |
|---|---|---|---|---|---|
| ៦.១.២.២ | បណ្តុះបណ្តាលព្រះរាជអាជ្ញាពីក្របខ័ណ្ឌច្បាប់ និងនីតិវិធីសម្រាប់ដោះស្រាយករណីសម្អាតប្រាក់និងសំអាងនៃបទល្មើស | ១ | មករា - ធ្នូ ២០១៩ | -ក្រសួងយុត្តិធម៌ | -ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ |
| ៦.១.៣ | បង្កើតក្រុមការងារពិសេសទទួលបន្ទុកការចោទប្រកាន់ការសម្អាតប្រាក់ | | | -ក្រសួងយុត្តិធម៌ | |
| ៦.១.៣.១ | បង្កើតក្រុមការងារពិសេសប្រឆាំងការសម្អាតប្រាក់ នៅក្រោមក្រសួងយុត្តិធម៌ សម្រាប់ចោទប្រកាន់បទសម្អាតប្រាក់ (ក៏អាចទទួលខុសត្រូវលើការងាររឹបអូសផងដែរ) | ១ | មករា - ធ្នូ ២០១៩ | -ក្រសួងយុត្តិធម៌ | |
| ៦.២ | កំណត់អាទិភាពការចោទប្រកាន់បទសម្អាតប្រាក់ | | | | |
| ៦.២.១ | បង្កើតគោលនយោបាយនិងយុទ្ធសាស្ត្រផ្ទៃក្នុងដើម្បីចោទប្រកាន់ការសម្អាតប្រាក់ | ២ | មករា-ធ្នូ ២០២១ | | |
| ៦.២.២ | បង្កើតនីតិវិធិប្រតិបត្តិការស្តង់ដាដើម្បីអនុវត្តចំណុច៦.២.១ | ១ | មករា - ធ្នូ ២០១៩ | -ក្រសួងយុត្តិធម៌ | |
| ៦.២.៣ | បង្កើតមន្ត្រីទំនាក់ទំនងរវាងក្រុមការងារពិសេសប្រឆាំងការសម្អាតប្រាក់ ជាមួយនឹង ១/- ក្រុមទទួលខុសត្រូវការចោទប្រកាន់សំអាងនៃបទល្មើស (ជាពិសេសបទល្មើសមានហានិភ័យខ្ពស់) ២/- ក្រុមស៊ើបអង្កេតទទួលខុសត្រូវ | ១ | មករា - ធ្នូ ២០១៩ | -ក្រសួងយុត្តិធម៌ | |

| គោលបំណង | សកម្មភាព | អាទិភាព | ពេលវេលា | ក្រសួង-ស្ថាប័នដឹកនាំ | ក្រសួង-ស្ថាប័នពាក់ព័ន្ធ |
|---|---|---|---|---|---|
| | ការស៊ើបអង្កេតបទសម្អាតប្រាក់និង៣/- ក្រុមទទួលខុសត្រូវការរឹបអូស | | | | |
| ៦.២.៤ | បង្កើតមន្ត្រីទំនាក់ទំនងរវាងក្រុមការងារពិសេសប្រឆាំងការសម្អាតប្រាក់ ជាមួយនឹងភ្នាក់ងារផ្សេងទៀតដែលអាចគាំទ្រការចោទប្រកាន់ការសម្អាតប្រាក់ឬទទួលសំណៅដើម (Referral) នៃករណីទាក់ទងការសម្អាតប្រាក់ពីអាជ្ញាធរណាមួយ(ឧ. អាជ្ញាធរពន្ធ) ពុំអាចចោទប្រកាន់ពីបទសម្អាតប្រាក់ | ១ | មករា - ធ្នូ ២០១៩ | -ក្រសួងយុត្តិធម៌ | -អគ្គនាយកដ្ឋានពន្ធដារ |
| **៧.ការជំរុញប្រសិទ្ធភាពនៃការរឹបអូសផលនៃបទល្មើស** | | | | | |
| ៧.១ | ពង្រឹងសមត្ថភាពក្រសួង-ស្ថាប័នទទួលខុសត្រូវរឹបអូសឧបករណ៍និងផលនៃបទល្មើស | | | | |
| ៧.១.១ | កសាងសមត្ថភាពតាមរយៈការបណ្តុះបណ្តាល | | | | |
| ៧.១.១.១ | បណ្តុះបណ្តាលដល់មន្ត្រីទទួលភារកិច្ចក្នុងក្រុមការងារពិសេសឯកទេសខាងការរឹបអូស | ១ | មករា - ធ្នូ ២០១៩ | -ក្រសួងយុត្តិធម៌ | -ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ |
| ៧.១.១.២ | បណ្តុះបណ្តាលព្រះរាជអាជ្ញាពីគោលនយោបាយនីតិវិធី និងក្របខណ្ឌច្បាប់សម្រាប់ការរឹបអូសផលនិងឧបករណ៍នៃបទល្មើស | ១ | មករា - ធ្នូ ២០១៩ | -ក្រសួងយុត្តិធម៌ | -ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ |

| គោលបំណង | សកម្មភាព | អាទិភាព | ពេលវេលា | ក្រសួង-ស្ថាប័នដឹកនាំ | ក្រសួង-ស្ថាប័នពាក់ព័ន្ធ |
|---|---|---|---|---|---|
| ៧.១.២ | បែងចែកធនធានមន្ត្រីនិងបំពាក់បំប៉នជំនាញឯកទេស | ១ | មករា-ធ្នូ ២០១៩ | -ក្រសួងយុត្តិធម៌ | -ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ |
| ៧.១.២.១ | បែងចែកធនធានបន្ថែមសម្រាប់ការងាររឹបអូសដល់អ្នកស៊ើបអង្កេតនិងការចោទប្រកាន់ | ១ | មករា - ធ្នូ ២០១៩ | -ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | -ក្រសួងយុត្តិធម៌<br>-អគ្គស្នងការដ្ឋាននគរបាលជាតិ |
| ៧.១.២.២ | បង្កើតក្រុមការងារពិសេសឯកទេសនៅក្រសួងយុត្តិធម៌និងអគ្គស្នងការដ្ឋាននគរបាលជាតិសម្រាប់ការងាររឹបអូសការស៊ើបអង្កេតនិងការចោទប្រកាន់ | ១ | មករា - ធ្នូ ២០១៩ | -ក្រសួងយុត្តិធម៌<br>-អគ្គស្នងការដ្ឋាននគរបាលជាតិ | -អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា<br>-អាជ្ញាធរអនុវត្តច្បាប់ទាំងអស់ |
| ៧.២ | ការកំណត់អាទិភាពការរឹបអូសផលនៃបទល្មើស | | | | |
| ៧.២.១ | បង្កើតគោលនយោបាយឬយុទ្ធសាស្ត្រជាតិរឹបអូសសាច់ប្រាក់ឆ្លងដែនដែលពុំមានការធ្វើប្រតិវេទន៍ឬប្រតិវេទន៍ក្លែងបន្លំ | ១ | មករា - ធ្នូ ២០១៩ | -អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា | -ក្រសួងយុត្តិធម៌<br>-អគ្គស្នងការដ្ឋាននគរបាលជាតិ<br>-អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា |
| ៧.២.២ | បង្កើតគោលនយោបាយយុទ្ធសាស្ត្រនិងនីតិវិធីប្រតិបត្តិការស្តង់ដាផ្ទៃក្នុងសម្រាប់ការរឹបអូសផលនិងឧបករណ៍នៃបទល្មើស | ១ | មករា - ធ្នូ ២០១៩ | -ក្រសួងយុត្តិធម៌ | |

| គោលបំណង | សកម្មភាព | អាទិភាព | ពេលវេលា | ក្រសួង-ស្ថាប័នដឹកនាំ | ក្រសួង-ស្ថាប័នពាក់ព័ន្ធ |
|---|---|---|---|---|---|
| **៨.កិច្ចសហប្រតិបត្តិការអន្តរជាតិ** | | | | | |
| ៨.១ | កែលម្អក្របខ័ណ្ឌច្បាប់ដើម្បីជំរុញកិច្ចសហប្រតិបត្តិការអន្តរជាតិ | | | | |
| ៨.១.១ | អនុម័តច្បាប់ស្ដីពីជំនួយផ្នែកច្បាប់ទៅវិញទៅមកក្នុងវិស័យព្រហ្មទណ្ឌ (MLA) និងបង្កើនធនធានបុគ្គលិកសម្រាប់អាជ្ញាធរកណ្ដាលអនុវត្តច្បាប់ MLA | ១ | កក្កដា ២០១៩ (ទីស្ដីការគណៈរដ្ឋមន្ត្រី) | -ក្រសួងយុត្តិធម៌ | |
| ៨.២ | កែលម្អការអនុវត្តការងាររបស់ក្រសួង-ស្ថាប័នដើម្បីធានាប្រសិទ្ធភាពនៃកិច្ចសហប្រតិបត្តិការអន្តរជាតិ | | | | |
| ៨.២.១ | បង្កើតនីតិវិធីប្រតិបត្តិការស្តង់ដាផ្ទៃក្នុងដើម្បីកំណត់អាទិភាពនិងអនុវត្តសំណើសុំកិច្ចសហប្រតិបត្តិការអន្តរជាតិ | ១ | កុម្ភៈ - ធ្នូ ២០១៩ | -ក្រសួងយុត្តិធម៌ | |
| ៨.២.២ | បង្កើតប្រព័ន្ធគ្រប់គ្រងសំណុំរឿងសម្រាប់ដំណើរការលើការស្នើសុំនិងការទទួលសំណើសុំកិច្ចសហប្រតិបត្តិការអន្តរជាតិ | ១ | ២០១៨ - ធ្នូ ២០១៩ | -ក្រសួងយុត្តិធម៌ | |
| ៨.២.៣ | បង្កើនបុគ្គលិកនិងធនធនសម្រាប់អាជ្ញាធរកណ្តាលដើម្បីអនុវត្តច្បាប់ស្តីពីជំនួយផ្នែកច្បាប់ទៅវិញទៅមកក្នុងវិស័យព្រហ្មទណ្ឌ | ១ | ធ្នូ ២០១៩ (៤-៦ នាក់)<br>ធ្នូ ២០២០-២០២៣ (៤-៦ នាក់) | -ក្រសួងយុត្តិធម៌ | |

| គោលបំណង | សកម្មភាព | អាទិភាព | ពេលវេលា | ក្រសួង-ស្ថាប័នដឹកនាំ | ក្រសួង-ស្ថាប័នពាក់ព័ន្ធ |
|---|---|---|---|---|---|
| **៩.ការប្រឆាំងហិរញ្ញប្បទានភេរវកម្មនិងហិរញ្ញប្បទានការរីកសាយភាយអាវុធមហាប្រល័យ** | | | | | |
| ៩.១ | កែលម្អក្របខ័ណ្ឌច្បាប់ដើម្បីប្រឆាំងហិរញ្ញប្បទានការរីកសាយភាយអាវុធមហាប្រល័យ | | | | |
| ៩.១.១ | ចេញផ្សាយលិខិតបទដ្ឋានគតិយុត្តិដើម្បីអនុវត្តសេចក្តីសម្រេចចិត្តរបស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិប្រឆាំងនឹងការរីកសាយភាយអាវុធមហាប្រល័យ | ១ | មករា - ធ្នូ ២០១៩ | -ក្រសួងមហាផ្ទៃ | -គ្រប់ភាគីពាក់ព័ន្ធ |
| ៩.២ | សហការជាមួយវិស័យឯកជនក្នុងការប្រឆាំងហិរញ្ញប្បទានការរីកសាយភាយអាវុធមហាប្រល័យ | | | | |
| ៩.២.១ | វាយតម្លៃហានិភ័យនៃការប្រើប្រាស់សេដ្ឋកិច្ចកម្ពុជា ដោយប្រយោលឬដោយផ្ទាល់សម្រាប់គេចវេសពីទណ្ឌកម្មរបស់អង្គការសហប្រជាជាតិពាក់ព័ន្ធនឹងការរីកសាយភាយអាវុធមហា-ប្រល័យ | ២ | មករា-ធ្នូ ២០២០ | -ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ<br>-ក្រសួងពាណិជ្ជកម្ម<br>- អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា | -គ្រប់ភាគីសាធារណៈពាក់ព័ន្ធ |
| ៩.២.២ | រៀបចំលើកកម្ពស់ការយល់ដឹងជាមួយវិស័យឯកជនពីហានិភ័យហិរញ្ញប្បទានលើការរីកសាយភាយអាវុធមហាប្រល័យនិងកាតព្វកិច្ចបង្កកទ្រព្យ | ៣ | មករា-ធ្នូ ២០២២ | -ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ<br>-ក្រសួងពាណិជ្ជកម្ម<br>- អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា | -គ្រប់ភាគីសាធារណៈពាក់ព័ន្ធ |
| ៩.២.៣ | ចេញសេចក្តីណែនាំពីហិរញ្ញប្បទានលើការរីកសាយភាយអាវុធមហាប្រល័យដល់វិស័យឯកជន | ៣ | មករា - ធ្នូ ២០២២ | -ក្រសួងមហាផ្ទៃ<br>-អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា | -បុគ្គលរាយការណ៍និងវិស័យនានា |

| គោលបំណង | សកម្មភាព | អាទិភាព | ពេលវេលា | ក្រសួង-ស្ថាប័នដឹកនាំ | ក្រសួង-ស្ថាប័នពាក់ព័ន្ធ |
|---|---|---|---|---|---|
| **១០.ការគ្រប់គ្រងយុទ្ធសាស្ត្រជាតិស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម** | | | | | |
| ១០.១ | តាមដានការអនុវត្តយុទ្ធសាស្ត្រជាតិឆ្នាំ២០១៩-២០២៣ | | | | |
| ១០.១.១ | បង្កើតក្រុមការងាររដ្ឋបាលមួយទទួលបន្ទុកតាមដានវឌ្ឍនភាពនៃការអនុវត្តយុទ្ធសាស្ត្រជាតិឆ្នាំ២០១៩-២០២៣ | ១ | ភ្លាមៗ | -គណៈកម្មាធិការសម្របសម្រួលថ្នាក់ជាតិប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម | -អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា |
| ១០.១.២ | បង្កើតកញ្ចប់ថវិកាសម្រាប់ប្រតិបត្តិការរបស់ក្រុមការងាររដ្ឋបាល | ១ | មករា-ធ្នូ ២០១៩ | - ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ<br>-ធនាគារជាតិនៃកម្ពុជា | |
| ១០.១.៣ | រៀបចំនីតិវិធីដោះស្រាយបញ្ហានៃការអនុវត្ត | ១ | មករា-ធ្នូ ២០១៩ | -គណៈកម្មាធិការសម្របសម្រួលថ្នាក់ជាតិប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម | -ក្រុមការងារអន្តរក្រសួងប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម |
| ១០.១.៤ | បង្កើតយន្តការរាយការណ៍ទៀងទាត់មួយពីក្រសួង-ស្ថាប័នពាក់ព័ន្ធដើម្បីទទួលបានព័ត៌មានថ្មីៗ | ១ | មករា-ធ្នូ ២០១៩ | -គណៈកម្មាធិការសម្របសម្រួលថ្នាក់ជាតិប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម<br>-ក្រុមការងារអន្តរក្រសួងប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម | -អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា |
| ១០.១.៥ | បង្កើតយន្តការរាយការណ៍ទៀងទាត់ទៅ គ.ស.ហ | ១ | មករា-ធ្នូ ២០១៩ | -គណៈកម្មាធិការសម្របសម្រួលថ្នាក់ជាតិប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម<br>-ក្រុមការងារអន្តរក្រសួងប្រឆាំងការសម្អាត | -អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា |

| គោលបំណង | សកម្មភាព | អាទិភាព | ពេលវេលា | ក្រសួង-ស្ថាប័នដឹកនាំ | ក្រសួង-ស្ថាប័នពាក់ព័ន្ធ |
|---|---|---|---|---|---|
| | | | | ប្រាក់និងហិរញ្ញប្បទានភេរវកម្ម | |
| ១០.១.៦ | រៀបចំកិច្ចប្រជុំតាមកាលវិភាគ និងពិនិត្យពីលទ្ធផលការងារតាមពេលវេលាដែលបានកំណត់ | ១ | មករា-ធ្នូ ២០១៩ | -គណៈកម្មាធិការសម្របសម្រួលថ្នាក់ជាតិប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម<br>-ក្រុមការងារអន្តរក្រសួងប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម | -អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា |
| ១០.២ | ឧបត្ថម្ភគាំទ្រសកម្មភាពក្នុងយុទ្ធសាស្ត្រជាតិឆ្នាំ២០១៩-២០២៣ | | | | |
| ១០.២.១ | បង្កើតយន្តការបន្ថែមផ្នែកហិរញ្ញវត្ថុ ដើម្បីបង្កើនថវិកាគាំទ្រការអនុវត្តផែនការសកម្មភាពនៅក្នុងយុទ្ធសាស្ត្រជាតិ ឆ្នាំ២០១៩-២០២៣ | ១ | ភ្លាមៗ | -គណៈកម្មាធិការសម្របសម្រួលថ្នាក់ជាតិប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម | -ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ<br>-ធនាគារជាតិនៃកម្ពុជា<br>-អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា |
| ១០.២.២ | រៀបចំរបាយការណ៍អំពីការផ្តល់មូលនិធិសម្រាប់ការអនុវត្តយុទ្ធសាស្ត្រជាតិនេះ និងបញ្ជូនទៅ គ.ស.ហ | ១ | មករា-ធ្នូ ២០១៩ | -ក្រុមការងារអន្តរក្រសួងប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម | -អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា |
| ១០.២.៣ | អនុវត្តការរៀបចំមូលនិធិថ្មី | ១ | មករា-ធ្នូ ២០១៩ | -គណៈកម្មាធិការសម្របសម្រួលថ្នាក់ជាតិប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម | -ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ<br>-ធនាគារជាតិនៃកម្ពុជា<br>-អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា |